ឧបត្ថម្ភដោយ:

សម្ព័ន្ធភាពតំបន់ដីសើម

THE WETLANDS ALLIANCE

BUILDING LOCAL CAPACITY FOR SUSTAINABLE WETLANDS MANAGEMENT

សមាគមថែរក្សាបរិស្ថាន និង វប្បធម

Culture and Environment Preservation Associatio

# លទ្ធផលសិក្សាឧបករណ៍នេសាទ

# របស់អ្នកស្រាវជ្រាវគម្រោងសាលាភូមិ



បោះពុម្ពឆ្នាំ២០១២

ស្រាវជ្រាវដោយៈ    អ្នកស្រាវជ្រាវសាលាភូមិ

សំរបសំរួលដោយៈ គម្រោងសាលាភូមិ(សមាគមថែរក្សាបរិស្ថាន និងវប្បធម៌)

រៀបរៀង និងកែសម្រួលដោយៈ

- លោក អ៊ុយ សុភាវីរៈ អ្នកសម្របសម្រួលគម្រោងសាលាភូមិ
- លោក សុខ ចក្រី ជំនួយការអ្នកស្រាជ្រាវ
- លោក សេង សុធា ជំនួយការអ្នកស្រាជ្រាវ
- លោក អ៊ុន វណ្ណៈ ជំនួយការអ្នកស្រាជ្រាវ

ត្រួតពិនិត្យ និងកែសំរួលដោយៈ

- លោក ទេព ប៊ុណ្ណារិទ្ធិ នាយកប្រតិបត្តិ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌
- លោក ម៉ម កុសល មជ្ឈមណ្ឌលត្រីពិភពលោក
- លោក អៀម ឌីណា មជ្ឈមណ្ឌលត្រីពិភពលោក
- លោកស្រី ជា សិលា មជ្ឈមណ្ឌលត្រីពិភពលោក

WorldFish    THE WETLANDS ALLIANCE
BUILDING LOCAL CAPACITY FOR SUSTAINABLE WETLANDS MANAGEMENT    CEPA

មតិយោបល់ដែលលើកឡើងនៅក្នុងសៀវភៅនេះ គឺឆ្លុះបញ្ចាំងពីទស្សនទាន របស់សហគមន៍ អ្នកស្រាវជ្រាវសាលាភូមិនិងពីសំណាក់អ្នកពាក់ព័ន្ធនានាចំពោះគំរោងសាលាភូមិ ។ ដូច្នេះអត្ថបទទាំងមូលមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនទានរបស់ មជ្ឈមណ្ឌលត្រីពិភពលោក សម្ព័ន្ធភាពតំបន់ដីសើម និងអង្គការសេប៉ាឡើយ ។

# មាតិកា

**១.សេចក្តីថ្លែងអំណរគុណ** ១

**២.សង្ខេបព័ត៌មានរួម** ៣

**៣.សេចក្តីផ្តើម** ៩

**៤.សាវតាភូមិ** ១១

**ជំពូក ១: ឧបករណ៍ដង ជួស និងជញ្ជ្រាត់**

១.ឈ្នាងជញ្ជ្រាត់ ៣១

២.កញ្ច្រែងជួសត្រី ៣៣

៣.ថ្នងដេញត្រី ៣៥

**ជំពូក ២: ឧបករណ៍សន្ទូច**

**២.១ សន្ទូចនោល**

២.១.១ សន្ទូចបបក់ ៣៧

២.១.២ សន្ទូចរ៉ាត់ ៣៩

**២.២ សន្ទូចបង្កៃ**

២.២.១ សន្ទូចបង្កៃត្រីរ៉ស ៤១

២.២.២ សន្ទូចពុម្ពបង្កៃត្រីខ្យា ៤៣

២.២.៣ សន្ទូចបង្កៃ ៤៥

**២.៣ សន្ទូចរនង**

២.៣.១ សន្ទូចរនងរឺសន្ទូចបណ្ដែតលើ ៤៧

២.៣.២ សន្ទូចសំយ៉ាប ៤៩

២.៣.៣ សន្ទូចសំយ៉ុង ៥១

២.៣.៤ សន្ទូចពុម្ពតូច ៥៣

**ជំពូក ៣: ឧបករណ៍អន្ទាក់**

**៣.១ លាយ ជុច ចាន់**

៣.១.១ លាយ ៥៥

៣.១.២ ជុច ៥៧

៣.១.៣ ចាន់ ៥៩

**៣.២ អន្ទាក់ទ្រូង**

៣.២.១ សៃយ៉ឺន ៦៣

៣.២.២ សាប ៦៥

៣.២.៣ ទ្រូ ៦៧

៣.២.៤ លបប្រើសពីរ ៦៩

៣.២.៥ លាន់ ៧១

៣.២.៦ តុម ៧៣

៣.២.៧ ប៉ោង ៧៥

**ជំពូក ៤: ឧបករណ៍មង**

៤.១ មងពន្លិច ៧៧

៤.១ មងបណ្ដែត ៧៩

៤.១ មងត្រីរៀល ៨១

**ជំពូក ៥: ឧបករណ៍គ្រូងគ្រប**

**៥.១ ឧបករណ៍គ្រូងគ្រប**

៥.១.១ អង្រុត ៨៣

**៥.២ ឧបករណ៍សំណាញ់**

៥.២.១ សំណាញ់ ៨៥

**ជំពូក ៦: ឧបករណ៍ធ្វើអោយត្រីថ្គី**

៦.១ ឈ្នាងត្រាំ ៨៧

៦.២ កន្ទុំ ៨៩

**ជំពូក ៧: ឧបករណ៍លំពែង**

៧.១ សាង ៩១

**មជ្ឈមណ្ឌលត្រីពិភពលោក** ៩៣

**សម្ព័ន្ធភាពតំបន់ដីសើម** ៩៥

**អត្ថការសេចំ** ៩៧

**បញ្ជីឈ្មោះអ្នកស្រាវជ្រាវ** ៩៨

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំចងក្រង សៀវភៅឧបករណ៍នេសាទមួយក្បាលនេះឡើង គឺពិតជាមិនអាចសម្រេចជោគជ័យឡើយ ប្រសិនបើគ្មានការចូលរួមសហប្រតិបត្តិការពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការលើកទឹកចិត្ត ការគាំទ្រ ការជំរុញ ការលះបង់កម្លាំងកាយ កម្លាំងចិត្ត ពេលវេលា និងសម្ភារៈ ទើបអាចសម្រេចបាន ជាផ្លែផ្កាក្នុងការសិក្សាស្រាវជ្រាវនេះ។

ក្រុមអ្នកស្រាវជ្រាវយើងខ្ញុំសូមធ្វើគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តម ឡូយ សុផាត អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងលោកអភិបាលរង ដែលបានគាំទ្រ និងលើកទឹកចិត្តអ្នកភូមិក្នុងមូលដ្ឋាន ក៏ដូចជាអ្នកស្រាវជ្រាវទាំងអស់ឲ្យខិតខំស្រាវជ្រាវ ប្រមូលព័ត៌មាន ទាក់ទងទៅនឹងឧបករណ៍នេសាទនេះ ។

យើងក៏សូមថ្លែងអំណរគុណចំពោះលោក ទេព ប៊ុណ្ណារិទ្ធិ នាយកប្រតិបត្តិអង្គការសេប៉ា (CEPA) លោក Alan Brooks លោក Mark Dubois លោក ម៉មកុសល លោក អៀម ឌីណា និងលោកស្រី ជា សីលា តំណាងមជ្ឈមណ្ឌលត្រីពិភពលោក ប្រចាំតំបន់មេគង្គ ដែលបានជួយគាំទ្រផ្នែកបច្ចេកទេស និងមជ្ឈមណ្ឌលត្រីពិភពលោកប្រចាំតំបន់មេគង្គដែលបានផ្តល់ថវិកាតាមរយៈសម្ព័ន្ធភាពតំបន់ដីសើម។

ចំពោះការគាំទ្រផ្នែកបច្ចេកទេសផ្ទាល់ ការបណ្តុះបណ្តាលអ្នកស្រាវជ្រាវ និងជួយសម្របសម្រួលក្នុងការស្រាវជ្រាវ រៀបចំសិក្ខាសាលាតាំងពីថ្នាក់ភូមិ ដល់ថ្នាក់ខេត្ត ក្រុមអ្នកស្រាវជ្រាវទាំងអស់ សូមថ្លែងអំណរគុណជាអនេកកប្បការចំពោះលោក អ៊ុយ សុភាវីរៈ អ្នកសម្របសម្រួលគំរោងសាលាភូមិ និងលោក សុខចក្រី លោក សេង សុធា ដែលជាជំនួយការអ្នកស្រាវជ្រាវ។

យើងខ្ញុំក៏មិនភ្លេចសូមថ្លែងអំណរគុណដល់អតីតអ្នកស្រាវជ្រាវសាលាភូមិ និងជំនួយការអ្នកស្រាវជ្រាវសាលាភូមិ ដែលបុគ្គលមួយចំនួនបានលាចាកពីលោកនេះ និងបុគ្គលមួយចំនួនទៀតបានផ្លាស់ប្តូរការងារ ឬផ្លាស់ទីលំនៅទៅនៅភូមិ ឬ ខេត្ត ឬ ប្រទេសដទៃទៀត។



សូមថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះលោក យេន រុន អ្នកសម្របសម្រួលថ្នាក់ខេត្តរបស់អង្គការសេប៉ា ដែលបានជួយសម្រួលការងារទំនាក់ទំនងក្នុងមូលដ្ឋាន និងជុំវិញខេត្ត ផ្តល់មធ្យោបាយធ្វើដំណើរ និងសម្ភារៈប្រើប្រាស់ដូចជាទោចក្រយានយន្ត កុំព្យូទ័រ និងអិលស៊ីឌី ។ល។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីសាលាខេត្តស្ទឹងត្រែង ថ្នាក់ដឹកនាំមន្ទីរបរិស្ថាន មន្ទីរកសិកម្ម ខណ្ឌរដ្ឋបាលជលផល នាយកតំបន់រ៉ាមសារ អភិបាលស្រុកស្ទឹងត្រែង អភិបាលស្រុកថាឡាបរិវ៉ាត់ មេបញ្ជាការសឹករងខេត្ត ដែលបានចូលរួមផ្តល់យោបល់កែសម្រួលព័ត៌មានទិន្នន័យ រចនាបថ ពាក្យពេចន៍ ដើម្បីបញ្ជាក់ពីសុពលភាពនៃឯកសារ។

សូមថ្លែងអំណរគុណជាពិសេសផងដែរ ចំពោះ អាជ្ញាធរមូលដ្ឋាន មេឃុំសាមគ្គី ប្រធានភូមិកោះខនឌិន មេឃុំកោះស្នែង ប្រធានភូមិកោះស្នែង មេឃុំអូរស្វាយ ប្រធានភូមិរ៉ុនសៀន មេឃុំព្រះរំកិល ប្រធានភូមិកោះល្វ ក្រុមប្រឹក្សាឃុំ និងប្រជាជននៃភូមិទាំងបួនខាងលើនេះដែលបានសហការ និងបង្កលក្ខណៈងាយស្រួលដល់ការចុះយកព័ត៌មាន ហើយបានចំណាយកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលា ចូលរួមយ៉ាងសកម្មគ្រប់សកម្មភាពរបស់អ្នកស្រាវជ្រាវនៅតាមមូលដ្ឋាន និងថ្នាក់ខេត្ត ។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលត្រីពិភពលោក តាមរយៈកម្មវិធីសម្ពន្ធភាពតំបន់ដីសើម ដែលបានជួយសំរួលការងារបោះពុម្ពផ្សាយ។

# សង្ខេបព័ត៌មានរួម

គម្រោងស្រាវជ្រាវ **សាលាភូមិ** នៅតំបន់វ៉ាមសារ ខេត្តស្ទឹងត្រែង បានទទួលការគាំទ្រ និងសហប្រតិបត្តិការរវាងអង្គការក្នុងស្រុកមួយដែលមានឈ្មោះថា សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ក្រោមការឧបត្ថម្ភពីសម្ព័ន្ធភាពតំបន់ដីសើម **(WA)** ។ ការសិក្សានេះ ត្រូវបានធ្វើឡើងដោយប្រជាជននៅតាមភូមិចំនួន៧ ដូចជាភូមិកោះខនឌិន ភូមិកោះស្នែង ភូមិរ៉ីនសៀន ភូមិកោះលូ ភូមិស្រែតាប៉ាន ភូមិក្លុក និងភូមិដំរីផុង ភូមិទាំង៧នេះគឺស្ថិតនៅក្នុងអាងទន្លេមេគង្គ តំបន់វ៉ាមសារខេត្តស្ទឹងត្រែង ។

អ្នកស្រាវជ្រាវគម្រោង **សាលាភូមិ** គឺជាអ្នកភូមិ ។ ពួកគាត់គឺជាអ្នកកំណត់ប្រធានបទចំនួន៨គឺ:

- ធនធានជលផល (រួមមានប្រភេទត្រី ឧបករណ៍នេសាទបែបបុរាណ កន្លែងរស់នៅរបស់ត្រី ទីកន្លែងពងកូន និងការបំលាស់ទីរបស់ត្រី )
- ប្រភេទរុក្ខជាតិប្រើប្រាស់ជាបន្លែ និងឱសថបុរាណ
- ប្រភេទជម្រកត្រីសំខាន់ៗ
- ប្រភេទឧបករណ៍នេសាទនៅតាមភូមិគោលដៅ
- អន្លង់សំខាន់ៗនៅតាមភូមិគោលដៅ
- សុខភាព និងជម្ងឺដែលតែងតែកើតមាននៅក្នុងភូមិ
- ចំណីអាហារដែលប្រើប្រាស់នៅក្នុងភូមិ
- ការប្រែប្រួលអាកាសធាតុ និងការបន្សាំខ្លួន

គម្រោងស្រាវជ្រាវ **សាលាភូមិ** មានគោលបំណងសំខាន់ៗចំនួន៦ដូចខាងក្រោម:

- ដើម្បីលើកម្ពស់សិទ្ធិអំណាចដល់ប្រជាជនមូលដ្ឋាន និងបង្កើនចំណេះដឹងដល់ពួកគេពីធនធានធម្មជាតិដែលមានតាមភូមិរបស់ពួកគេ តាមរយៈការសិក្សាស្រាវជ្រាវដោយខ្លួនឯង
- ដើម្បីបរិយាយ និងត្រួតពិនិត្យមើលការប្រែប្រួលធនធានធម្មជាតិ
- បណ្តុះបណ្តាលក្រុមអ្នកស្រាវជ្រាវ អោយចេះពីរបៀបធ្វើការជាបណ្តាញដើម្បីផ្លាស់ប្តូរចំណេះដឹងរវាងគ្នា និងគ្នាក្នុងរង្វង់ភូមិរបស់ខ្លួន ។



- ដើម្បីប្រមូលនិងចងក្រងឯកសារ ពីចំណេះដឹងតាមមូលដ្ឋាន ដែលទាក់ ទងនិងធនធានធម្មជាតិនៅក្នុងភូមិរបស់ពួកគេ។
- ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅរបស់អ្នកភូមិ តាមរយៈការផ្តល់អោយដូចជា ពូជដំណាំ ពូជត្រី និងបង្កើតជាក្រុមសន្សំ។
- ដើម្បីអោយពួកគាត់ចេះគ្រប់គ្រងនិងដកហូតធនធានប្រកបដោយនិរន្តរភាព

គម្រោងស្រាវជ្រាវ **សាលាភូមិ** ចាប់ផ្តើមអនុវត្តនៅខែឧសភា ឆ្នាំ២០០៥ ការសិក្សានេះ មានការចូលរួមធ្វើពីអ្នកស្រាវជ្រាវដែលជាប្រជាជនមូលដ្ឋានចំនួន ១៦៣នាក់ក្នុងនោះមានស្រីចំនួន ៦៥នាក់ ដែលរស់នៅក្នុងខេត្តស្ទឹងត្រែង ភាគល្អសាននៃប្រទេសកម្ពុជា រួមមានចាស់ទុំក្នុងភូមិ និងប្រជានេសាទផ្សេងៗទៀត ។

វិធីសាស្ត្ររបស់គម្រោងស្រាវជ្រាវ **សាលាភូមិ** ត្រូវបានបែងចែកជាជំហានៗ គឺដំបូងឡើងបង្កើតក្រុមស្រាវជ្រាវ ចុះសិក្សានៅតំបន់មូលដ្ឋានផ្ទាល់ និងធ្វើការស្ទង់មតិ ការសម្ភាសន៍គ្រួសារ កិច្ចប្រជុំបណ្តាញដើម្បីចែករំលែក និងធ្វើអោយមានសុពលភាពនូវលទ្ធផលស្រាវជ្រាវ និងដើម្បីរៀបចំរបាយការណ៍ពង្រៀង និងចុងក្រោយរៀបចំសិក្ខាសាលា ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋានដើម្បីសុំយោបល់មុននិងចេញរបាយការណ៍ចុងក្រោយ ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវការនូវទិន្នន័យបែបពិសោធន៍ និងការតាមដានត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន ។ តាមរយៈដំណើរការសិក្សានេះ ក្រុមអ្នកស្រាវជ្រាវមិនត្រឹមតែបានផ្តល់ជាព័ត៌មានតែប៉ុណ្ណោះទេ ថែមទាំងអាចពង្រឹងចំណេះដឹង និងជំនាញក្នុងការបង្ហាញលទ្ធផលស្រាវជ្រាវរបស់ពួកគេផងដែរ ។ អ្នកដែលបានចូលរួមនៅក្នុងគម្រោងស្រាវជ្រាវ **សាលាភូមិ** មានឱកាសបង្ហាញអ្នកខាងក្រៅពីជីវភាពរស់នៅរបស់ខ្លួន និងពីឧបសគ្គផ្សេងៗដែលកើតមានពីធនធានធម្មជាតិដែលពួកគេពឹងអាស្រ័យ ។ ការស្រាវជ្រាវបានផ្តល់ជាវេទិកាសម្រាប់អ្នកភូមិ ក្នុងការបង្ហាញ និងចរចារទាមទាចំពោះកង្វល់របស់ពួកគេ ។

អ្នកស្រាវជ្រាវគម្រោង **សាលាភូមិ** បានប្រមូលព័ត៌មានជាច្រើនប្រភេទផ្សេងៗគ្នា ។ ក្រុមអ្នកស្រាវជ្រាវទាំងនោះ បានចងក្រងជាឯកសារនូវឈ្មោះតាម

តំបន់ និងលក្ខណៈសំគាល់របស់ត្រី ជម្រកត្រី ប្រភេទរុក្ខជាតិ អន្លង់ និងឧបករណ៍នេសាទ ជម្ងឺ ចំណីអាហារ និងការប្រែប្រួលអាកាសធាតុ ។ មានគំរូជាច្រើនត្រូវបានប្រមូល និងថតទុកជាឯកសារដោយក្រុមអ្នកស្រាវជ្រាវគម្រោង **សាលាភូមិ** ។ ក្រៅពីថតរូបដើម្បីជួយគាំទ្រដល់ប្រធានបទស្រាវជ្រាវហើយ ក្រុមអ្នកស្រាវជ្រាវបានរៀបចំជាក្រុមពិភាក្សា ចាត់ថ្នាក់ និងវាស់ស្ទង់ ព័ត៌មានដែលប្រមូលបាន ។

ជាលទ្ធផលអ្នកស្រាវជ្រាវសាលាភូមិទាំងបួនភូមិ បានសិក្សាស្រាវជ្រាវទៅលើឧបករណ៍នេសាទបាន ចំនួន៣០ប្រភេទ និងបែងចែកជា ១៦ក្រុមធំៗ ដោយផ្អែកទៅលើរបៀបប្រើប្រាស់របស់ឧបករណ៍និមួយៗ។ សព្វថ្ងៃនេះប្រជាពលរដ្ឋនៅក្នុងភូមិកំពុងតែប្រើប្រាស់ឧបករណ៍ទាំងអស់នេះ ហើយនៅក្នុងនោះផលដែរក៏មានឧបករណ៍មួយចំនួនតូចដែលប្រជាជននៅក្នុងភូមិស្ទើរតែឈប់ប្រើទៅហើយ ដោយសារតែវាចំណាយពេលយូរក្នុងការនេសាទ ហើយទទួលបានផលតិច ហេតុនេះហើយពួកគាត់ក៏ឈប់ធ្វើ ឈប់ប្រើប្រាស់ ។ ដោយសារតែបែបនេះហើយទើបអ្នកស្រាវជ្រាវគម្រោងសាលាភូមិ បានសិក្សាស្រាវជ្រាវអំពីឧបករណ៍ នេសាទនេះ ដោយបានថតរូប ប្រាប់ពីរបៀបធ្វើ, របៀបប្រើប្រាស់, រដូវកាលប្រើប្រាស់, ទីកន្លែងនេសាទ, ប្រភេទត្រីដែលរកបាន និងការវិវត្តន៏របស់ឧបករណ៍នេះ ដើម្បីអោយកូនចៅជំនាន់ក្រោយបានយល់ដឹងពីឧបករណ៍បុរាណទាំងអស់នេះតាមរយៈសៀវភៅមួយក្បាលនេះ។

គម្រោងសាលាភូមិនឹងសង្ឃឹមទុកថា តាមរយៈការចែករំលែកលទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍ ប្រជាជនកម្ពុជាផ្សេងៗទៀត នឹងចូលរួមគាំទ្រនូវលទ្ធផលរបស់គម្រោង **សាលាភូមិ** ។ តាមរយៈការបង្ហាញពីលទ្ធផលរបស់គម្រោងសាលាភូមិ ទៅកាន់អ្នកអានកាន់តែច្រើន គេក៏សង្ឃឹមផងដែរថា ប្រតិកម្មតមនិងជំបូន្មានដែលទទួលបានត្រឡប់មកវិញ នឹងចូលរួមចំណែកបន្តដំណើរការស្រាវជ្រាវអោយទៅមុខទៀត ។



## Executive Summary

The **Sala Phum** research project in the Ramsar Site of Stung Treng is supported and developed by the local organization known as the Culture and Environment Preservation Association (CEPA). We are working in collaboration and have received our donation from the Wetland Alliance Program (WAP). This study is established by the people of four villages: Koh Khonden, Koh Snaeng, Veon Sien and Koh Larngor village. These four villages are in the four Communes and two Districts which are located along the Mekong River in the Ramsar Site of Stung Treng province.

The **Sala Phum** project researchers are villagers. The topics that were covered in the research are in eight categories:

- Fishery Resources (Fish species, Traditional fishing equipment, Fish habitats including fish reproductive areas and fish path-ways).
- Plant species which are used as vegetable and herbal medi-cines
- The main fishing areas.
- Fishing equipment and gear in the target village.
- The main deep pools that are in the target village.
- Health issues and sickness occurrences in the village.
- Other sources of nutrients that is eaten in the village.
- Climate change and adaptation.

The **Sala Phum** research project has six essential objectives listed below:

- Strengthen the human rights of local people and improve their knowledge of natural resources that are in their village by hav-ing them perform research studies.
- To describe and monitor the natural resource changes.
- Training the researcher team to be able to work as a network to exchange knowledge with each other and around their village.
- To collect and transcribe the research with local knowledge that links to the natural resources in their village.

- To enhance livelihoods in the village through providing seeds, fish and creating savings groups.
- To train them to manage and extract resources in a sustainable methodology

The **Sala Phum** research project team began to implement studies in May 2005. This report has been assembled with the support and contribution of researchers from local villages. In total there were 163 people, including 65 women that directly participated in as CEPA researchers for gathering information. These villagers also included local elders and other fishermen that are specifically from Stung Treng province in the northeast quadrant of Cambodia.
CEPA has developed and supported a Project Assistant Team that included five assistants to facilitate and transcribe documents which are linked to this research.

The **Sala Phum** research project strategy is divided into steps. Firstly was to create the researcher team for collecting data to study from the local environment, then conduct an assessment, interview families, prepare a network meeting to share and validate the results of the research. Next was to organize the draft report and then coordinate a workshop which had the participation of key stakeholders in order to get additional comments before the report was complete. We took this opportunity to review and evaluate our outputs and ascertain any further issues that may have arisen.

This research study required a detailed and lengthy time-frame for the collection of data, in addition to monitoring and verifying facts. Throughout this research study, the researcher teams were not only providing the CEPA staff with information, but they were also strengthening their knowledge and skills by demonstrating and informing the CEPA staff of results. The research had then been compiled by **Sala Phum,** where we articulated the structure of the final report. The research had given the opportunity to show the outside world the villager livelihoods, and what obstacles can occur from being dependant on the natural resources. The research study also provided the forum for villagers to discuss potential concerns and demands in presentations and negotiations.



The **Sala Phum** project's researchers collected a large quantity of important information pertaining to natural resources within their hinterland. The researchers transcribed this information into a report. The document consisted of a framework that included: identifying and naming the area of study, fish characteristics, fish habitats, plant species, deep pool location and size, fishing equipment and gear. In the collection of data, many patterns emerged which were recorded as a part of the final document by the **Sala Phum** project researchers. Aside from taking pictures to support the research topics, the research teams also organized the discussion group, classified and assessed the collected information.

The final component of this **Sala Phum** project involved the submission of a research on fishing equipment and gear by the trained researchers from four villages. The results lead to the determination that there are 30 types of nets, which were then categorized into 16 main varieties. Nowadays, the people in the village are not utilizing all of the varieties of equipment to catch fish, as some have become less effective do to the change in fish patterns and overall reduction of fish populations. The **Sala Phum** project researcher studied and researched the fishing equipment by taking pictures, explaining the process of how to make it, including material, where they would generally
go for fishing and what species of fish they would usually catch. By recording this significant information, CEPA will maintain a database of traditional knowledge of fishing livelihoods for future generations to understand and learn past best practices.

Through the sharing of our findings and results that we have presented in the final report of the **Sala Phum** project, we are expectant that other Cambodians will contribute and support the preservation and sustainability of our significant fishing villages along the Mekong River. In the presentation of these outcomes of the **Sala Phum** project, CEPA hopes to receive further feedback and recommendations for contributing to the betterment and continuation of our research in the future a head.

# សេចក្ដីផ្ដើម

សៀវភៅឧបករណ៍នេសាទមួយក្បាលនេះ គឺជាស្នាដៃថ្មីមួយទៀតរបស់អ្នកស្រាវជ្រាវសាលាភូមិ ទាំង៧ភូមិ គឺភូមិកោះខនឌិន ភូមិកោះស្នែង ភូមិរ៉ឺនសៀន ភូមិកោះលូ ភូមិស្រែតាប៉ាន ភូមិភ្លុក និងភូមិដំរីផុង ក្នុងខេត្តស្ទឹងត្រែង ដែលបានចំណាយពេលវេលា កំលាំងកាយ ចិត្ត ធ្វើការសិក្សាស្រាវជ្រាវទៅលើឧបករណ៍នេសាទដែល មាន ប្រើប្រាស់នៅក្នុងភូមិ ។

ជាលទ្ធផលអ្នកស្រាវជ្រាវសាលាភូមិទាំងបួនភូមិ បានសិក្សាស្រាវជ្រាវទៅលើឧបករណ៍នេសាទបាន ចំនួន៣០ប្រភេទ និងបែងចែកជា ៧ក្រុមធំៗ ដោយផ្អែកទៅលើរបៀបប្រើប្រាស់របស់ឧបករណ៍និមួយៗ។ សព្វថ្ងៃនេះវត្តមានរបស់ឧបករណ៍បែបប្រពៃណី គឺនៅតែជាទីពេញនិយមប្រើប្រាស់ពីសំណាក់ប្រជាពលរដ្ឋនៅក្នុងភូមិ ។

នៅក្នុងការសិក្សាស្រាវជ្រាវឧបករណ៍នេសាទ អ្នកស្រាវជ្រាវបានកំណត់ចំណុចសំខាន់ៗចំនួន៩ ដូចខាងក្រោមសម្រាប់ការពិភាក្សា៖

- លក្ខណៈរូប
- វិធីធ្វើ
- របៀបប្រើប្រាស់
- រដូវកាលប្រើប្រាស់
- ទីកន្លែងនេសាទ
- ប្រភេទត្រីដែលរកបាន
- អ្នកប្រើប្រាស់
- ការវិវត្តន៍

ក្នុងចំណោមប្រជាជនកម្ពុជាប្រមាណ១២លាននាក់ មាន ៨៥% រស់នៅតាមជនបទប្រកបរបរធ្វើស្រែចំការ និងនេសាទជាលក្ខណៈគ្រួសារ ដែលទាំងអស់នេះហើយជាលក្ខណៈពិសេស ស្ដែងអោយឃើញថា កម្ពុជាមានអំណោយផល សំបូរទៅដោយធនធានជលផលគ្រប់ប្រភេទ ។ ប្រជាជនអាចចាប់ត្រីបានគ្រប់ប្រភេទ និងគ្រប់ទីកន្លែងទៅតាមរដូវកាល ជាមួយគ្នានេះការនេសាទដែលទទួល



បានទិន្នផលច្រើនបំផុតនោះ គឺកើតមាននៅរដូវទឹកជំនន់ ពេលដែលត្រីប្រមូលផ្ដុំគ្នាចុះតាមទឹកមករកទន្លេវិញ តាមលក្ខ័ខ័ណ្ឌខុសៗគ្នា អ្នកនេសាទបានប្រើប្រាស់វិធីសាស្ត្រជាច្រើនរបៀបសម្រាប់ចាប់ត្រី ដូចជារបៀបងាយៗបំផុត (ចាប់ត្រីដោយដៃ) ឬតាមរយៈការនេសាទប្រចាំថ្ងៃដែលមានដូចជា: មង សំណាញ់ លប ទ្រូ...។ រីឯការនេសាទដែលមានលក្ខណៈសាំញ៉ាំបំផុតវិញនោះ គឺការនេសាទជាលក្ខណៈឧស្សាហកម្មរបៀបជាឡូតិនេសាទ ។

យ៉ាងណាមិញ ប្រជាពលរដ្ឋរស់នៅក្នុងខេត្តស្ទឹងត្រែង ភាគច្រើនគឺគាត់នេសាទជាលក្ខណៈគ្រួសារដោយប្រើប្រាស់ឧបករណ៍នេសាទបែបបុរាណបន្តពីចាស់ជំនាន់មុន មានដូចជា: មង សំណាញ់ ទ្រូ និងលបជាដើម...។

ការទទួលបាននូវរាល់មតិត្រឡប់ពីសំណាក់មិត្តអ្នកអាន អ្នកជំនាញឯកទេសខាងជលផល ឬ អ្នកសិក្សាស្រាវជ្រាវ...ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីចូលរួមចំណែកពង្រឹងការស្រាវជ្រាវដោយមានការចូលរួម។

ជាទីបញ្ចប់ ក្រុមស្រាវជ្រាវសាលាភូមិ សូមឧទ្ទិសស្នាដៃនេះចំពោះព្រលឹងបុព្វបុរសដូនតាខ្មែរ ដែលបានបន្សល់ទុកនូវចំណេះដឹង ប្រពៃណីទំនៀមទំលាប់ក្នុងការប្រើប្រាស់ឧបករណ៍នេសាទដ៏មានតម្លៃមិនអាចកាត់ថ្លៃបាននេះ។

# សាវតាភូមិ

## ១-សាវតាភូមិកោះខនឌិន

គឺមានដើមកំណើតពីជនជាតិឡាវមួយគ្រួសារឈ្មោះ**តាឌិន** ដែលបានមក រស់នៅ និងបង្ករបង្កើនផលនៅលើដីកោះនេះ។ គាត់គឺជាមនុស្សម្នាក់មានមហិទ្ធិរិទ្ធិខ្លាំងក្លាណាស់ កាប់មិនមុតដុតមិនឆេះ។ ឆ្នាំដំបូង នៃការបង្កបង្កើនផលរបស់គាត់គឺគាត់ដាំស្រូវ ១ ប៉ោតអាចរក្សាទុកហូបបានពេញមួយឆ្នាំព្រោះជាប្រភេទដីជីជាតិ។ នៅឆ្នាំបន្ទាប់គាត់បានដើរទៅតាមភូមិដទៃ ហើយបានអួតប្រាប់ពីធនធានដ៏សំបូរហូរហៀរនៅលើដីកោះរបស់គាត់ ដើម្បីប្រមូលប្រជាជនឱ្យមករស់នៅលើកោះនេះជាមួយគ្រួសាររបស់គាត់ដែរ។ មួយរយៈកាល ក្រោយមក ទើបមានប្រជាជនចំនួន៥គ្រួសារបានមករស់នៅ និងបង្ករបង្កើនផលជាមួយគ្រួសារតាឌិនដែរ។ រហូតដល់ឆ្នាំទីបីកំណើនគ្រួសារបានកើនដល់ ១៥គ្រួសារដែលសុទ្ធសឹងជាជនជាតិឡាវ។

សម័យថ្ងៃមួយមានចោរហារយមួយក្រុម មិនដឹងប្រភពពិតប្រាកដបានចូលមកប្លន់ប្រជាជននៅលើកោះនេះប្រដាប់ដោយដាវ កាំបិត លំពែង ហើយមាន កាំភ្លើងកាំបិនមួយដើម (កាំភ្លើងកាំបិននេះធ្វើឡើងពី ស្រកីដូង និងរំសេវ)។ តាឌិន បានចេញមុខដឹកនាំបុរសពេញកំលាំងក្នុងភូមិ តស៊ូប្រយុទ្ធជាមួយក្រុមចោរ ហើយឱ្យចាស់ៗ ស្ត្រី និងកុមាររត់ទៅលាក់ខ្លួនតាមគុម្ពោតព្រៃ។ ទីបំផុតតាឌិនត្រូវបានស្លាប់នៅក្រោមកាំភ្លើង កាំបិន។ ដោយវីរភាពរបស់លោកតាឌិន អ្នកភូមិ បានដាក់ឈ្មោះ កោះនេះថា **កោះតាឌិន** ចាប់ពីពេលនោះមក។

ឆ្នាំ ១៩៣៨ រហូតមកដល់ពេលបច្ចុប្បន្ន កោះតាឌិន បានផ្លាស់ប្តូរមកជា **ភូមិកោះខនឌិន** (មានន័យ ជាភាសាខ្មែរថា ភូមិពន្លដី)។



នៅឆ្នាំ១៩៥៩ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់ព្រះអតីតព្រះមហាវីរក្សត្រព្រះបិតាឯករាជ្យជាតិ **ព្រះបាទនរោត្តមសីហនុ** បានជំរុញឱ្យកូនចៅនៅតាមខេត្តកំពង់ចាម ព្រៃវែង តាកែវ កំពត មករស់នៅតាម ភូមិភាគឦសានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ពីព្រោះដីនៅតាមខេត្តខាងក្រោមតូចចង្អៀតក្នុងការធ្វើកសិកម្ម និងរស់នៅ ដូច្នេះហើយទើបចំនួនប្រជាជននៅភូមិកោះខនឌិនកើនបានចំនួន ៤៣គ្រួសារ ក្នុងនោះ ជ្រាជនជាតិឡាវ ៣៥គ្រួសារ និងជាជនជាតិខ្មែរ ៨គ្រួសារ។ ចំណែកការធ្វើស្រែចំការរបស់គាត់ គឺធ្វើជាលក្ខណៈវិលជុំដោយគាត់មានជំនឿលើការដុតធូបបន់ស្រន់អារក្សអ្នកតា ដើម្បីកុំឱ្យសត្វចង្រៃមកបំផ្លាញដំណាំរបស់គាត់។ ចំណែកទិន្នផលដែលទទួលបានពីការដាំដុះ ការរកត្រី និងអនុផលព្រៃឈើ គឺគាត់តែងតែចែកគ្នាហូបទៅវិញទៅមក មិនដែលចេះលក់ដូរអ្វីទេ។ ប៉ុន្តែរយៈកាលប៉ុន្មានឆ្នាំក្រោយមក ដីច្រាំងបានបាក់ជាបន្តបន្ទាប់ដោយទាំងផ្ទះអ្នកភូមិ ជនជាតិឡាវដែលសង់នៅតាមមាត់ទន្លេ ទើបធ្វើឱ្យពួកគាត់ ប្តូរទីតាំងទៅរស់នៅខាងដីគោកឆ្ងាយពីកន្លែងបាក់ច្រាំង ដែលបច្ចុប្បន្នប្រមូលផ្តុំទៅជាភូមិថ្មីមួយផ្សេងទៀត គឺ **"ភូមិខាំផាន់"** ឯអ្នកភូមិជាជនជាតិខ្មែរបានផ្លាស់ទីមករស់នៅ ដីគោកឆ្ងាយពីច្រាំងទន្លេ ហើយនៅតែរក្សាឈ្មោះភូមិរបស់ខ្លួនដដែលគឺ ភូមិកោះខនឌិន រហូតមកទល់សព្វថ្ងៃនេះ។

អស់រយៈកាលជាង១០ឆ្នាំ ដែលប្រជាជនបានរស់នៅយ៉ាងសុខដុមរមនា ដោយប្រកបរបរកសិកម្មរួម ជាមួយនឹង ការរុករកអនុផលព្រៃឈើ និងប្រមាញ់សត្វព្រៃដូចជា ជ្រូកព្រៃ ខ្លា ដំរី ទន្សោង ខ្ទីង កាំប្រមា។ល។

ក្នុងកំឡុងឆ្នាំ១៩៧០-១៩៧៥ រដ្ឋប្រហារសម័យលន់នល់ ប្រទេសកម្ពុជាបានជួបសង្គ្រាមផ្ទៃក្នុង។

អ្នកភូមិ កោះខនឌិនបានរត់ពីស្រុកទៅនៅក្នុងព្រៃ ដើម្បីគេចពីគ្រាប់ប្លោង មិនបានធ្វើស្រែចំការ ដូចនេះគ្រោះទុរ្ភិក្ស ជំងឺដង្កាត់បាន កើតឡើងឥតឈប់ឈរ។

ឆ្នាំ១៩៧៥-១៩៧៩ ប្រជាជនភូមិកោះខនឌិនរួមទាំងប្រជាពលរដ្ឋទូទាំងប្រទេសបានរងទុក្ខវេទនា ម្តងទៀត ក្នុង សង្គមខ្មៅងងឹត ប៉ុល ពត, អៀង សារី, និង ខៀវ សំផន ដោយសារធ្វើការងារធ្ងន់ ប៉ុន្តែមិនអាចហូប អាហារឱ្យគ្រប់គ្រាន់។ អ្នកភូមិរស់នៅបែកខ្ញែកគ្នា កូនបែកពីឪពុកពីម្តាយ ប្រពន្ធបែកពីប្តី ប្រជាជនមួយចំនួនត្រូវ គេជំលាសទៅនៅញ៉ើន ខ្លះទៅ ខេត្តព្រះវិហារ។ ក្រោយសង្គ្រាមបានបញ្ចប់ឆ្នាំ ១៩៧៩ សន្តិសុខនៅតាមតំបន់នៅ តែមានភាពច្របូកច្របល់ ប្រជាជនមួយចំនួនបានវិលមកតាមផ្ទះវិញ ចំណែកឯហេដ្ឋារចនាសម្ពន្ធ័មួយចំនួនត្រូវ ខ្ទេចខ្ទីហើយ ទាហានជាច្រើននៅវាយប៉ាយគ្រប់ទិសទី។

នៅឆ្នាំ១៩៨០-១៩៨៥ កំណើនប្រជាជនកើនឡើងជាបន្តបន្ទាប់ ដីព្រៃត្រូវរុករានសំរាប់ធ្វើស្រែចំការ ផុតគំនិតនៃអំពើហឹង្សា និងការស្រែកឃ្លានក្រោយពីសង្គ្រាមបានធ្វើឱ្យមនុស្សចាប់សត្វព្រៃ និងធនធានផ្សេងៗដោយ ប្រើឧបករណ៍ខុសច្បាប់។ ដើម្បីបំបាត់អនក្ខរភាព ស្ថាប័នរដ្ឋ និងប្រជាពលរដ្ឋក្នុងភូមិបានស្ថាបនាសាលារៀនមួយ ខ្នងនៅក្នុងភូមិកោះខនឌិន ដែលមានចំនួន ២ថ្នាក់ ដោយជ្រើសរើសគ្រូបង្រៀនដោយស្ម័គ្រចិត្តពីក្នុងភូមិ និងកសាង បានសាលាឆទានមួយខ្នងដែរ។

ឆ្នាំ១៩៨៥-១៩៨៩ គ្រួសារនៅក្នុងភូមិកោះខនឌិន កើនឡើងបានចំនួន ៥០គ្រួសារ ហើយរស់នៅដោយ ពឹងផ្អែកយ៉ាងសំខាន់ទៅលើការ ធ្វើកសិកម្មសំរាប់ទុកហូប និងលក់ជូនរដ្ឋ ប៉ុន្តែគាត់នៅតែមានការភ័យភិតដោយ សាររដ្ឋបានចេញ ច្បាប់ឱ្យយុវជនគ្រប់អាយុចូលធ្វើទាហាន។ ចំពោះធនធានធម្មជាតិនៅក្នុងភូមិ ដូចជា ឈើ



គ្រប់ប្រភេទ ត្រូវបានគេកាប់ដោយ អនាធិបតេយ្យពីសំណាក់អ្នកមានអំណាច និង ទាហាន ទៅកាន់ប្រទេសជិតខាង។

ឆ្នាំ១៩៩០-១៩៩៩ អតីតព្រះមហាវីរក្សត្រព្រះបិតាឯករាជ្យជាតិព្រះបាទនរោត្តមសីហនុវរ្ម័ន បានយាង និវត្តចូលមកស្រុកខ្មែរវិញ។ សម័យប្រជាធិបតេយ្យសេរីពហុបក្សបានបង្កើតឡើង ដោយសារមានការបោះឆ្នោត ជាលើកទី១ ដើម្បីជ្រើសរើសនាយករដ្ឋមន្ត្រី ការបង្កើតក្រុមប្រឹក្សាឃុំសង្កាត់។ ចំពោះសាសនា ប្រជាជនក្នុងភូមិ ប្រតិបត្តិតាមសាសនាព្រះពុទ្ធ ប៉ុន្តែដោយនៅក្នុងភូមិមិនទាន់មាន វត្តអារាមនៅឡើយ ដូចនេះនៅពេលមានបុណ្យ ទានក្នុងភូមិម្តងៗ គាត់ត្រូវនិមន្តព្រះសង្ឃមកពីខេត្តស្ទឹងត្រែង។

នៅឆ្នាំ១៩៩១ ពុទ្ធបរិសទ័ចំនុះជើងវត្តបាន មូលមតិគ្នាកសាងវត្តមួយដែលមានឈ្មោះថា **សាសនរង្សី**។

ឆ្នាំ១៩៩៤-១៩៩៥ មានគ្រោះរាំងស្ងួត និងគ្រោះទឹក ជំនន់បានកើតឡើងផ្ទួនៗគ្នាដែលធ្វើឱ្យប្រជាជនខ្វះស្បៀងអាហារ ជំងឺដង្កាត់ ខ្វះថ្នាំពេទ្យ។ ដោយមើលឃើញភាព លំបាកបែបនេះទើបរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បានចូលជាវិភាគទានផ្តល់អំណោយ ដល់គាត់។ នៅឆ្នាំ១៩៩៨ អង្គការ UNICEF បានជួយកសាង អាគារសិក្សាថ្មីមួយខ្នងដល់ភូមិ ពីព្រោះថ្នាក់ រៀនពីមុនមានសភាពចាស់ទ្រុឌទ្រោមណាស់ទៅហើយ ចំណែកអង្គការ PFD បានផ្តល់អណ្តូងស្នប់ចំនួន ៥។

ឆ្នាំ២០០០ អង្គការ PFD បានផ្តល់ពាងចំរោះទឹកស្អាតចំនួន ១៨។

ឆ្នាំ២០០១ គណៈកម្មការអភិវឌ្ឍភូមិ បានបង្កើតឡើងដោយការសំរបសំរួលពីអង្គការ PFD ។ នៅឆ្នាំ ដដែលនេះ ធនាគារស្រូវ ត្រូវបានបង្កើតឡើងដែរ ក្រោយ

ពេលមើលឃើញអ្នកភូមិមួយចំនួនជំពាក់បុលចិន ច្រើនពេក ដើម្បីយកលុយមកទិញស្រូវហូប ដោយខ្ចីលុយមួយម៉ឺន សងវិញជាស្រូវមួយតៅ ឬខ្ចីមួយម៉ឺនរៀល សងវិញជាប្រាក់បីម៉ឺនរៀលក្រោយពេលប្រមូលផលស្រែចំការរួច។

ក្រៅពីនេះផ្លូវលំចាក់គ្រួសក្រហមមួយខ្សែបាន ស្ថាបនាឡើងដែរ។ ទន្ទឹមនឹងនេះការអភិវឌ្ឍនៅក្នុងភូមិ ធនធានធម្មជាតិដូចជា សត្វព្រៃ ព្រៃឈើ ត្រី ដែលប្រជាជនធ្លាប់ពឹងអាស្រ័យបានធ្លាក់ចុះយ៉ាងខ្លាំង។

ឆ្នាំ២០០២ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅកាត់ថា CEPA បានចុះសំរង់ព័ត៌មាន PNRA លើធនធាន ធម្មជាតិដោយមានការចូលរួមពីមន្ត្រី ការិយាល័យជលផលខេត្ត និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ដើម្បីលើកផែនការ អភិរក្សធនធានធម្មជាតិដោយមានការចូលរួម។ បន្ទាប់មកទៀតទើបមានការរៀបចំបង្កើត សហគមន៍នេសាទ ដែលសំរប សំរួលដោយអង្គការសេប៉ា។

ខែមេសា ឆ្នាំ២០០៦ គំរោងសាលាភូមិចាប់ផ្តើមដំណើរការដោយមានការចូលរួមពីសំណាក់ប្រជាជន នៅក្នុងភូមិ ក្រោមកិច្ចសហការរវាងអង្គការសេប៉ា CEPA និងកម្មវិធីអភិរក្សជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ MWBP គឺជាគំរោង ថ្មីមួយដែលចូលរួមដោយអ្នកស្រាវជ្រាវនៅពីក្នុងភូមិ។ គំរោងនោះចាប់ផ្តើមអនុវត្តនៅក្នុង ខែឧសភា ឆ្នាំ២០០៥ ដោយធ្វើ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទត្រី ជំរកត្រី និង



ជីវភាពរស់នៅ។

ឆ្នាំ២០០៦ កំនើនគ្រួសារនៅក្នុងភូមិមានចំនួន ១៣៨គ្រួសារ ស្មើនឹង ៧៤១នាក់ ក្នុងនោះមានស្រី ៤២០នាក់។ ចំពោះការធ្វើស្រែចំការ ចិញ្ចឹមសត្វ (ក្របី ជ្រូក មាន់ ទា) ការរកត្រី គឺនៅតែជាយុទ្ធសាស្ត្រចិញ្ចឹម ជីវិតរបស់ប្រជាជនក្នុងភូមិ។

ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដោយមានការឧបត្ថម្ភពីសម្ព័ន្ធភាពតំបន់ដីសើម **(WAP)** អ្នកស្រាវជ្រាវគម្រោងសាលាភូមិក៏បានបន្តការសិក្សាទៅលើ ប្រភេទត្រី រុក្ខជាតិ អន្លង់ ឧបករណ៍នេសាទ សុខភាព និងបម្រែបម្រួលអាកាសធាតុ ។

ឆ្នាំ២០០៨ អង្គការសេដាកបានចូលមកបង្កើតនៅក្នុងភូមិទាក់ទងទៅនិងកសិកម្ម ការសន្សំប្រាក់ និងចិញ្ចឹមមាន់ ។

អ្នកស្រាវជ្រាវបានចែករំលែកពីវិធីសាស្ត្រស្រាវជ្រាវនៅក្នុងខេត្តក្រចេះ ។

ឆ្នាំ២០០៩ គម្រោងសាលាភូមិបានបណ្តុះបណ្តាលអ្នកស្រាវជ្រាវពីរបៀបប្រើប្រាស់ កាម៉ារ៉ាវីដេអូ និងបានថតខ្សែវីដេអូទាក់ទងទៅនិងបម្រែបម្រួលអាកាសធាតុ ។

ឆ្នាំ២០១០ អ្នកស្រាវជ្រាវបានផលិតខ្សែវីដេអូទាក់ទងទៅនិងបម្រែបម្រួលអាកាសធាតុ និងបានចែកជា CD ដល់អ្នកភូមិ និងអ្នកពាក់ព័ន្ធ ។

ឆ្នាំ២០១១ គម្រោងសាលាភូមិបានបង្កើតក្រុមសន្សំប្រាក់ដែលមានឈ្មោះថា អង្គការអភិវឌ្ឍន៍សហគមមូលដ្ឋានភូមិកោះខនឌិន ។

## ២- សាវតាភូមិកោះស្នែង

កោះស្នែងជាភូមិមួយក្នុងចំណោមភូមិទាំងបួន (ភូមិកោះកី ភូមិកោះស្រឡៅ និងភូមិជាំធំ) នៃឃុំកោះស្នែង ស្រុក ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ ភូមិនេះស្ថិតនៅក្នុងអាងទន្លេមេគង្គ ខាងជើងពីទីរួម ខេត្តស្ទឹងត្រែងប្រមាណ ២១គ.ម ហើយមានព្រំប្រទល់ខាងជើងជាប់នឹងភូមិកោះកីខាងត្បូង និងខាងលិចជាប់ នឹងភូមិកោះស្រឡៅឯខាងកើតជាប់នឹងឃុំសាមគ្គី និងខាងលិចជាប់នឹងភូមិជាំធំ។

ភូមិកោះស្នែងមានអាយុកាលប្រហែល ២៧០ឆ្នាំកន្លងមកហើយដោយបានឆ្លងកាត់ព្រឹត្តិការណ៍សំខាន់ៗ ជាច្រើនដូចតទៅនេះៈ កាលពីដើមមានព្រានប្រមាញ់ម្នាក់បានមកបាញ់ជ្រូកព្រៃនៅលើកោះខ្លី។ គាត់បានបាញ់ ជ្រូកព្រៃ១ក្បាលឱ្យរបួស ប៉ុន្តែវាបានរត់គេចមកនៅលើកោះមួយ ឯអ្នកប្រមាញ់ក៏រត់ដេញតាមពីក្រោយដែរ ទើបធ្វើឱ្យគាត់ជ្រុះស្នែងក្របី សំរាប់ដាក់រំសេវកាំភ្លើងកឹបរបស់គាត់បាត់ ដូចនេះគេក៏ហៅកោះនេះថាកោះស្នែង រៀងរហូតមក។ រយៈកាលកន្លងមកមាន អ្នកភូមិហាងខូចំនួន ២នាក់ គឺ លោកតា **វង្សខាំសាវ** និង លោកតា **ណាមម៉ាហឿង** បានមកធ្វើស្រែចំការនៅលើ កោះស្នែង និងបានតាំងទីលំនៅ ចំណេរក្រោយមកទើបមានអ្នក ចំណូលថ្មីដែលមកពីភូមិផ្សេងៗមករស់នៅលើកោះនេះ រហូតកើតបានជាភូមិធំដូចជាសព្វថ្ងៃ។

ឆ្នាំ១៩៣០ ក្រោមនឹមអាណានិគមបារាំង អ្នកភូមិកោះស្នែងបានត្រូវគេកែនយកទៅធ្វើផ្លូវជាតិលេខ១៣ ពីស្ទឹង ត្រែងទៅព្រំដែនឡាវ ដោយឱ្យធ្វើការជាទំងន់។ ម្យ៉ាងវិញទៀត ជំងឺអាសន្នរោគក៏បានកើតឡើង ដែលធ្វើឱ្យអ្នកភូមិស្លាប់ អស់ជាច្រើននាក់។



ឆ្នាំ១៩៤០ ប្រជាពលរដ្ឋក្នុងភូមិកើនបានចំនួន ៣០គ្រួសារ។ ប៉ុន្តែសម័យកាលនេះគឺសៀមបានចូលមក កាន់កាប់វិញ ម្តង ប្រជាជនមានជីវភាពក្រខ្សត់លំបាកវេទនាកើតដំបៅកមរមាស់ជាច្រើននាក់ ខ្វះសំលៀកបំពាក់។ ដូចនេះទើបគាត់នាំគ្នាដាំកប្បាសយកមកត្បាញរវៃធ្វើសំលៀកបំពាក់ដោយខ្លួនឯង។

ឆ្នាំ១៩៤៧ សៀមបានដកចេញទៅវិញ បារាំងបានចូលមកកាន់កាប់ម្តងទៀតមានការជំរិតយកពន្ធដារ គ្រប់ជំពូក និង បានកំណែនអ្នកភូមិទៅធ្វើទាហាន។

ឆ្នាំ១៩៥១ ប្រជាពលរដ្ឋបានកើនដល់ ៥១គ្រួសារ ប៉ុន្តែដោយសារ នៅក្នុងភូមិកើតជំងឺអុត និងអាសន្ន រោគដែលធ្វើ ឱ្យមនុស្សស្លាប់អស់ជាច្រើននាក់ ចំណែកឯសត្វក្របីក៏ស្លាប់អស់ជាច្រើនក្បាលដែរដោយសារ ជំងឺរាតត្បាត។

ឆ្នាំ១៩៥៤ ខ្មែរបានទទួលឯករាជ្យពីបារាំង ប្រជាជនចាប់ផ្តើមមានជីវភាពមធ្យម ការដើរហើររកស៊ីបាន ស្រួលជាង មុន។

ឆ្នាំ១៩៦០ មានសាលារៀនមួយខ្នងបានកសាងឡើងនៅក្នុងភូមិ។ អ្នកភូមិមានជីវភាពរស់នៅធូរធារជាង មុនដោយ សារការប្រកបរបរធ្វើស្រែចំការ។

ឆ្នាំ១៩៧០ **លន់ ណុល** ធ្វើរដ្ឋប្រហារទំលាក់សម្តេចសីហនុ ស្រុកទេសចាប់ផ្តើមកើតសង្គ្រាមកលល្បុក វឹកវរពេញប្រទេស មានយន្តហោះទំលាក់គ្រាប់ បែកគ្រប់ទីកន្លែង អ្នកភូមិមិនបានធ្វើស្រែចំការ ជីវភាពជួបការ លំបាក ខ្វះថ្នាំសង្កូវ សំលៀកបំពាក់ ស្រូវ អង្ករ អំបិល...។

ឆ្នាំ១៩៧៧ អ្នកភូមិកោះស្នែង ត្រូវបានគេជំលៀសចេញពីភូមិអោយទៅនៅស្រុកឆែប ខេត្តព្រះវិហារ ដោយឱ្យធ្វើ ការរួម ហូបបាយរួម គឺគ្មានអ្វីជាកម្មសិទ្ធិ បុគ្គលឡើយ ម្នាក់ត្រូវខិតខំធ្វើការជាទំងន់ទាំងយប់ទាំងថ្ងៃប៉ុន្តែមិនអាចហូបគ្រប់ក្រាន់ទេ ។

របបនេះធ្វើឱ្យខ្មែរចាំមិនភ្លេចដោយសារតែប្រជាពលរដ្ឋជាច្រើនបានត្រូវគេកាប់ សំលាប់ វត្តអារាមក្លាយទៅ ជាកន្លែងដាក់ម៉ាស៊ីនកិនស្រូវ ។

ឆ្នាំ១៩៧៩ កងទ័ពខ្មែរ និងកងទ័ពវៀតណាមបានចូលមករំដោះប្រជាជនឱ្យចេញពីរបប **ប៉ុល ពត** ហើយវិល ត្រឡប់ចូលភូមិវិញ និងធ្វើលំនៅដ្ឋានថ្មី ធ្វើស្រែចំការជាក្រុមប្រវាស់ដៃគ្នា ដែលធ្វើឱ្យគាត់មានជីវភាពមធ្យម ។

ឆ្នាំ១៩៨១ ជារយៈពេលមួយដែលគេបានជ្រើសរើសយុវជននៅក្នុងភូមិឱ្យធ្វើជាកងទ័ព និងមានរៀបចំការ បោះឆ្នោតជ្រើសរើសគណៈឃុំ ចំពោះការដើរហើរទៅណាមកណាម្នាក់ៗត្រូវសុំច្បាប់ភូមិ-ឃុំជាមុនសិន ។ នៅគ្រា នោះក៏មាន កងទ័ពវៀតណាមបោះទីតាំងនៅក្នុងភូមិ ។

ឆ្នាំ១៩៨២ ប្រជាជនបានសាងសង់អាគារសិក្សាមួយខ្នងដែលមាន៤ថ្នាក់ ។

ឆ្នាំ១៩៨៥ អ្នកភូមិបាននាំគ្នាទៅក៥ចំនួន ៤លើក ដោយ១លើកៗមានរយៈពេល៣ខែ ដើម្បីទៅកាប់ព្រៃ តាមព្រំដែនថៃ-ខ្មែរ ។

ឆ្នាំ១៩៨៨ ទាហានវៀតណាមបានដកចេញពីភូមិ ចំណែកឯប្រជាពលរដ្ឋបានចូលរួមកសាងវត្តដែលបាន បំផ្លិច បំផ្លាញក្រោយពីរបបខ្មែរក្រហមឡើងវិញ ។

ឆ្នាំ១៩៩៣ របបប្រជាធិបតេយ្យ អ៊ុនតាក់បានចូលរួមរៀបចំការបោះឆ្នោតដោយសេរី និងលើកដំបូង ក្រោយពី សង្គ្រាមផ្ទៃក្នុងបានបញ្ចប់ទៅ ។

ឆ្នាំ១៩៩៦-១៩៩៧ ប្រជាពលរដ្ឋជួបប្រទះនូវគ្រោះទឹកជំនន់ជួនៗគ្នា២ឆ្នាំដោយទាំងផលដំណាំរបស់អ្នក ភូមិដែល ធ្វើឱ្យជីវភាពរបស់គាត់ជួបការលំបាក ។ យ៉ាងណាមិញអង្គការ UNICEF បានជួយជួសជុលសាលារៀន ក្នុងភូមិចំនួន៣ បន្ទប់ ។



ឆ្នាំ១៩៩៨ បន្ទាប់ពីគ្រោះទឹកជំនន់ គ្រោះរាំងស្ងួតក៏បានចូលមកយាយីជីវភាពរស់នៅរបស់អ្នកភូមិ កោះស្នែងម្តង ។ នៅឆ្នាំដដែលនេះក៏មានការរៀបចំការបោះឆ្នោតថ្នាក់ជាតិសំរាប់រដ្ឋាភិបាលអណត្តិទី២ ។ ចំពោះ ការអភិវឌ្ឍនៅក្នុងភូមិ អង្គការភាពជាដៃគូដើម្បីអភិវឌ្ឍ (PFD) បានសាងសង់បង្គន់នៅក្នុងសាលារៀនចំនួន ៣បន្ទប់ និងបង្កើតគណៈកម្មការ អភិវឌ្ឍភូមិ ព្រមទាំងបានចុះមកសំរង់ព័ត៌មានការ វាយតំលៃជនបទដោយមាន ការចូលរួម (PRA)។ រយៈកាលក្រោយមក សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) បានចុះសំរង់ព័ត៌មាន (PNRA) លើធនធានធម្មជាតិដោយមានការចូល រួមពីមន្រ្តីការិយាល័យជលផលខេត្ត និងស្ថាប័នពាក់ព័ន្ធ ជាច្រើនទៀត ដើម្បីលើកផែនការអភិរក្សធនធានធម្មជាតិដោយមាន ការចូលរួម។ ដូចនេះទើបនៅឆ្នាំ ២000 សហគមន៍នេសាទបានត្រូវបង្កើតឡើងដោយមានការសំរបសំរួលពីអង្គការសេប៉ា ។

គំរោងសាលាភូមិរបស់អង្គការសេប៉ា (CEPA) សហការជាមួយកម្មវិធីអភិរក្សជីវៈចម្រុះតំបន់ដីសើម ទន្លេមេគង្គ (MWBP) គឺជាគំរោងថ្មីមួយដែល ចូលរួមដោយអ្នកស្រាវជ្រាវនៅក្នុងភូមិ ។ គំរោងនោះចាប់ផ្តើម អនុវត្តនៅក្នុងខែ ឧសភា ឆ្នាំ២00៥ ដោយធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទត្រី, ជំរកត្រី, ប្រភេទរុក្ខជាតិ ដែលប្រើប្រាស់ជាឱសថ បុរាណ និងបន្លែ , និងជីវភាពរស់នៅពឹងផ្អែកលើធនធានធម្មជាតិ ។

តាមទិន្នន័យភូមិឆ្នាំ២00៥ ភូមិកោះស្នែងមានប្រជាជនសរុបចំនួន ១,0១៣ នាក់ ក្នុងនោះមានស្រីចំនួន ៥២៣នាក់ និងប្រុសចំនួន៤៩0នាក់ ស្មើនឹង១៨៦គ្រួសារ គឺជាភូមិដែលមានចំនួនគ្រួសារច្រើនជាងគេបើប្រៀប ធៀបជាមួយភូមិផ្សេងៗទៀតក្នុងឃុំកោះស្នែង ។

ប្រជាជនភូមិកោះស្នែងប្រកបមុខរបរជាច្រើនសំរាប់ការចិញ្ចឹមជីវិត ដូចជា ធ្វើស្រែចំការ ដាំដំណាំ នេសាទត្រី ដងជ័រ ចិញ្ចឹមសត្វ បិទស្រា ខារ៉ាអូខេ លក់ដូរ ជាងឈើឈ្នួលញទិញលក់ត្រី និង ជាងទូក។ ការធ្វើស្រែ គឺជាមុខរបរសំខាន់ សំរាប់អ្នកភូមិកោះស្នែងដោយគាត់ធ្វើទាំងស្រូវចំការ និងស្រូវស្រែ។ ចំពោះស្រូវចំការចាប់ ធ្វើនៅខែឧសភា ដល់ខែសីហា ឯស្រូវស្រែចាប់ផ្តើមធ្វើពីខែសីហា ដល់ខែធ្នូ ឬខែមករា។ ចំពោះស្រូវស្រែជាទូទៅ អ្នកភូមិតែងធ្វើនៅក្នុងភូមិក្បែរលំនៅ ដ្ឋានរបស់គាត់ផ្ទាល់ ចំណែកឯស្រូវចំការវិញ គាត់ច្រើនធ្វើនៅតាមកោះនានា ដូចជាកោះហាន កោះទន្លេមួយ។ ការធ្វើស្រូវចំការនៅតាមកោះ គឺត្រូវទាមទារអោយគាត់ត្រូវសង់រោង និងស្នាក់នៅទីនោះរហូតដល់ការងារស្រែចំការរួចរាល់ ទើបគាត់ត្រឡប់ចូលភូមិវិញ។

ក្រៅពីធ្វើស្រែ ប្រជាជនភូមិកោះស្នែងពឹងផ្អែកលើធនធានធម្មជាតិដែលមាន នៅក្នុងភូមិរបស់គាត់។ ក្នុងចំណោម ធនធានទាំងនោះ ការប្រមូលជ័រជាប្រភពចំណូល មួយសំរាប់ការរស់នៅរបស់អ្នកភូមិកោះស្នែងចំនួន ៣គ្រួសារដែលបាន ទៅប្រមូលនៅចំងាយប្រមាណ ៣០គ.ម ពីភូមិកោះស្នែង គឺម្តុំអូរតាឡាស់ ព្រំប្រទល់ ឃុំកោះស្នែង និង ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ មុនឆ្នាំ១៩៩៣ តំបន់នេះគ្រប់គ្រងដោយ របបខ្មែរក្រហម។ បន្ទាប់ពីទាហានខ្មែរ ក្រហមបានដកចេញពីតំបន់នេះ ប្រជាជនដែលមកពីភូមិឆ្ងាំងក៏បានទៅដង ជ័រនៅកន្លែងនោះរហូតដល់ឆ្នាំ១៩៩៥ ទើបអ្នកភូមិ ៣គ្រួសារបានទៅប្រមូលជ័រនៅកន្លែង នោះដែរ។ អ្នកភូមិ កោះស្នែងមានដើម



ឈើយកជ័រប្រហែល ៣០០ដើម ដែលអាចផលិតជ័របាន ៣៩០ លីត្រ ក្នុងរយៈពេល ៥ថ្ងៃ។ ជ័រមាន ២ប្រភេទគឺ ជ័រលេខ ១ ដែលអាចលក់បាន ក្នុង តំលៃ ២៥,០០០-៣០,០០០រៀល/កាដុង ឯជ័រលេខ ២ គឺលក់បានក្នុងតំលៃ១៥,០០០ រៀល/កាដុង។

**មានព្រំប្រទល់ ៖**

ខាងជើងទល់នឹង អូរឈើទាល ភូមិកោះកី (ឃុំកោះស្នែង)

ខាងត្បូងទល់នឹង កន្ទុយកោះហាន

ខាងកើតទល់នឹង អូរសម្រោង សង្កាត់សាមគ្គី

ខាងលិចទល់នឹង អូរឃ្លួយលំ ភូមិកោះស្រឡៅ (ឃុំកោះស្នែង)

ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដោយមានការឧបត្ថពីសម្ព័ន្ធភាពតំបន់ដីសើម **(WAP)** អ្នកស្រាវជ្រាវគម្រោងសាលាភូមិក៏បានបន្តការសិក្សាទៅលើ ប្រភេទត្រីវុក្ខជាតិ អន្លង់ ឧបករណ៍នេសា សុខភាព និងបម្រែបម្រួលអាកាសធាតុ ។

## ៣- សាវតាភូមិវ៉ុនសៀន

ភូមិវ៉ុនសៀន ជាភូមិតូចមួយនៅលើកោះខនហាង។ នៅខាងលិចភូមិមាន អន្លង់ទឹកហូរវិលចុះវិលឡើង មួយដែល ប្រជាជនបានហៅអន្លង់នោះជាភាសាឡាវថា **វ៉ុនសៀន** ដែលមានន័យជាភាសាខ្មែរថា **អន្លង់ទឹកសង ឬ ទឹកវិល។**

នៅឆ្នាំ១៩៥២ ប្រជាជនមកពីកោះក្រឡាយ កោះហិប និងភូមិផ្សេងៗទៀត ចំនួន ៤-៥ គ្រួសារបានមក តាំងទីលំនៅ លើដីភូមិម្តុំមាត់អន្លង់នោះ ក៏នាំគ្នាហៅភូមិ នេះថា **ភូមិវ៉ុនសៀន** រហូតមកដល់សព្វថ្ងៃ។ តាំងពីដើម មកភូមិនេះ មិនសូវមាន អ្នកចំណូលថ្មីទេ ដោយសារជាកូនភូមិតូចស្ថិតនៅក្នុងព្រៃឆ្ងាយពីគេ។ នៅក្នុងឆ្នាំដដែល នេះ ប្រទេសកម្ពុជាទាំងមូលស្ថិតនៅក្រោមនឹមអាណានិគមបារាំង ឯអ្នកភូមិវ៉ុនសៀនបានត្រូវគេកែនយកទៅ ធ្វើផ្លូវជាតិលេខ ១៣ ពីស្ទឹងត្រែងទៅកាន់ព្រំដែនឡាវ ខណៈ� នោះអ្នកភូមិមានជីវភាពក្រលំបាកណាស់ ព្រោះគាត់ ត្រូវបង់ពន្ធជូនរដ្ឋ។

ឆ្នាំ១៩៥៤-១៩៦០ ខ្មែរបានទទួលឯករាជ្យពីបារាំង អ្នកភូមិមានជីវភាព ធូរធារបន្តិចព្រោះមិនបាច់បង់ពន្ធដារ។ ប៉ុន្តែមានការលំបាកនៅពេលមានជម្ងឺម្តងៗ គ្មានថ្នាំសង្កូវ គ្មានពេទ្យព្យាបាល។

ឆ្នាំ១៩៦៣-១៩៦៩ មានថៅកែម្នាក់ឈ្មោះ នោម ជាថៅកែឈើហ៊ុប មក កាប់ឈើធ្វើដេប៉ូដាក់នៅក្នុង ភូមិនេះ។ អ្នកភូមិមានជីវភាពធូរធារបន្តិចដោយសារ ប្រកបរបរធ្វើស្រែ ចំការ បានផលបង្គួរ។

ឆ្នាំ១៩៧០-១៩៧៤ លន់ណុលធ្វើរដ្ឋប្រហារទំលាក់សម្តេចឪ អ្នកភូមិភ័យខ្លាច យ៉ាងខ្លាំងហើយបានរត់ទៅជ្រកពួន កោះក្រឡាយដោយសារយន្តហោះទំលាក់គ្រាប់បែក ដែលធ្វើឱ្យជីវភាពគាត់កាន់តែ ក្រលំបាក អត់បាយ អត់អំបិល គ្មាន ថ្នាំសង្កូវ គ្មានពេទ្យព្យាបាល រស់នៅដោយគ្មាន សេរីភាព។



ឆ្នាំ១៩៧៥-១៩៧៨ របបខ្មែរក្រហមកាន់កាប់ បានបញ្ជូនអ្នកវ៉ុនសៀន ឱ្យត្រឡប់មករស់នៅក្នុងភូមិវិញ មិនត្រឹម តែប៉ុណ្ណោះបានបញ្ជូនប្រជាជនផ្សេងៗ មករស់នៅបន្ថែមទៀត។ អ្នកភូមិមានជីវភាពរស់នៅលំបាកវេទនាបំផុត ដោយធ្វើ ស្រែ ចំការរួម ហូបរួម រស់នៅជាសហករួមគ្នា ហើយនាពេលនោះក៏មានទឹកជំនន់ លិចលង់ស្រែ ចំការច្បារដំណាំ ដែលជាហេតុធ្វើឱ្យ ខ្វះស្បៀងអាហារ ទើបគាត់នាំគ្នា ទៅជាហូបក្តួច ដំឡូងព្រៃជាអាហារជំនួសវិញ។ ក្នុងសម័យកាលនោះ ស្ត្រីក៏ត្រូវធ្វើការ ធ្ងន់ដូចបុរសដែរ ទាំងក្នុងពេលមានផ្ទៃពោះក៏មិនបានសំរាក ហើយសំរាលកូនក៏មិនបានសំរាកយូរ គ្មានចំណីអាហារហូបបំប៉ន គ្រប់គ្រាន់។ ក្រុមគ្រួសារត្រូវរស់នៅបែក ឆ្ងាយពីគ្នា អ្នកភូមិមួយចំនួនបានជំលៀសចេញពីភូមិទៅធ្វើស្រែនៅភូមិគីឡូប្រាំបី អូរនទោង ញើន អូរពូក និងគុជចំបក់។

ឆ្នាំ១៩៧៩-១៩៨០ ក្រោយថ្ងៃរំដោះ ៧ មករា អ្នកភូមិបានបែកគ្នាដោយសារ ខ្មែរក្រហមកៀរយក ទៅព្រំដែនខ្មែរ-សៀម តែដោយសារកងទ័ពរណសិរ្ស សាមគ្គី សង្គ្រោះជាតិ ២ ធ្នូ បានសហការជាមួយកងទ័ព វៀតណាម បានរំដោះអ្នកភូមិ ឱ្យត្រឡប់មករស់នៅក្នុងភូមិវិញ។ ប្រជាជនរស់នៅក្នុងជីវភាពប្រសើរជាងមុន ប៉ុន្តែ ក្នុងការធ្វើស្រែចំការ គាត់នៅមានការ លំបាកដោយសារខ្វះកំលាំងអូសទាញ និង សំភារៈធ្វើស្រែ ចំការ។

ឆ្នាំ១៩៨០-១៩៨២ អ្នកភូមិធ្វើស្រែរួម បានផលចែកគ្នាតាមកំលាំងពលកម្ម ក្នុងនោះគ្រួសារខ្លះចាប់ ផ្តើមចិញ្ចឹម សត្វជ្រូក មាន់ ទា គោ ក្របី ។

ឆ្នាំ១៩៨២-១៩៩០ អ្នកភូមិបានឯកភាពសាងសង់សាលារៀនចំនួន ២ កន្លែង ដោយសាលាទី ១ បាំងជញ្ជាំង សំបកឈើ មានបណ្តោយ ៦ ម៉ែត្រ , ទទឹង ៥ ម៉ែត្រ

ដំបូលប្រក់ស្បូវ។ ឯសាលាទី ២ បាំងជញ្ជាំងឬស្សី មានបណ្តោយ ៨ម៉ែត្រ , ទទឹង ៦ម៉ែត្រ ដំបូលប្រក់ស្បូវ។ នៅឆ្នាំ ១៩៨៤ សាលាទី ១ បានខូចខាតអស់ដោយ សារដីទាបទឹកលិចពុកជញ្ជាំង ឬស្សី ពុកសរសរ មិនអាចបង្រៀនបាន រីឯសាលាទី ២ ខូចខាតនៅឆ្នាំ ១៩៩០ ដោយសារគ្រូចូលនិវត្តន៍ គ្មានអ្នកគ្រប់គ្រង ថែរក្សា។ នៅក្នុងឆ្នាំដដែលនេះមានគ្រោះទឹកជំនន់ ដែលបណ្តាល ឱ្យខូចខាតផលស្រូវ ជម្ងឺរាគត្បាតបណ្តាលឱ្យស្លាប់មនុស្ស អស់ ១៥នាក់ ចាប់ពីអាយុ ៦ឆ្នាំ ដល់ ១០ឆ្នាំ ដោយសារជម្ងឺកញ្ជ្រឹល និងរាគមួល។ ចំពោះសត្វក្របីជាច្រើនក្បាលងាប់ដោយ ជម្ងឺអុតក្តាម ដែលជាហេតុធ្វើឱ្យខ្វះកំលាំងអូសទាញក្នុងការធ្វើកសិកម្ម។

យ៉ាងណាមិញជំនឿទៅលើការសែនព្រេនអ្នកតាព្រៃភ្នំ នៅពេលមាន មនុស្សឈឺ ឬសត្វឈឺ គឺធ្វើមិនដែលខានទេដោយសារគាត់គិតថាមកពីខុសអ្នកតា ប៉ុន្តែការសែនព្រេននេះ ជួនកាលជា ជួនកាលក៏មិនជា។ ទន្ទឹមនឹងការសែនព្រេន ថ្នាំបុរាណ ដូចជាសំបកឈើ ស្លឹកឈើ គាត់ក៏បានយកមក ប្រើប្រាស់សំរាប់ព្យាបាលដែរ។

ឆ្នាំ១៩៩០-១៩៩៩ លទ្ធិប្រជាធិតេយ្យសេរីពហុបក្ស រីឯនៅក្នុងភូមិបានកើនផ្ទះចំនួន ៣ខ្នងទៀត។ ឯការប្រកប របរធ្វើស្រែចំការ ប្រជាជននៅខ្វះកំលាំងអូសទាញ ដូច្នេះគាត់ក៏នៅតែជួលក្របីពីអ្នកក្នុង និងក្រៅភូមិ ដោយក្របី ១ក្បាល សងវិញជាស្រូវ ១៧០ គីឡូក្រាម ក្រោយពេលប្រមូលផលរួច។ ក្នុងឆ្នាំនេះដែរ អ្នកភូមិបានសាងសង់សាលាឆទានមួយខ្នង មានបណ្តោយ ៧ម៉ែត្រ ទទឹង ៦ម៉ែត្រ ជញ្ជាំងបាំងឬស្សី ដំបូលប្រក់ ស្បូវ ទុកសំរាប់បង្រៀនសិស្ស និងធ្វើបុណ្យទានផ្សេងៗ ក្នុងភូមិ។ បន្ទាប់មកមានអង្គការជាច្រើនដូចជា **YWAM PFD** បានចុះផ្តល់ថ្នាំការពារជម្ងឺ ៦មុខដល់កុមារនិងផ្តល់ថ្នាំការពារជម្ងឺដល់ស្ត្រីនិងការចុះធ្វើផែនការអភិវឌ្ឍសហគមន៍។



ឆ្នាំ២០០២ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ហៅកាត់ថា CEPA បានចុះសំរង់ព័ត៌មាន PNRA លើធនធាន ធម្មជាតិ ដោយមានការចូលរួមពីមន្ត្រីការិយាល័យជលផលខេត្ត និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ដើម្បីលើកផែនការ អភិរក្សធនធានធម្មជាតិដោយមានការចូលរួម។ បន្ទាប់មកទៀត បានបង្កើតសហគមន៍នេសាទ ដែលសំរបសំរួលដោយ អង្គការសេប៉ា។ រហូតដល់ពេលបច្ចុប្បន្ននេះ ប្រជាជននៅភូមិវ៉ឺនសៀន កើនបានចំនួន ៣៦គ្រួសារ ។ ក្នុងនោះដែរ ការធ្វើស្រែ ចំការ ការរកអនុផលព្រៃឈើ ការរកត្រី គឺនៅតែជាអាទិភាពសំរាប់គាត់ រកទទួលទាន និង បង្កើនប្រាក់ចំណូលក្នុងគ្រួសារ នីមួយៗដដែល។

គំរោងសាលាភូមិរបស់អង្គការសេប៉ា **CEPA** សហការជាមួយកម្មវិធីអភិរក្សជីវៈចម្រុះតំបន់ដីសើម ទន្លេមេគង្គ **MWBP** គឺជាគំរោងថ្មីមួយដែលចូលរួមដោយ អ្នកស្រាវជ្រាវនៅពីក្នុងភូមិ។ គំរោងនោះចាប់ផ្តើម អនុវត្តនៅក្នុងខែឧសភា ឆ្នាំ២០០៥ ដោយធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទត្រីជីវភាពរស់នៅ និងការពឹង ផ្អែកលើអនុផលព្រៃឈើ។

បច្ចុប្បន្ននេះប្រជាជននៅភូមិវ៉ឺនសៀនកើនបានចំនួន ៥៣គ្រួសារ ស្មើនឹង ២៩៩នាក់ ក្នុងនោះដែរ ស្រីមានចំនួន ១១៧នាក់ នៅក្នុងនោះមានជនជាតិខ្មែរចំនួន..**១00%..**នាក់។

**មានព្រំប្រទល់:**

ខាងជើងទល់នឹងអូរគុម្ពជាប់ព្រំប្រទល់សហគមន៍នេសាទភូមិអូររុន

ខាងត្បូងទល់នឹង ពាក់កណ្ដាលអូរខនហាងជាប់ព្រំប្រទល់សហគមន៍នេសាទ

ភូមិកោះគី

ខាងកើតទល់នឹង ត្រឹមព្រំប្រទល់ដីក្រុមហ៊ុនជីជីវើលគ្រុប

ខាងលិចទល់នឹង កោះខនកែវជាប់សហគមន៍នេសាទភូមិក្រឡាពាស

ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដោយមានការឧបត្ថពីសម្ព័ន្ធភាពតំបន់ដីសើម (WAP) អ្នកស្រាវជ្រាវគម្រោងសាលាភូមិក៏បានបន្តការសិក្សាទៅលើ ប្រភេទត្រី រុក្ខជាតិ អន្លង់ ឧបករណ៍នេសា សុខភាព និងបម្រែបម្រួលអាកាសធាតុ ។



## ៤- សាវតាភូមិកោះល្ងូ

កោះល្ងូគឺជាភូមិមួយស្ថិតនៅក្នុងឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ ភូមិនេះគឺជាដីកោះ ដែលមាន បណ្ដោយ១.២០០ម៉ែត្រ និងទទឹង៥០០ម៉ែត្រ និងមានព្រំប្រទល់ខាងជើងជាប់នឹងកន្ទុយខន ខាងត្បូង ជាប់នឹងក្បាលកោះ សំបូរ , ខាង លិចជាប់នឹងអន្លង់ឈើទាល និង ខាងកើតទល់នឹងកោះសាដាំ ដែលពេលបច្ចុប្បន្ន ភូមិនេះមានប្រជាជនចំនួន ៦៨គ្រួសារ ស្មើនឹង ៣៤១នាក់ ក្នុងនោះមានស្ត្រីចំនួន ១៧៨ នាក់។

តាមដំណាលរបស់ចាស់ទុំនៅក្នុងភូមិ បានរៀបរាប់ថា កាលពីសម័យមុន ដោយសារតែចាញ់សង្គ្រាម ទើបមានកង ទ័ពម្នាក់ឈ្មោះ **កុំម៉ាមឿង** និងកូនទាហានដែលជាជនជាតិកាវ៉ែតមួយក្រុម បានភៀសខ្លួនចូលមករស់ នៅភូមិកោះល្ងូ ដោយប្រកបរបរធ្វើស្រែចំការ និងដាំដំណាំកសិកម្មផ្សេងៗ ជាពិសេសគឺ ដើមល្ងូ។ តាំង-ពីនោះមក គេចាប់ផ្ដើមហៅកោះនោះថា ភូមិកោះល្ងូ " ភាសាឡាវប្រែថា **បានជនឡាង៉ាក** "។

ឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៥ ប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលរៀបចំដោយ *អ៊ុនតាក់* ។ ចំពោះការប្រកបរបរធ្វើស្រែចំការ គឺបានទទួលទិន្នផលជាមធ្យម ព្រោះមានទឹកភ្លៀងគ្រប់គ្រាន់ ឯចំណែកការនេសាទត្រីវិញ មានការលំបាកបន្តិចដោយសារមានជនល្មើសនេសាទខុសច្បាប់ ដូចជា : គប់គ្រាប់បែក ឆក់ត្រី និងអូសអួន ។ល។

ឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០០ ប្រជាជនបានចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាលើកទី២ ដែលរៀបចំ ដោយ រាជរដ្ឋាភិបាល ។ ប្រជាជនចាប់ផ្តើម រស់នៅក្នុងជីវភាពធូរធារ មានដីស្រែច្រើនជាងមុនក្នុងការបង្កបង្កើនផល ប៉ុន្តែការ នេសាទគឺជាសេចក្តីកង្វល់របស់ប្រជាជន ពីព្រោះធនធានជលផលកាន់តែខ្សត់ទៅៗ ដោយសារការនេសាទ ខុសច្បាប់ និងការ នាំត្រីចេញទៅប្រទេសឡាវ ។ ដោយមើលឃើញពីការលំបាកបែបនេះ ទើបសមាគមថែរក្សា បរិស្ថាន និង វប្បធម៌ (ជភៅ) បានចូលសំរង់ព័ត៌មានលើធនធានធម្មជាតិដែលមានការចូលរួម និងការលើកផែន ការអភិវឌ្ឍន៍ដោយសហគមន៍ (PNRA) ព្រមទាំងជួយធ្វើការអប់រំបរិស្ថាន និងបានសម្របសម្រួលក្នុងការ បង្កើតសហគមន៍នេសាទ ដើម្បីជួយថែរក្សា និងប្រើប្រាស់ ធនធានជលផលឱ្យមាននិរន្តរភាពដោយសហគមន៍ ។

ខែមេសា ឆ្នាំ ២០០៦ គំរោងសាលាភូមិចាប់ផ្តើមដំណើរការ ដោយមានការចូលរួមពីសំណាក់ប្រជាជន នៅក្នុងភូមិ ក្រោមកិច្ចសហការរវាងអង្គការសេប៉ា **CEPA** និងកម្មវិធីអភិរក្សជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ **MWBP** ។ គំរោងនេះចាប់ផ្តើម អនុវត្តនៅក្នុងខែឧសភា ឆ្នាំ២០០៥ ដោយស្រាវជ្រាវទៅលើប្រធានបទត្រីជំរកត្រី និងជីវភាពរស់នៅ ។

ចំពោះស្ថានភាពរស់នៅរបស់អ្នកភូមិកោះល្វ គឺប្រជាជនចំនួន៩០ភាគរយប្រកបរបរធ្វើស្រែ ទោះបីជា យ៉ាងនេះក្តី ក៏ប្រជាជនមួយចំនួនធំ នៅតែជួបប្រទះ ការខ្វះស្បៀងដដែល ពីព្រោះគាត់ធ្វើស្រែពឹងផ្អែកលើទឹកភ្លៀង ទាំងស្រុង។ ម្យ៉ាងទៀតក្នុងមួយគ្រួសារៗមានស្រែប្រមាណពី២០-៣០ស្រែ ដែលក្នុង១ស្រែមានបណ្តោយប្រ



ហែល២០ម៉ែត្រ, ទទឹង ១០ម៉ែត្រ ប៉ុណ្ណោះ ដែលធ្វើឱ្យពួកគេទទួលបានទិន្នផល ជាម-ធ្យមពី ២០-៣០ហាបក្នុង១ឆ្នាំ (១ហាប = ៦០គ.កស្រូវ) ។ ចំណែក ការធ្វើចំការវិញ គឺមានប្រជាជនតែ ៣០ភាគរយប៉ុណ្ណោះ ដែលឆ្លៀតពេលពីធ្វើស្រែ មកដាំដំណាំចំរុះគ្រប់ប្រភេទដូចជា : ស្រូវ, ពោត, ត្រសក់, ល្ពៅ, ចេក, ត្រប់... សំរាប់ទុកហូបនៅក្នុងគ្រួសារ ។ ក្រៅពីនេះពួកគាត់នាំគ្នាចុះទៅនេសាទត្រី , លក់ដូរបន្តិចបន្តួច , ចិញ្ចឹមក្របី ។

**<u>មានព្រំប្រទល់:</u>**

ខាងជើងជាប់នឹង ព្រំដែនឡាវ

ខាងត្បូងទល់នឹង កោះសំបួរ

ខាងកើតទល់នឹង ព្រំដែនឡាវ

ខាងលិចជាបនឹង ឃុំព្រះរំកិល

ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន ដោយមានការឧបត្ថពីសម្ព័ន្ធភាពតំបន់ដីសើម **(WAP)** អ្នកស្រាវជ្រាវគម្រោងសាលាភូមិក៏បានបន្តការសិក្សាទៅលើ ប្រភេទត្រីរុក្ខជាតិ អន្លង់ ឧបករណ៍នេសា សុខភាព និងបម្រែបម្រួលអាកាសធាតុ ។

## ការពិពណ៌នាអំពីឧបករណ៍នេសាទ

## នៅភូមិកោះខនឌិន ភូមិកោះស្លែង ភូមិទ៊ីនសៀន និងភូមិកោះល្វ

## ជំពូក ១: ឧបករណ៍ដង ដួស និងជញ្ជាត់

### ១. ឈ្នាងជញ្ជាត់



**លក្ខណៈរូប** ឧករណ៍នេះធ្វើឡើងពីឫស្សី ផ្តៅ ឬខ្សែដំរ មានរាងកោង ដូចព្រះច័ន្ទថ្ងៃ ៨ កើត មានមុខកាត់ ០,៥-០,៦ ម៉ែត្រ ជម្រៅពី ៣-៤តឹក ប្រវែងពី ៧-៨តឹក ។

**វិធីធ្វើ** ដំបូងគេត្រូវទៅកាប់ឫស្សីយកមកពុះជាចំរៀក តូចៗ ប៉ុនចុងចង្កឹះ រួចគេបិតរាងសំប៉ែតស្មើរមូលសំរាប់ធ្វើជាឆ្អឹងឈ្នាង ដើម្បីពត់ទៅតាមរង្វង់ ទំហំរបស់ឈ្នាង រីឯបន្ទះឈ្នាងគេយកឫស្សីពុះជា ចំរៀក តូចៗជាងឆ្អឹងឈ្នាងបន្តិច រួចក៏ចាប់ផ្តើមក្រងត្បាញខ្វាស់លើកមួយសង្កត់មួយ ទៅតាមទំហំរង្វង់ដែលអ្នកប្រើពេញចិត្ត និងធ្លាប់ប្រើ តាមធម្មតាឈ្នាងជញ្ជាត់នេះមាន មុខកាត់ជាមធ្យម មិនលើសពី ០,៥-០,៦ម៉ែត្រ នោះទេ និងគូទ របស់ឈ្នាងគេធ្វើវាអោយមានរាង ដក់សំរាប់ត្រង ត្រី រឺកំពិស ។ ពេលគេចាប់ត្បាញគេត្រូវត្បាញអោយញឹក និងអមឫស្សីសងខាងដោយខ្សែផ្តៅ រឺខ្សែដំរ ហើយមុខឈ្នាងក៏ក្តាប់ដូចគែមដែរ ។

**វិធីប្រើប្រាស់** ដៃទាំងពីរចាប់អបសងខាង រួចចូកទឹកទៅមុខអោយលឿន ហើយលើកឡើង ក្រែងមានត្រីចូលឈ្នាង ។

**ទីកន្លែងនេសាទ** តាមមាត់ទឹកទន្លេ រាក់ៗ ជំរៅត្រឹមស្មងជើង ជ្រៅបំផុតត្រឹមជង្គង់ ។ គេអាចប្រើប្រាស់ឧបករណ៍នេះនៅតាមបឹង ត្រពាំង អូរ ស្រែ ជាដើម ។

**រដូវកាលប្រើប្រាស់** អាចប្រើបានគ្រប់រដូវកាល ( ពេញមួយឆ្នាំ) ។

**ប្រភេទត្រីរឺផលផានដែលនេសាទបាន** មានដូចជា ត្រីរៀល កំពិស ខ្យង ខ្ចៅ លៀស ត្រីអណ្តែង ត្រីផ្ទក់ ត្រីក្រាញ់ ត្រីកំភ្លាញ ជាពិសេសប្រភេទត្រីតូចៗ ។

**អ្នកប្រើប្រាស់** ប្រើប្រាស់បានទាំងក្មេង និងមនុស្សចាស់ ។

**ការវិវត្តន៍** ឈ្នាងជញ្ជាត់ជាឧបករណ៍នេសាទមួយប្រភេទ ដែលមានប្រើតាំងពីដូនតាយើងមក ក៏ប៉ុន្តែមបច្ចុប្បន្នមិនសូវមានអ្នកប្រើប្រាស់ឧបករណ៍នេះទេពីព្រោះវានេសាទបានតែកូនត្រី និងកំពឹស ហើយអ្នកភូមិគាត់ពិបាកក្នុងការទៅរកឫស្សីយកមកចាក់ធ្វើជាឈ្នាង ដូចនេះហើយទើបអ្នកភូមិបានផ្លាស់ប្តូរមកប្រើសំណាញ់ និងមងវិញព្រោះវាងាយស្រួលហើយនេសាទបានត្រីច្រើនជាងឧបករណ៍ ឈ្នាងជញ្ជាត់ ។

## ២. កញ្ច្រែងដួសត្រី



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** កញ្ច្រែងដួសត្រីគឺជាកញ្ច្រែងចំហមាត់រាងមូល ធ្វើពីបន្ទះឫស្សីរីខ្សែជ័រ ដែលមានមុខកាត់ចាប់ពី ១.២ - ១.៥ ម៉ែត្រ និងមានជំរៅប្រហែល ៤០ សង់ទីម៉ែត្រ ។ នៅចំមួយភាគបី នៃមុខកាត់ទទឹង មានបន្ទះឫស្សីមួយចំរៀក ប្រើដើម្បីងាយស្រួលក្នុងការកាន់ដើម្បីដួសត្រី ។

**វិធីធ្វើ** កញ្ច្រែងដួស គឺគេត្រូវទៅកាប់ឫស្សីយកមកពុះអោយតូចៗ ហើយ-យកមកបិទអោយស្តើងទំហំ ២ លី ។ បន្ទាប់មកគេយកឫស្សីមកត្បាញតាម ទំហំដែលចង់បាន ដែលចន្លោះពីក្រឡាមួយទៅក្រឡាមួយមានទំហំចាប់ពី ១-២ លី រួចយកមកត្បាញ និងយកមកជាន់អោយចេញរាងដូចពាងតែគ្រាន់តែមានរាង តូច មូលជាងពាង បន្តិច និងមាត់វាគេយកឫស្សីមកបិទអោយស្អាតរួចយកទៅក្តាប់ជាមួយខ្សែជ័រ ។



ហើយចំពោះរបៀបជាន់គឺគេត្រូវជីកដីដាក់ដើម្បីជាន់ទៅអោយ វាចេញជារូបរាងជាកញ្ច្រែងដួស និងមាត់របស់វាគេមានដាក់ឈើកាត់ទទឹង ដើម្បីងាយ ស្រួលកាន់ ។

**វិធីប្រើប្រាស់** បន្ទាប់ពីធ្វើរួចហើយគឺគេយកទៅដាក់លើទូក ដើម្បីយកទៅប្រើដោយប្រើចាប់ពី ១-៥ ឧបករណ៍ជា ដំបូងគេត្រូវដាក់កញ្ច្រែងដួសនេះទៅក្នុងទឹក រួចហើយបានគេដាក់នុយ ឬចំណីដូចជា កន្ទក់ អង្កាម ឬខ្លាញ់ត្រីរួចហើយគេ ដាក់ចំណីនេះនៅក្នុងកញ្ច្រែង នៅពេលដែលត្រីវាចូលក្នុងកញ្ច្រែងហើយ ក៏លើកឡើង យកទៅចាក់ចូលក្នុងទូក ។

**ប្រភេទត្រីដែលនេសាទបាន** ភាគច្រើនជាប្រភេទត្រីស្លឹកឫស្សី ត្រីចង្វារ និងត្រីរៀល ។

**រដូវកាលនេសាទ** គឺគេដួសចាប់ពីខែមករា ដល់ខែឧសភា ព្រោះជារដូវសំបូរត្រីស្លឹកឫស្សី ។

**អ្នកប្រើប្រាស់** អាចប្រើបានទាំងបុរស និងស្ត្រី ។

**ការវិវត្តន៍** បច្ចុប្បន្ននេះប្រជាពលរដ្ឋនៅក្នុងភូមិមិនសូវប្រើប្រាស់ឧបករណ៍នេះទេពីព្រោះនេសាទបានតែត្រីស្លឹកឫស្សី និងត្រីរៀល ហើយប្រជាពលរដ្ឋនៅក្នុងភូមិមិនសូវចេះធ្វើឧបករណ៍នេះ ។ កញ្ច្រែងដួសត្រីនេះមានប្រើប្រាស់នៅក្នុងភូមិ គឺតាមរយៈជនជាតិវៀតណាមដែលចូលមកនេសាទក្នុងភូមិកាលពីមុន ហើយក៏មានតែជនជាតិវៀតណាមនេះទេដែលចេះធ្វើឧបករណ៍នេះ ។

# ៣. ដូងដេញត្រី



**លក្ខណៈរូប** ឧបករណ៍នេះធ្វើពីឫស្សី ខ្សែនីឡុង ឫខ្សែជ័រ

**វិធីធ្វើ** យកឫស្សីពីរដើមដាក់ខ្វែងគ្នាយកខ្សែនីឡុង ឫខ្សែជ័រយកមកចាក់អោយបានប្រវែង ១-១.៥ ម៉ែត្រ រួចយកទៅចងរុំជាមួយនឹងដងឫស្សី។ ចំនែកនៅខាងចុងឫស្សីគេមានដាក់សំបកដូងទុំ ដើម្បីកុំអោយវាស្អិតជាប់នឹងដី ជាពិសេសកុំអោយវាពិបាករុញទៅមុខ។

**របៀបប្រើប្រាស់** មានអ្នកកាន់ដូនម្នាក់និងមានអ្នកជិះទូកពីរនាក់ដើម្បីដេញត្រីអោយវាផ្អើលហើយប្រដាប់ដេញត្រី គេធ្វើពីឫស្សីធំនៅក្រោមឫចុង ហើយដាក់ឫស្សីតូចប៉ុនក៏ដៃធ្វើជាដងសំរាប់ដេញត្រី ។



**រដូវកាលប្រើប្រាស់** ចាប់ពីខែឧសភាដល់ខែតុលា ។

**ទីកន្លែងនេសាទ** នៅតាម អូរ ទន្លេ បឹង តាមកោះ ។

**ប្រភេទត្រីដែលបាន** មានត្រីរ៉ស់ ត្រីឆ្ពិន ត្រីឆ្តោ ត្រីក្រាយ ត្រីអំបូង និងត្រីស្លាត។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** កាលពីមុនត្រីសំបូរប្រជាពលរដ្ឋចូលចិត្តប្រើប្រាស់ឧបករណ៍នេះ ក៏ប៉ុន្តែបច្ចុប្បន្នត្រីមិនសូវសំបូរដូចពីមុន ហើយឧបករណ៍នេះនេសាទត្រីមិនសូវបានអ្នកភូមិស្ទើរតែឈប់ប្រើឧបករណ៍នេះ ហើយប្តូរមកប្រើមង និងសំណាញ់វិញព្រោះអាចរកត្រីបានច្រើនជាងឧបករណ៍នេះ ។

## ជំពូក២៖ ឧបករណ៍សន្ទូច

### ២.១ សន្ទូចទោល

### ២.១.១ សន្ទូចបបក់



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** មានដងឫស្សីធំប៉ុនកដៃកូនក្មេង ដែលមានប្រវែងចាប់ពី៦-៨ម៉ែត្រ ហើយខ្សែចងប្រវែងពី ១០-១៥ ម៉ែត្រ ទំហំលេខខ្សែ ៥០-៧០ (លេខសំគាល់ខ្សែ ) ហើយផ្លែភាគច្រើនអ្នកភូមិគឺជាអ្នកធ្វើខ្លួនឯងផ្ទាល់ ដោយយកឆ្អឹងទ្រនុងឆ័ត្រយកមក ឆាបអោយចេញជាផ្លែសន្ទូច។

**វិធីធ្វើ** ដំបូងគេត្រូវទៅកាប់ឫស្សីប៉ុនកដៃកូនក្មេង ហើយត្រូសអោយស្អាត រួចហើយយកទៅរោលភ្លើង និងពត់អោយវាកោង ចំនែកនៅខាងគល់នៃសន្ទូចគេធ្វើចំពាម សំរាប់ដាក់នៅលើភ្លៅ ពេលគេបបក់ត្រី។



**របៀបប្រើប្រាស់** ដំបូងគេត្រូវធ្វើគន្លងសំរាប់បបក់ត្រី បើសិនជាកន្លែងនោះមានឈូក កំប្លោក រឺ ចក ដោយយើងទាញចេញ អោយមានរាងតូច ដូចជា ប្រឡាយ-ទឹក។ ហើយមុនពេលដែលយើងបោះខ្សែចូលទឹក យើងត្រូវគ្រវីខ្សែរួចបោះចូលទៅក្នុងទឹកអោយត្រូវគន្លងដែលបានវែកចេញនោះ រួចហើយគេយកគល់សន្ទូចដែលមានមែកចំពាមមកដាក់នៅលើភ្លៅ រួចហើយគេញាក់ដងសន្ទូចរហូតដល់កន្លែងដែលយើងឈរ ហើយប្រសិនបើត្រីវាត្របាក់គេវាត់តែម្តង។

**ទីកន្លែង** ច្រើននៅតាមបឹង ត្រពាំង ហើយនុយ មានដូចជាកូនកង្កែប កូនដង្កូវខ្នង ។

**រដូវកាល** ភាគច្រើនគឺចាប់ពីខែ សីហា ដល់ខែ តុលា

**ប្រភេទត្រី** ត្រីរ៉ស់ ត្រីឆ្តោ ត្រីខ្ទាន់...។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** បច្ចុប្បន្ននេះប្រជាពលរដ្ឋនៅក្នុងភូមិមិនសូវប្រើប្រាស់ទេ គឺពួកគាត់ប្រើសន្ទូចរនង និងមងវិញព្រោះរកត្រីបានច្រើនជាងសន្ទូចបបក់នេះ ។

## ២.១.២ សន្ទូចទវាត់



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** មានដងឬស្សីរាងវែងដោយយើងចងខ្សែពីចុងដងសន្ទូចម្ខាង ដោយប្រើខ្សែនីឡុង រឺខ្សែជ័រប្រវែង ៥-៦ ម៉ែត្រ លេខ ៣០-៤០។ ចំនែកផ្លែយើង ប្រើលេខ ១២ ឬ១៥ និងដងសន្ទូចមានប្រវែងចាប់ពី ២-៣ ម៉ែត្រ ទំហំប៉ុនមេដៃ ហើយចុងតូចរាងកោង ហើយនៅខ្សែនៃសន្ទូចគេមានដាក់កំសួល សំរាប់ដឹងថាត្រីវាស៊ី ហើយយើងក៏អាចរួតចុះឡើងបានទៅតាមជំរៅទឹក។

**វិធីធ្វើ** គឺងាយស្រួលណាស់ដោយគ្រាន់តែយើងទៅកាប់ឬស្សីប៉ុនមេដៃ នៅក្បែរភូមិ ចំនែកខ្សែ និងផ្លែរបស់វា គឺយើងទៅទិញយកមកពីផ្សារ ហើយយកមក ចងភ្ជាប់ទៅនឹងដងសន្ទូច ផ្លែ និងប៉ោលជាការស្រេច។



**របៀបប្រើប្រាស់** ដាក់នុយជាប់ជាមួយផ្លែសន្ទូច រួចបោះខ្សែចូលទៅក្នុងទឹក នៅពេលដែលត្រីស៊ី ប៉ោលលិច រួចហើយយើងវាត់មកជាការស្រេច។

**ទីកន្លែង** ប្រើភាគច្រើននៅ តាមអូរ ពាម បឹង និងច្រាំងទន្លេ ។

**រដូវកាលប្រើប្រាស់** គឺពេញមួយឆ្នាំ។ ចំពោះនុយមានដូចជា ជន្លេនដង្កូវខ្យង ពងអង្ក្រង កំពិស ផ្លែលាចផ្ទុះ។

**ប្រភេទត្រី** មានដូចជា ត្រីឆ្លាត ត្រីខ្ជឹង ត្រីក្រាញ់ ត្រីកញ្ចុះ ត្រីឆ្លាំង ត្រីព្រាម ត្រីអណ្តែង ត្រីឆ្ពិន ត្រីកន្ទ្រប់ ត្រីរមាស់។

**អ្នកប្រើប្រាស់** ទាំងចាស់ ទាំងក្មេង ។

**ការវិវត្តន៍** បច្ចុប្បន្នឧបករណ៍សន្ទូចនេះប្រជាពលរដ្ឋនៅតែចូលចិត្តប្រើប្រាស់ ជាពិសេសគឺក្មេងៗ ចំណែកមនុស្សចាស់គឺគាត់មិនសូវប្រើប្រាស់សន្ទូចនេះទេ គឺគាត់ ប្រើប្រាស់មង និងសំណាញ់វិញ ព្រោះវាអាចរកបានត្រីច្រើនជាង ។

## ២.២ សន្ទូចបង្កៃ

### ២.២.១ សន្ទូចបង្កៃត្រីរស



**លក្ខណៈរូប** សន្ទូចនេះធ្វើឡើងពីផ្លែសន្ទូចដែកលេខ ១២-១៣ ខ្សែជ័រ ឬខ្សែនីឡុងលេខ ៧០។ ប្រើខ្សែអស់ចំនួន ១ដុំ ក្នុងសន្ទូចមួយអស់ខ្សែចំនួន ៣-៤ដុំ ខ្សែខៀវអស់ ២ដុំ។ ហើយគេប្រើផ្លែអស់ចំនួនពី ៥០-១០០ ផ្លែ ។

**វិធីធ្វើ** យកខ្សែមកចងនឹងផ្លែសន្ទូច

**វិធីប្រើប្រាស់** យកនុយមកដោតនឹងផ្លែសន្ទូចហើយយកវាមកចងតាមព្រៃលិចទឹក។

**ប្រភេទនុយដែលប្រើ** មាន ជន្លេន ចង្រិត ត្រីរៀល ក្តាម កង្កែប ខ្យងហ៊ាន។



**ពេលវេលាដាក់** នៅម៉ោង ២-៣ ល្ងាច នៅម៉ោង ៥-៦ គេទៅមើលវា

**ទីកន្លែងប្រើប្រាស់** នៅតាមខាង១ព្រៃលិចទឹក

**ប្រភេទត្រីដែលដាក់បាន** ត្រីរស់ ត្រីឆ្លាំង ត្រីខ្ញឹង ត្រីក្រាយ ត្រីឆ្តិន ត្រីរមាស ត្រីកូនត្រីខ្យា ។

**អ្នកប្រើប្រាស់** អាចប្រើបានទាំងក្មេង និងចាស់។

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ បើសិនជាគាត់ឧស្សាហ៍ទៅមើលសន្ទូច និងផ្លាស់នុយ ១ថ្ងៃអាចបាន ពី៣ទៅ៥គីឡូក្រាម ។

## ២.២.២ សន្ទូចពុម្ពបន្ដោត្រីខ្យា



**លក្ខណៈរូប** សន្ទូចនេះខុសពីសន្ទូចពុំតូចត្រង់សន្ទូចនេះ គេយកដុំសំណមកចងជាប់នឹងខ្សែសន្ទូច ។

-ផ្លែសន្ទូចលេខ ៤-៥ ,ខ្សែនីឡុងលេខ ៦០ , សំណរ១,៥គីឡូក្រាម បានសន្ទូច ១៣ផ្លែ.

-ប្រវែងខ្សែសន្ទូច ៣-៤ម៉ែត្រ

**វិធីធ្វើ** ពុំរបស់សន្ទូចគេធ្វើអំពីសំណ ដោយគេស្លសំណអោយរលាយ រយៈពេលប្រហែល១ម៉ោង រួចគេយកឈើមកធ្វើអោយវាមានរាងស្រួចចុង ហើយដំចូលទៅក្នុងដី បន្ទាប់មកគេដកឈើចេញរួចយកស្លឹកចេកមកបត់វាអោយមានរាងដូចឈើដែលយើងដំចូលនោះហើយដាក់វាចូលទៅក្នុងដី បន្ទាប់មកទៀតយើងយកសំណ



ដែលស្លរួចនោះ ទៅចាក់ចូលក្នុងស្លឹកចេក ដើម្បីធ្វើជាប្រហោងសំរាប់ ស៊កខ្សែបញ្ចូល នៅពេលដែលគេចាក់ចូលទៅក្នុងស្លឹកចេកហើយគេច្រៀកឬស្សីអោយ តូចមួយចាក់ចំកណ្ដាលសំណដែលគេចាក់ចូលទៅក្នុងស្លឹចេកនោះ គេទុករយៈពេលប្រហែល២-៣នាទីទើបវារឹង បន្ទាប់មកគេយកវាទៅដាក់ត្រាំទឹកហើយទុកវាអោយត្រជាក់ទើបគេយកឬស្សីដែលគេដោតនោះចេញរួចគេស៊កខ្សែចូល ហើយគេចងខ្សែនោះជាមួយនឹងផ្លែសន្ទូចជាការស្រេច ។

**វិធីប្រើប្រាស់** យកកូនត្រីមកដោតវារួចដាក់វាចូលទៅក្នុងទឹក បន្ទាប់មកចងខ្សែនឹងមែកឈើ ទុកវាចោលរយៈពេល ១យប់ទើបទៅមើលវាម្ដង ។

**ទីកន្លែងប្រើប្រាស់** ព្រៃត្រែង , ព្រៃលិចទឹក ,មាត់អូរមានជំរៅ២-៣ម៉ែត្រ។

**រដូវកាលប្រើប្រាស់** ពេញ១ ឆ្នាំ

**ប្រភេទត្រីដែលដាក់បាន** ត្រីខ្យា , កញ្ចុះ ,ស្លាបមាន់ , ឆ្លាំង ដោយប្រើនុយដូចជាត្រីកញ្ចុះ ,ឆ្លាំង ,ថ្លែន ,ខ្យងហ៊ាន...។

**អ្នកប្រើប្រាស់** ប្រើបានទាំងបុរសនិងស្ត្រី

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ ក៏ប៉ុន្តែរកត្រីមិនសូវបានដូចពីមុន ។ កាលពីមុន ១ថ្ងៃ ទៅ២ថ្ងៃ អាចបានត្រីមួយដែលមានទំហំពី ១០ ទៅ ១៥គីឡូក្រាម ហើយតិចបំផុតក៏ ៣គីឡូក្រាមដែរ ប៉ុន្តែបច្ចុប្បន្នវិញ ៤ទៅ ១០ថ្ងៃទើបបាន១គីឡូក្រាម មូលហេតុគឺដោយសារបច្ចុប្បន្នត្រីមិនសូវសំបូរដូចមុន ។

## ២.២.៣ សន្ទូចបង្កៃ






**លក្ខណៈរូប** ដងសន្ទូចបង្កៃមានរាងតូងប៉ុនមេដៃ ចុងរាងកោងបន្តិចមាន ប្រវែង ១ម៉ែត្រ ហើយខ្សែមានប្រវែង ៦ តឹក ទំហំខ្សែ លេខ ៣០ ( លេខសំគាល់ខ្សែ) ចងភ្ជាប់ដោយប្រើផ្លែលេខ ១២-១៥រឺ១៦ ( លេខសំគាល់ផ្លែ) ។

**វិធីធ្វើ** យកឫស្សីមកពុះជាចំរៀកតូចៗ រួចបិតអោយតូច ស្អាតដោយអោយ ចុងបង្កៃមានរាងស្តើងបន្តិចដើម្បីអោយវាកោងរលាស់បាន បន្ទាប់មកយើងយកខ្សែ ដ៏រដែលមានប្រវែង៦តឹក យកទៅចងភ្ជាប់នឹងចុងបង្កៃ និងផ្លែចងភ្ជាប់ទៅនឹងខ្សែ។ នៅដងបង្កៃគេមានដាក់លួស រឺក៏ស្បែកជើងនៅគល់សន្ទូចដើម្បីគេយកផ្លែសន្ទូច ទៅ ថ្កក់ដើម្បីកុំអោយវាជំពាក់គ្នាពេលសារ ។

**វិធីប្រើប្រាស់** យើងយកបង្កៃយកទៅដោតនៅតាម មាត់ទន្លេ មាត់បឹង ដោយដោតអោយឆ្ងាយ ពីគ្នាប្រវែង២ម៉ែត្រ ដោយដោតជាជួរ រួចហើយទើប គេដាក់ នុយតាមក្រោយ ជួនកាលគេដាក់នុយហើយ ដោតយកតែម្តងជាការស្រេច។



**រដូវកាលប្រើប្រាស់** ភាគច្រើនចាប់ពីខែ មិថុនា ដល់ខែ កញ្ញា ។

**ប្រភេទត្រី** មានដូចជា ត្រីឆ្លាំង ត្រីអណ្តែង ត្រីរ៉ស់ ត្រីខ្ជឹង ត្រីក្រាយ ត្រីកែ ត្រីត្រនេល ត្រីខ្យា... ដោយប្រើនុយដូចជា ជន្លេន កូនកង្កែប និងចង្រិត។

**អ្នកប្រើប្រាស់** ទាំងចាស់ ទាំងក្មេង ។

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ គ្រាន់តែកាលពី មុនផ្លែ១០ក្នុង១យប់អាចបានត្រី៣ទៅ៥គីឡូក្រាម ក៏ប៉ុន្តែបច្ចុប្បន្ននេះ ផ្លែ១០ ១យប់ បាន១ទៅ២គីឡូក្រាមហើយថ្ងៃខ្លះក៏អត់បានផង មូលហេតុគឺដោយសារបច្ចុប្បន្នត្រី មិនសូវសំបូរដូចមុន ។

## ២.៣ សន្ទូចរនង

## ២.៣.១ សន្ទូចរនង រឺសន្ទូចបណ្តែតលើ



**លក្ខណៈរូប** សន្ទូចរនងគឺជាប្រភេទឧបករណ៍នេសាទបែបបុរាណដែលមានរូបរាងទ្រវែងធ្វើអំពីខ្សែជ័រដែលមានប្រវែងចាប់ពី ៥០-១០០ម៉ែត្រ និងខ្សែសំរាប់ចងភ្ជាប់ផ្លែទៅនឹងខ្សែមានប្រវែងពី៨តឹកដល់១ម៉ែត្រដោយគេប្រើខ្សែលេខ ៧០-៩០ (លេខសំគាល់ខ្សែ) និងប្រើផ្លែលេខ ៩ ទៅ លេខ១១ ។

**វិធីធ្វើ** គឺមានភាពងាយស្រួលណាស់ដោយគ្រាន់តែទៅទិញខ្សែជ័រនិងផ្លែយកមកពីផ្សាររួចយកមកចងផ្លែនិងខ្សែជាប់គ្នាជាការស្រេច ដោយមិនចំណាយពេលយូរ ។

**ទីកន្លែង** ភាគច្រើនដាក់នៅតាមទន្លេ បឹង អូរ ។

**របៀបប្រើប្រាស់** ក្នុងការប្រើប្រាស់ដំបូង យើងវាយននងចងនឹងដើមឈើរួចយើងចាប់ផ្តើមយកផ្លែសន្ទូចទៅចងដោយគេចងអោយ ហើយអស់ទើបគេដាក់នុយតាមក្រោយ ជួនកាលគេដាក់មួយចងមួយ ភាគច្រើនគេប្រើនុយដូចជា ជន្លេន ចង្រិត



ផ្លែល្ងា ផ្លែទម្លាប់ ផ្លែត្រដិត កូនត្រី មេខ្ចិល ផ្កាអណ្តែង កូនក្តាម និងកូនកង្កែប។

**ពេលវេលាប្រើប្រាស់** សន្ទូចនេះគេអាចបណ្តែតបានពេញមួយឆ្នាំ ។

**ប្រភេទត្រី** មានដូចជា ត្រីខ្យា ត្រីកេស ត្រីត្រនេល ត្រីឆ្ពិន ត្រីពោ ត្រីកែ ត្រីឈ្បៀត ត្រីក្លាំងហាយ ត្រីឆ្កោក ត្រីព្រលូង និង ត្រីក្របី។

**អ្នកប្រើប្រាស់** ទាំងចាស់ ទាំងក្មេង ។

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ គ្រាន់តែមានប្រជាពលរដ្ឋមួយចំនួនតូចបានប្រើប្រាស់នុយអប់ គឺជានុយដែលកែប្រែពីត្រី ហើយទុករយះពេលកន្លះឡើងទៅយកមកប្រើប្រាស់ វាមានក្លិនស្អុយធ្វើអោយត្រីឆាប់ស៊ីនុយ ហើយវាក៏ជាប្រភេទជានុយខុសច្បាប់ ។ បើសិនជាប្រើនុយអប់ក្នុងចំនោម១០០ផ្លែអាចបានត្រីយ៉ាងតិចបំផុតក៏៣០ទៅ៥០ត្រីដែរ ប៉ុន្តែបើយើងប្រើនុយធម្មតាវិញក្នុងចំនោម១០០ផ្លែបានត្រីយ៉ាងច្រើនពី១០ទៅ២០ក្បាល។

## ២.៣.២ សន្ទូចសំយាប



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** គេធ្វើពីខ្សែលេខ ៨0 ហើយផ្លែរបស់វាមាន លេខ ៨ ក្នុងសន្ទូចមួយគេប្រើខ្សែអស់ចំនួន ១,៥ គីឡូក្រាម ហើយប្រើផ្លែអស់ ចំនួនពី ២0-៣0ផ្លែ ដែលខ្សែរបស់វាមានប្រវែងពី ៥-៨ ម៉ែត្រ ។

**វិធីធ្វើ** យកខ្សែជ័រលេខ ៨0 ប្រវែង ១,៥-២ម៉ែត្រ ទៅចងជាមួយនឹងផ្លែសន្ទូច ។

**វិធីប្រើប្រាស់** ចងតាមមែកឈើ ចុងដើមអញ្ចែង បណ្ដែតតាមខ្សែទឹក ។

**ប្រភេទនុយដែលប្រើ** ចង្រិត ជន្លេន ត្រីរៀល កណ្ដូប ផ្លែល្វា។

**ទីកន្លែងប្រើប្រាស់** គេចងវានៅតាមព្រៃលិចទឹក

**រដូវកាលប្រើប្រាស់** គេប្រើវាពីខែ មិថុនា ដល់ខែតុលា



**ប្រភេទត្រីដែលចាប់បាន** មាន ត្រីខ្យា ត្រីកែ ត្រីក្រពើ ត្រីកេស ត្រីពោ ត្រីប្រា ត្រីឆ្ពាត ត្រីឆ្កោក។

**អ្នកប្រើប្រាស់** ទាំងក្មេង និងចាស់។

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ ជាពិសេសគឺពួកគាត់ប្រើនៅរដូវទឹកឡើង យ៉ាងហោចណាស់ ១0ផ្លែក៏បានត្រីចាប់ ពី ៤ទៅ៥ ត្រីដែរក្នុងមួយយប់សម្រាប់ធ្វើម្ហូប ។

## ២.៣.៣ សន្ទូចសំយ៉ុង



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** គេធ្វើពីផ្លែលេខ ៤-៨ ហើយខ្សែរបស់វាមានលេខ ៦០ ខ្នងសន្ទូចមួយគេប្រើខ្សែអស់ចំនួន ១,៥ គីឡូក្រាម ហើយប្រើផ្លែអស់ចំនួនពី ២០-៣០ផ្លែ ដែលខ្សែ របស់វាមានប្រវែងពី ៥-៨ម៉ែត្រ ។

**វិធីធ្វើ** យកខ្សែជ័រលេខ ៨០ ប្រវែង ១,៥-២ម៉ែត្រ ទៅចងជាមួយនឹងផ្លែសន្ទូច ។

**វិធីប្រើប្រាស់** ដំបូងគេយកដុំថ្មមួយដុំមកចងជាប់ជាមួយនិងផ្លែសន្ទូច ដែលមានប្រវែងកន្លះម៉ែត្រពីផ្លែសន្ទូចហើយចងភ្ជាប់ជាមួយមែកឈើ បន្ទាប់មកទំលាក់ចូលទៅក្នុងទឹក ។ សន្ទូចសំយ៉ុង និងសន្ទូចសំយ៉ាបមានការប្រើប្រហាក់ប្រហែលគ្នា គ្រាន់តែសន្ទូចសំយ៉ុងប្រើនៅរដូវទឹកស្រក និងសន្ទូចសំយ៉ាបប្រើនៅរដូវទឹកឡើង ។

**ទីកន្លែងប្រើប្រាស់** ចងវានៅតាមព្រៃលិចទឹកដែលមានជម្រៅពី២-៣ម៉ែត្រ

**រដូវកាលប្រើប្រាស់** គេប្រើវាពីខែ ១០-១១



**ប្រភេទត្រីដែលដាក់បាន** មានត្រីខ្យា កែ ក្រពើ កេស ...។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាពលរដ្ឋនៅក្នុងភូមិនៅប្រើប្រាស់ធម្មតាទេ ជាពិសេសគឺពួកគាត់ប្រើនៅរដូវទឹកស្រក យ៉ាងហោចណាស់ ១០ផ្លែក៏បានត្រីចាប់ ពី ៤ទៅ៥ ត្រីដែរក្នុង មួយយប់សម្រាប់ធ្វើម្ហូប ។

## ២.៣.៤ សន្ទូចពុម្ពតូច



**លក្ខណៈរូប** ផ្លែរបស់វាលេខ១២ ហើយខ្សែរបស់សន្ទូចលេខ៨០ ប្រវែង ១៥-២០ម៉ែត្រ ។

**វិធីធ្វើ** ដំបូងគេយកឈើទំហំប្រហែលប៉ុនមេដៃមកសំរួចគួចវាអោយមូលមានរាងដូចកន្ទោង បន្ទាប់មកយកឈើដែលបានសម្រួចរួចនោះទៅបុកចូលទៅក្នុងដីហើយដកឈើនោះចេញមកវិញ បន្ទាប់មកគេយកឈើតូចមួយទំហំប្រហែលធំជាងខ្សែដំរលេខ ៨០ យកទៅដោតថ្នឹង អោយស្មើចំកណ្តាលកុំអោយលំអៀង រួចយកស្លឹកចេក មកធ្វើជាកន្ទោងអោយមានរាងដូចរណ្តៅដីដែលគេបុករួចនោះ បន្ទាប់មកគេយកសំណដែលបានស្លរួចរាល់នោះទៅចាក់ចូលក្នុងពុម្ពស្លឹកចេក បន្ទាប់ពីចាក់សំណហើយភ្លាមត្រូវចាក់ទឹកចូលភ្លាមដើម្បីកុំអោយឆេះឈើស្នូល។ ក្រោយពីចាក់ទឹកចូលភ្លាមវាកកភ្លាម បន្ទាប់មកគេក៏ដកយកដុំសំណដែលចាក់រួចនេះទៅទុកអោយត្រជាក់ដោយខ្លួនឯង ឬគេអាចយកវាទៅដាក់ត្រាំទឹកដើម្បីអោយឆាប់ត្រជាក់។



ក្រោយពីត្រជាក់ហើយទើបគេដកយកឈើស្នូលកណ្តាលនោះចេញ បន្ទាប់មកយកខ្សែដំរចូល ហើយគេយកកន្ទុយខ្សែទៅចងជាមួយផ្លែសន្ទូច និងធ្វើការចងគួចខ្សែ ឬយកឈើមកសៀតដើម្បីកុំអោយដុំសំណរត់ចុះរត់ឡើង។ ការចងគួចខ្សែដុំសំណនេះគេត្រូវចងទុក ។

**វិធីប្រើប្រាស់** ដៃម្ខាងគេចាប់ខ្សែដៃម្ខាងទៀតគេចាប់ផ្លែសន្ទូចបោះចូលទៅក្នុងទឹក។ ប្រភេទនុយមានដូចជា ជន្លេន ប្រហុក ចង្រិត កណ្តូប ។

**ទីកន្លែងប្រើប្រាស់** កន្លែងដែលមានទឹកហូរហើយគ្មានសំរាស់ឈើ គល់ឈើ មាត់អូរ ទឹកជួរ , ទឹកវិល , ប៉ែរ , អូរ , ទន្លេ ។

**រដូវកាលប្រើប្រាស់** ពេញ១ ឆ្នាំភាគច្រើនខែ ១០-១១

**ប្រភេទត្រីដែលដាក់បាន** ត្រីកែ,ឆ្តោក,ក្រាយ,ក្អុក,ព្រាម,ឆ្ពិន,កញ្ជ្រូក,ខ្យា,កញ្ចុះ,ស្លាបមាន់,ឆ្លាំង ...។

**អ្នកប្រើប្រាស់** ប្រើបានទាំងក្មេងនិងចាស់ ។

**ការវិវត្តន៍** កាលពីមុនប្រជាជនប្រើច្រើន ប៉ុន្តែបច្ចុប្បន្នមិនសូវមានអ្នកប្រើប្រាស់ទេ ពីព្រោះមិនសូវសំបូរត្រីដូចកាលពីមុន ដូចច្នេះពួកគាត់បានផ្លាស់ប្តូរមកប្រើប្រាស់មង និងសំណាញ់វិញ ព្រោះវាអាចធ្វើអោយពួកគាត់ទទួលបានត្រីច្រើនជាងប្រើសន្ទូចពុម្ពនេះ ។

## ជំពូក ៣៖ ឧបករណ៍អន្ទាក់

### ៣.១ លោប ឌុច ចាន់

### ៣.១.១ លោប



**លក្ខណៈរូប** លោបមានលក្ខណៈដូចស្វាងដែរដោយវាមានរាងដូចសំបុក-មាន់គ្រាន់តែតូច និងខ្លីជាង។ លោបក្រងពីឬស្សីយកមកពុះជាជំរៀកហើយ ក្រងដូចជាព្រួល បន្ទាប់មកផ្គុំវាដូចជាទ្រូដែរដោយគេក្រងវិលរហូតដល់មាត់របស់វាឡើងរីកធំតាមធម្មតាគេច្រើន ធ្វើវាមានប្រវែងចាប់ពី ១-២(ម៉ែត្រ) និងទំហំមុខកាត់ចាប់ពី ១៥-២០ (សង់ទីម៉ែត្រ)លោបគេច្រើនប្រើវល្លិ៍ក្រង ជាមួយឬស្សី និងក្រឡាវាប៉ុនម្រាមដៃ។

**របៀបធ្វើ** យើងពុះឬស្សីជាបន្ទះតូចៗប៉ុនចង្កឹះរួចចង នឹងវល្លិ៍ពីកន្ទុយ រហូតដល់មាត់ដោយមាត់គេក្រងពង្រីក ដើម្បីជំរងត្រី។



**របៀបប្រើប្រាស់** ចំពោះការប្រើប្រាស់គឺគេយកវាទៅដាក់តាមជួរទឹក ដែលមានរង្វះទឹកតូចៗហើយទឹកនោះហូរជាប្រចាំដែលជាផ្លូវសំរាប់ត្រីធ្វើចរាចរណ៍។ ប្រភេទឧបករណ៍ដែលនេសាទនេះគេដាក់វានៅតាមទន្លេ អូរនិងស្រែ ដោយមិនប្រើប្រួលនោះទេដោយ គេគ្រាន់តែបោះបង្គោលសំរាប់ទប់ កុំអោយវាប៉ើងតាម ទឹកហូរ។

**រដូវកាលប្រើប្រាស់** ប្រើបានពេញមួយឆ្នាំ ដូចជានៅរដូវប្រាំងគេដាក់នៅតាមទន្លេ តាមចន្លោះថ្ម និងខែវស្សាគេដាក់នៅតាមត្រពាំង អូរ បឹង ជាដើម។ ហើយជំរៅទឹកដែលគេដាក់គឺដាក់ ក្នុងជំរៅទឹកត្រឹមពាក់កណ្ដាលស្មងជើងតែប៉ុណ្ណោះ។

**ប្រភេទត្រី** មានដូចជា ត្រីរ៉ស់ ត្រីផ្ទក់ ត្រីអណ្ដែង ត្រីអាចម៍កុក និងប្រភេទត្រីតូចៗជាច្រើនទៀត។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ព្រោះនៅក្នុងមិនសូវមានអ្នកចេះធ្វើ ហើយដោយសារតែបច្ចុប្បន្នត្រីមិនសូវសំបូរដូចពីមុន ដូចនេះការប្រើប្រាស់លោបនេះក៏ដាក់ត្រីមិនសូវបានដែរ ពួកគាត់បានធ្វើការផ្លាស់ប្ដូរមកប្រើ មង សំណាញ់វិញព្រោះអាចធ្វើអោយគាត់រកត្រីបានច្រើនជាង ។

## ៣.១.២ ជុច



**លក្ខណៈរូប** ជុចជាឧបករណ៍មួយមានរាងទ្រវែងធ្វើអំពី វល្លិ៍ថ្មឹង វល្លិ៍ត្រមូច ប៉ុន្តែនាពេលបច្ចុប្បន្ននេះគេច្រើនតែធ្វើអំពីខ្សែជ័រតាន់លេខ ១០០-១៥០ (លេខសំគាល់ខ្សែ) ។ ជុចមានរាងស្រដៀង និងស្រោមជើង ដែលមានប្រវែងចាប់ពី ០.៥ ទៅ ១ ម៉ែត្រ ។

**របៀបធ្វើ** យកខ្សែជ័រតាន់លេខ ១០០-១៥០(លេខសំគាល់ខ្សែ) យកមកចាក់ពីក្រោយ ទៅមុខ យកមាត់វាប្រហែលពី ២-៣ តឹក ហើយបណ្តោយវាពី ០,៥-១ ម៉ែត្រ ហើយចាក់យកក្រឡាពី ៤-៦ផឹង គេចាក់បានគ្រប់គ្រាន់ហើយ រួចគេយកខ្សែមកចងមាត់វាសម្រាប់ទុកពេលត្រីចូល ដើម្បីអោយវារួតជាប់នៅពេលដែលត្រីចូលក្នុងជុច ។



**របៀបប្រាស់** ជុចត្រូវបានយកមកដាក់ចូលចន្លោះស្មៅលិចទឹក ត្រែង បបុស រីវារីរុក្ខជាតិដែលមានជម្រៅពី២០សង់ទីម៉ែត្រ ដល់ ១ម៉ែត្រ យើងត្រូវចងភ្ជាប់ជុចទៅនិងរុក្ខជាតិដែលនៅជុំវិញវារឺចងភ្ជាប់ទៅនិងយុថ្កាទំលាក់ទៅបាតក្រោម ។

**ទីកន្លែង៖** ភាគច្រើននៅតាមទន្លេ បឹង ស្រែ និងប្រឡោះអូរ ។

**ពេលវេលាប្រើប្រាស់** នៅរដូវប្រាំង ពីខែ ៣-៥ ។

**ប្រភេទត្រី** មានដូចជាត្រីរ៉ស់ ត្រីឆ្តោ ត្រីអំបូង ត្រីខ្យា ត្រីតានេល ។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ព្រោះអីវារកបានត្រីតិច គេច្រើនប្រើលបវិញព្រោះអាចរកបានត្រីច្រើនជាងជុច ។

## ៣.១.៣ ចាន់



**លក្ខណៈរូប** ជាប្រភេទឧបករណ៍បែបបុរាណនិងជាប្រភេទឧបករណ៍នេសាទតាមបែបលក្ខណៈគ្រួសារ ។ចាន់ជាប្រភេទឧបករណ៍ដែលធ្វើអំពីឫស្សី ឬខ្សែរដ័រ វាមានលក្ខណៈស្រដៀងជុចដែរប៉ុន្តែវាមានក្រឡាធំជាងជុចនិងមានបង្គោលពីរ ។នៅសងខាងនៃមុខចាន់សំរាប់ទប់ និងការធ្វើចលនាអោយសន្ទះបើកបិតបាន ។

**វិធីធ្វើ** ចាន់ជាប្រភេទឧបករណ៍ដែលផលិតចេញមកពីឫស្សី ដំបូងគេយកឫស្សីមួយដើមមកកាត់តម្រូវតាមប្រវែងដែលអ្នកធ្វើចង់បានសម្រាប់ប្រើប្រាស់ក្នុងការនេសាទ ។ បន្ទាប់មកគេយកឫស្សីនោះមកពុះជាចំរៀក១ ។ការពុះនេះគេមិនបានពុះអោយវាដាច់ចេញពីគ្នានៅឡើយទេដោយទុកខាងចុងឫស្សីសម្រាប់ធ្វើជាត្រៀស ។



រួចហើយគេឃ្នងវាអោយមូល និងយកផ្តៅមកក្រង ខាងមុខអោយទៅជារូបរាងជាចាន់ រួចហើយយកទៅវ៉ែន្តដាក់ខាងក្នុងនៃរូបរាងចាន់ ។ បន្ទាប់មកយកខ្សែមកចងតាមវ៉ែន្តតាមប្រឡោះត្រៀស ចាប់ពីគូថរហូតដល់មាត់ចាន់ ហើយការក្រងនេះគេមិនអោយក្រឡាវាលើសពី ៤-៦ ធ្នឹង នោះទេ ។

រួចហើយគេយកឫស្សីតូចពីរដើមប្រវែង ២ ម៉ែត្រ យកធ្វើជាបង្គោលទប់ និងសម្រាប់បង្ហូតសន្ទះមុខនៃចាន់ឡើងចុះ ម្យ៉ាងទៀតបង្គោលនេះត្រូវបានគេចោះជាបង្ហួចសម្រាប់បញ្ចូលគែមសន្ទះសងខាងដើម្បីទប់សន្ទះទ្វាកុំអោយជ្រុះ ។ មុខចាន់មានទំហំប្រហែល ០,៥ ម៉ែត្រ ពីបង្គោលមួយទៅបង្គោលមួយមានកំពស់ ១,២ម៉ែត្រ នៅខាងលើបង្គោលគេធ្វើឫស្សីប្រហោង ដែលគេកាត់ថ្នាំងចេញទាំងសងខាង រួចហើយស៊កឈើទទឹងទៅក្នុងប្រហោងឫស្សី បន្ទាប់មកភ្ជាប់ពីបង្គោលម្ខាងទៅបង្គោលម្ខាងទៀត ។ ឫស្សីដែលកាត់ថ្នាំងចេញយកទៅដាក់នៅចំកណ្តាលឈើភ្ជាប់ធ្វើអោយឫស្សីអាចរមៀល ទៅមកបានហើយកន្លែងនេះគេធ្វើសំរាប់ដាក់រ៉កដើម្បីអោយវាទាក់ ខ្សែទៅសន្ទះនិងខ្សែជុក ។ចំនែកសន្ទះរបស់វាគេធ្វើអំពីឫស្សីបន្ទះតូច១យកមកក្រងឬខ្ទាស់អោយមានប្រវែង១ម៉ែត្រដោយគេទុកប្រវែង២តឹកសំរាប់គេញែកដាក់ដុំថ្ម និងគេចងខ្សែពីមុខទៅក្រោយ រួចយកទៅទាក់នឹងខ្សែជុក ។

**របៀបប្រើប្រាស់** ដំបូងចាន់នេះគឺគេត្រូវដាក់ព្រួលជាមុនសិន រួចគេដំឡើងវាដោយលើកសន្ទះទ្វាចាន់ចងខ្សែ ដាក់គងរូតលើឫស្សីរមៀលនៅលើបង្គោល ហើយ-យកទៅឆ្លកជាមួយខ្សែជុកដើម្បីអោយត្រីចូលប៉ះខ្សែជុកនោះនិងអាចថ្លោះធ្លាក់សន្ទះចុះក្រោមបិទទ្វាសន្ទះជាប់ត្រីបាន។ ចំណែកចាន់ ខ្សែមាន រូបរាងដូចចាន់ឫស្សីដែរប៉ុន្តែខុសត្រង់គេយកខ្សែជ័រយកមកចាក់ជាក្រឡាដូចមងទំហំពី៩-១២ សង់ទីម៉ែត្រ ដោយយកខ្សែលេខ ៥០-៦០ (លេខសំគាល់ខ្សែ)។ ហើយយកឫស្សីមកពុះជាចំរៀក ដើម្បីធ្វើជារាងចាន់ យកខ្សែដែកចាក់រួចជាក្រឡា នោះយកមកស្រោបពីក្រៅចាន់តែម្តងចំណែកសន្ទះ បង្គោលខ្សែជុក គឺធ្វើ ដូចចាន់ ឫស្សីដែរ។

**ទីកន្លែង** ចាន់ត្រូវបានដាក់នៅតាមមាន់ទន្លេដែលមានទឹកហូរ ដាក់ក្នុងទឹកជំរៅចាប់ពី ១ទៅ២ម៉ែត្រ។

**រដូវកាលប្រើប្រាស់** គឺប្រើបានពេញមួយឆ្នាំ ។

**ប្រភេទត្រី** មានដូចជា ត្រីរ៉ស់ ត្រីក្រាយ ត្រីក្អែក ត្រីឆ្តោ ត្រីឆ្កោក។ ចំនួនត្រីដែលចូលចាន់ភាគច្រើនបានតែមួយប៉ុណ្ណោះ រីឯជួនកាលអាចមានពីរ។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិប្រើប្រាស់ឧបករណ៍នេះធម្មតាទេ គ្រាន់តែកាលពីមុនគាត់ធ្វើពីឫស្សី ប៉ុន្តែបច្ចុប្បន្ន គាត់ធ្វើពីខ្សែវិញព្រោះវាងាយស្រួលធ្វើលឿន



ហើយប្រើបានយូរជាងចាន់ដែលធ្វើពីឫស្សី និងងាយស្រួលក្នុងការដឹងជញ្ជូនទៅមកហើយវាដាក់បានត្រីច្រើនជាងទៀត ។

## ៣.២ ឧបករណ៍អន្ទាក់ទ្រូង

### ៣.២.១ សៃយឺន



**លក្ខណៈរូប** ឧបករណ៍សៃយឺនធ្វើឡើងពីឫស្សី វល្លិ៍ឬខ្សែដ៏រ ដែលមានប្រវែងពី ១-១,៥ម៉ែត្រ ។

**វិធីធ្វើ** ដំបូងកាប់ឫស្សីមកកាត់អោយមានប្រវែង ១-១.៥ ម៉ែត្រ ពុះជាចំរៀកតូចៗពី ៥-៦លី ហើយបិតគ្រៀស អោយស្អាត រួចរោលភ្លើងអោយឫស្សីវាស្ងួតដើម្បីកុំអោយសត្វវាស៊ីឬក៏ឆាប់ពុក រួចហើយគេចាប់ក្រងអំពីវល្លិ៍ត្រមូច ឬខ្សែដ៏រ បន្ទាប់មកគេដំឡើងឃ្នង អោយមូលយក ទំហំ ១-១.២០ ម៉ែត្រ រួចហើយ គេបញ្ចូលឃ្នងពី ៤-៥ ហើយគេដាក់បន្ទះសងខាងចងភ្ជាប់ អោយជាប់ដើម្បីអោយវារឹងមាំ ល្អរួចហើយបានគេដាក់បញ្ចូលប្រើស សងខាងអោយជល់មុខគ្នាហើយ



**វិធីប្រើប្រាស់** ដំបូងគេបោះបង្គោលហើយរាយព្រួលអោយមានប្រវែងចាប់ពី ១-២ ម៉ែត្រ រួចហើយទើបគេដាក់សៃយឺនតាមក្រោយដោយដាក់អោយវាបញ្ឈរដែលមានជំរៅទឹក ២-២.៥០ ម៉ែត្រ ។

**រដូវកាលប្រើប្រាស់** ចាប់ពីខែ ឧសភា ដល់ខែធ្នូ ។

**ទីកន្លែងដាក់** ដាក់នៅតាមច្រាំងទន្លេ ឬនៅតាមកោះ ។

**ប្រភេទត្រីនេសាទបាន** ដាក់បានត្រីគ្រប់ប្រភេទ ទាំងត្រីតូច និងធំ ។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ព្រោះវារកបានត្រីតិចតួចណាស់ដោយសារតែត្រីមានការថយចុះ ហើយគាត់បានផ្លាស់ប្តូរមកប្រើប្រាស់ចាន់ និងលបវិញព្រោះអាចរកបានត្រីច្រើនជាង ។

## ៣.២.២ សាប

**លក្ខណៈរូបៈ** សាបជាប្រភេទឧបករណ៍នេសាទដែលមាន ផ្លែជាដែក ដង ធ្វើពីឬស្សី ។ សាបជាប្រភេទឧបករណ៍នេសាទ បែបពាក់កណ្ដាលបូរាណ និងសម័យ

**វិធីធ្វើៈ** ជាដំបូងគឺគេត្រូវពុះឬស្សីជាបន្ទះចាប់ពី ២-៣ ផ្ទាំង និងបណ្ដោយ ឬស្សីប្រវែង ៥ ម៉ែត្រ រួចហើយបោចវល្លិ៍យកមកក្រងធ្វើជាព្រួលផ្ទាំងៗ ដោយអោយ ចន្លោះត្រៀសពីមួយទៅមួយមានទំហំប៉ុនកូនដៃរួចហើយចាប់ដំឡើងជារាងចតុកោណ កែងដែលមានបណ្ដោយពី ១៥-៣០ ម៉ែត្រ និងទទឹងចាប់ពី ៣-៥ ម៉ែត្រ ដែលមានកំពស់ជញ្ជាំងប្រវែង ១-១៥ ម៉ែត្រ និងដោតបង្គោលជាជួរងាយស្រួល-ក្រាលព្រួលពីលើដើម្បីឱ្យត្រីនទៀលចេញបាន ។ វិធីប្រើគឺដំបូងគេបណ្ដែតសាបនៅលើផ្ទៃទឹកបន្ទាប់មកនៅផ្នែកខាងក្រោយទើបគេក្រងបត់ឡើងផុតពីទឹក ។

**របៀបប្រើប្រាស់** ដំបូងយើងត្រូវដាក់ព្រួល ហើយយកឬស្សីប្រវែងប្រហែល ជា១០ ម ធ្វើជាដៃបន្ទាប់មកត្រីវានិងហែលចូលមកក្នុងព្រួល ដូចនេះយើងអាចចាប់វា បានហើយ ។

**ពេលវេលាប្រើប្រាស់** ចាប់ពីខែ វិច្ឆិកា ដល់ខែធ្នូ ។

**ទីកន្លែងដាក់** នៅតាមដងអូរ ។

**ប្រភេទត្រីដែលនេសាទបាន** មានត្រីគ្រប់ប្រភេទមិនថាត្រីធំរឺក៏ត្រីតូចទេ ។

**អ្នកប្រើប្រាស់** ភាគច្រើនជាមនុស្សប្រុស ។



**ការវិវត្តន៍** បច្ចុប្បន្ននេះប្រជាជននៅក្នុងភូមិមិនសូវប្រើប្រាស់ទេ ព្រោះរក ត្រីបានតិច ដោយសារតែត្រីមានការថយចុះ ពួកគាត់បានប្រើប្រាស់ មង សំណាញ់ វិញព្រោះអាចរកត្រីបានច្រើនជាង ។

## ៣.២.៣ ទ្រូ



**លក្ខណៈរូប** ទ្រូមានរាងមូលទ្រវែងមានមុខកាត់ចាប់ពី ៣-៤ តឹក ប្រវែង ១-១.៥ ម៉ែតហើយប្រវែងពីត្រៀសមួយទៅត្រៀសមួយមានប្រវែង ០.៥- ១ស.ម។

**វិធីធ្វើ** មុនពេលធ្វើឧបករណ៍ទ្រូនេះដំបូងយើងត្រូវជ្រើសរើសយកឬស្សីពី ២-៣ ដើមមកកាត់ជាកង់ៗ បន្ទាប់មកយកឬស្សីដែលបានកាត់នោះទៅពុះជ្រៀក ជាចំរៀកតូចៗ និងបិតអោយស្អាតដែលត្រៀសនិមួយៗមានទំហំចាប់ពី ៤-៥ លី។ បន្ទាប់ពីការ បិតត្រៀសទាំងនោះគ្រប់តាមចំនួនដែលចង់បានរួចហើយក៏យកទៅរោលភ្លើងអោយស្ងួតជាតិទឹក។ ចំពោះការក្រងត្រៀសអោយក្លាយជាផ្ទាំងព្រួលវិញគេ អាចយកទៅក្រងជាមួយនឹងវល្លិ៍ត្រី វល្លិអន្ទង់ វល្លិ៍ធ្លកនៅពេលដែលក្រងជាព្រួល រួចហើយគេកាប់វល្លិ៍ក្រវ៉ាន់ យកមកព័ទ្ធដោយដាក់នៅខាងក្នុងព្រួលអោយមានរាងមូល បន្ទាប់មកពុះឬស្សី ជាបន្ទះយកមកអបនៅផ្នែកខាងក្រៅដើម្បីអោយវាមានសភាពរឹងមាំល្អ។



**វិធីប្រើប្រាស់** ទ្រូដំបូងគេយកព្រួលមកឃាំងអូរឬប្រឡាយ បន្ទាប់មកគេកាត់ព្រួល អោយមានប្រឡោះទំហំប៉ុននឹងទ្រូរួចហើយដាក់ទ្រូចូលទៅក្នុង ប្រឡោះដែលបានកាត់រួចជាស្រេច។ បន្ទាប់មកទៀតគេត្រូវយកចំបើងរឺក៏យកស្មៅទៅគ្របពីលើទ្រូដើម្បីបញ្ឆោតត្រី។

**ទីកន្លែង** ភាគច្រើនដាក់តាមប្រឡាយ តាមអូ ស្រែដែលមានទឹកលិចភ្លឺ។

**រដូវកាលប្រើប្រាស់** គឺគេប្រើបានពេញមួយឆ្នាំ។ ជាពិសេស ចាប់ពី ខែសីហា ដល់ ខែកញ្ញា គឺគេច្រើនតែដាក់ទ្រូ អោយប្រើសរបស់វាចុះទៅខាងក្រោម ដើម្បីអោយត្រីចូលព្រោះត្រីវាចរាចរណ៍នៅខាងក្រោមទ្រូ និងចាប់ពី ខែតុលា ដល់ ខែវិច្ឆិកា គេដាក់ប្រើស ឡើងមកលើវិញ។

**ប្រភេទត្រី** ដែលដាក់បានមានដូចជាត្រីរ៉ស់ ត្រីអណ្តែង ត្រីកន្ត្រប់ ត្រីចង្វាត្រីឆ្ពិន ក្តាម ពស់ កំពិស អន្ទង់....។

**អ្នកប្រើប្រាស់** ទាំងចាស់ ទាំងក្មេង ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិប្រើប្រាស់ច្រើន គ្រាន់តែកាលពីមុនពួកគាត់ច្រើនតែយកទៅដាក់នៅតាមបុង ក៏ប៉ុន្តែបច្ចុប្បន្នដោយសារតែទឹកអត់សូវស្រេក ពួកគាត់ក៏យកទៅដាក់នៅតាមអូរវិញ ។ បើដាក់នៅតាមបុងគឺគាត់ដាក់បានត្រីច្រើនជាងដាក់នៅអូរ ។

### ៣.២.៤ លបប្រើសពីរ



**លក្ខណៈរូប** លបជាប្រភេទឧបករណ៍នេសាទដែលប្រជាជននៅ ភូមិកោះខនឌិននិយម ប្រើប្រាស់ក្នុងការ នេសាទ។ លបមានពីរប្រភេទ គឺលបធ្វើពីឫស្សីក្រងដោយវល្លិ៍ ឬខ្សែប៉ៃនិងលបធ្វើពីខ្សែជ័រ ដែលទិញនៅផ្សារយកមកចាក់ជាក្រឡាតាមទំហំដែលអ្នកចង់បានដោយប្រើឫស្សីជាឃ្នង់។ លបដែលធ្វើពីឫស្សី មានរាងមូលទ្រវែងទំហំមុខកាត់មានប្រវែងចាប់ពី៦០-១៥០ ស.ម ដែល មានបណ្ដោយប្រវែង ២-៣ម៉ែត្រ ដោយយើងកំណត់យកទំហំទ្រាស់ប៉ុនចង្កឹះឬប៉ុនកូនដៃមានចំនួនទ្រាស់តាមទំហំ ១.៥ ម៉ែត្រ អស់ចំនួនត្រៀស ៨៩ ប្រវែង ៣ហាត់មួយចាប់ក្រឡាលប។ ពីត្រៀសមួយទៅត្រៀសមួយ ទៀតមានប្រវែង ៣ ស.ម។ ដោយប្រើឃ្នង់កងអស់ចំនួន ៥កង់ ដែលធ្វើពីឫស្សី ឬវល្លិ៍ក្រវ៉ាន់ ក្រងដោយខ្សែប៉ៃ ឬវល្លិ៍ ដោយយើងប្រើប្រើសចំនួនពីរ។

**វិធីធ្វើ** លបមុនដំបូងគេត្រូវទៅកាប់ឫស្សីចំនួន ២-៣ដើម ដោយប្រើឫស្សីស្រុក យកមកកាត់ជាកង់ៗ រួចពុះជាចំរៀកតូចៗហើយបិតអោយមូលស្អាតទំហំពី ៦-



៨លី រួចយកទៅរោលភ្លើងអោយស្ងួតងាយស្រួលក្នុងការក្រងដើម្បីកុំឱ្យវាវលុងរីសត្វខ្មួតស៊ី។ ក្នុងការក្រងនេះយើងប្រើវល្លិ៍ត្រី ឬខ្សែប៉ៃរួចយកវល្លិ៍ក្រវ៉ាន់ ឬវល្លិ៍ធ្មេញត្រី ឬក៏ឫស្សី យកមកធ្វើជាឃ្នង់ប្រហែលជា ៤-៥ ឃ្នង់។ រួចធ្វើប្រើសដាក់អមដោយយើងយកផ្ដៅ រឺខ្សែជ័រមកចង។ រួចហើយយើងចាប់ផ្ដើមធ្វើសន្ទះបិតគូទនិងធ្វើទ្វារតែម្ដង ។រីឯគូទវាគេកាច់ជារាងកញ្ចោងដើម្បីអោយត្រីដកដង្ហើមបាន។

**វិធីប្រើប្រាស់** យើងប្រើព្រួលពីរបន្ទះសំរាប់ដាក់លប ហើយមួយបន្ទះប្រវែង ២-៣ ម៉ែត្រ ដាក់អែបរាងឈម ដើម្បីបញ្ឆោតត្រីអោយវាចូលលប ចំនែកមុខលបទាំងសងខាងគេមានបោះបង្គោលបីបន្ទាប់មកគេចាប់ផ្ដើមចងខ្សែកៀបចំ កណ្ដាលលបនិងគូទរបស់វាដើម្បីកុំអោយវារេទៅតាមទឹកហូរ ។

**ទីកន្លែង** ភាគច្រើនគេដាក់តាមមាត់ច្រាំងទន្លេ តាមកោះតូច ធំ និងតាមប្រឡោះ ដើមរៃ ។

**រដូវកាលប្រើប្រាស់** ភាគច្រើនប្រជាជនតែងតែដាក់លបបានពេញមួយឆ្នាំ តែបើខែមិនា ដល់ខែមិថុនា គឺពួកគាត់ មិនអាចដាក់លបបានទេព្រោះនៅតាមទន្លេគឺចាប់ផ្ដើមកើតមានស្លែច្រើន ធ្វើអោយពិបាកក្នុងការដាក់លបនេះ តែបើដាក់តាមបឹងអូរ គឺអាចដាក់បានព្រោះវាមិនកើតមានស្លែដូចនៅតាមទន្លេនោះទេ។

**ប្រភេទត្រីដែលនេសាទបាន** មានដូចជាត្រីឆ្ពោ ត្រីក្រាយ ត្រីឆ្ពិន ត្រីក្អែក ត្រីរ៉ស់ ត្រីត្រនេល ត្រីខ្សា ត្រីឆ្ពោ ត្រីក្អែក ត្រីរមាស ត្រីខ្លា ....។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍៖** ប្រជាជននៅក្នុងភូមិប្រើប្រាស់លបនេះតាំងពីដូនតារបស់គាត់មក ហើយសព្វថ្ងៃនៅតែពេញនិយមប្រើប្រាស់ ។

# ៣.២.៥ លាន់



**លក្ខណៈរូប** លាន់ជាប្រភេទឧបករណ៏នេសាទបែបបុរាណដែលធ្វើឡើងពីឫស្សី ដែលមានប្រវែង ២ម៉ែត្រ និងមុខកាត់ប្រវែង ១តឹក ។

**វិធីធ្វើ** ដំបូងគេកាប់ឫស្សីស្រុក ឬឫស្សីព្រៃទំហំប៉ុនភ្លៅ ហើយយកមកកាត់ជាកង់ៗប្រវែង ១-២ ម៉ែត្រ ហើយយកភ្លើងរោលកុំអោយវាបែក បន្ទាប់មកយកទៅចាក់ទំលុះថ្នាំង ប៉ុន្តែក្នុងការចាក់នេះគេចាក់មិនអោយធ្លុះដាច់ដល់ថ្នាំងខាងគូថនោះទេ ក្រោយពេលដែលចាក់ទំលុះថ្នាំងរួចហើយគេចាប់ផ្តើមចោះជាប្រហោងខ្យល់ទំហំប៉ុនបិចដែលមានប្រវែង ២តឹក រួចហើយគេចាប់ផ្តើមធ្វើប្រើសនៅមាត់បំពង់ឫស្សី ដោយ បិតឫស្សីអោយស្តើងធ្វើជាត្រៀស ហើយបិតយ៉ាងណាអោយចុងត្រៀសមានរាងសំប៉ែតស្រួច ហើយត្រៀសនិមួយៗមានទំហំ ៥លី ។



បន្ទាប់មកគេចោះប្រហោងទំលុះពីខាងលើនៃលាន់ ដើម្បីភ្ជាប់ប្រើសអោយជាប់នឹងបំពង់សំរាប់ដោតជាប់ទៅនឹងដីផងដែរ ។

**វិធីប្រើប្រាស់** ដំបូងគេយកខ្យង ក្តាម មកវាយបំបែកសំបក រួចយកវាទៅដាក់ក្នុងលាន់ បន្ទាប់មកគេយកលាន់នោះទៅកប់នៅក្នុងដីភក់ៗ ហើយពិសេសមួយទៀតនោះគឺគេត្រូវយកម្ទេសមកលាបជាមួយនុយដើម្បីអោយអន្ទង់ចូលបានច្រើន ។

**រដូវកាលប្រើប្រាស់** ពីខែ តុលា-មករា ។

**ទីកន្លែងដាក់** នៅតាមបឹង តាមភ្លឺស្រែ ត្រពាំង ប្រឡាយ ទន្លេ អូរ ។

**ប្រភេទត្រីដែលនេសាទបាន** គេដាក់លាន់នេះគឺដើម្បីយកអន្ទង់ និងពស់ ។

**អ្នកប្រើប្រាស់** អាចប្រើបានទាំងប្រុស និងស្ត្រី ។

**ការវិវត្តន៍** បច្ចុប្បន្នប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ពីព្រោះប្រជាពលរដ្ឋមិនសូវចេះធ្វើ ហើយដាក់បានតែអន្ទង់ និងពស់តែប៉ុណ្ណោះ ។

## ៣.២.៦ តុំ



**លក្ខណៈរូប** តុំជាប្រភេទឧបករណ៏បែបបូរាណដែលមាត់របស់វាមានរាងមូលដូចជាកក្អមរឺឆ្នាំងដីហើយចំនែកគូទមានរាងប៉ោងដែលមានទំហំ ២.៥ តឹក និងកំពស់របស់វាមានប្រវែង៥តឹក។

**វិធីធ្វើ** ដំបូងឡើងយើងត្រូវទៅកាប់ឬស្សី យកមកពុះជាចំរៀកតូចៗ រួចបិតត្រៀសអោយតូចៗមានរាងសំប៉ែតសំរាប់ធ្វើគ្រោងនៃតុំ បន្ទាប់មកចាប់ត្បាញចេញពីគូទរបស់វាដោយអោយវារួមបន្តិច ហើយមកដល់ខ្លួនរបស់វាគេធ្វើអោយមានរាងប៉ោងមកដល់កគេធ្វើអោយមានរាងជាកក្អម ដល់ពេលធ្វើរួចហើយគេចាប់ផ្ដើមចោះរន្ធតុំសំរាប់ដាក់ប្រើសដោយយើងប្រើប្រើសម្ខាងចំនួន៦-៧ត្រៀស។ ហើយប្រើសនេះ



**របៀបប្រើប្រាស់** ចំនែកនៅខាងមាត់តុំគេកាត់បន្ទះក្ដាអោយមូលប៉ុនមាត់តុំដើម្បីគ្របមាត់វាកុំអោយត្រីវាលោតចេញ។ ក្នុងការប្រើប្រាស់គឺគេយកទៅដាក់នៅក្នុងទឹកដែលមានជំរៅចាប់ពី ១-១.៥0ម៉ែត្រ និងមានបង្គោលពីរនៅសងខាងសំរាប់ចងទប់តុំដោយមិនអោយក្កិតតុំដល់ដីឡើយ។

**ទីកន្លែង** គេយកទៅដាក់នៅតាមបឹង អូរ តាមច្រាំងទន្លេដោយគេដាក់នុយនៅក្នុងនោះដូចជា កន្ទក់ កណ្ដៀរជាដើម។

**រដូវកាល** គេដាក់ពេញ មួយឆ្នាំ។

**ប្រភេទត្រី** មានដូចជា ត្រីរៀល ត្រីស្លឹកឫស្សី ត្រីចង្វាមូល។

**អ្នកប្រើប្រាស់**ទាំងចាស់ ទាំងក្មេង ។

**ការវិវត្តន៏** បច្ចុប្បន្នប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ព្រោះរកត្រីបានតិចហើយសុទ្ធតែជាប្រភេទត្រីតូចៗទៀត។ ប្រជាពលរដ្ឋចាប់ផ្ដើមផ្លាស់ប្ដូរមកប្រើប្រាស់មង និងសំណាញ់វិញព្រោះអាចរកត្រីបានច្រើនជាងតុំ ។

## ២.៣.៧ ប៉ោង

**លក្ខណៈរូប** ប៉ោងមានរាងស្តួចលើហើយមាត់លើវារីកធំ ដែលមានកំពស់ពី ១,២ ម៉ែត្រ ធ្វើពីឫស្សី ។

**វិធីធ្វើ** ដំបូងគេត្រូវកាប់ឫស្សីមកពុះជាចំរៀកតូចៗរួចបិទវាអោយស្តើង ទំហំប្រហែល៥លីរួចយកទៅត្បាញជាប្រើសមុនទើបបានគេពត់វាធ្វើជាតួខ្លួនដែលមាន ទំហំចាប់ពី ៥-៦ តឹក និងមានរាងស្តួចលើហើយមាត់លើរីកមានទំហំ ១,២ តឹក ។

**វិធីប្រើប្រាស់** មុននឹងយកទៅដាក់ដំបូងត្រូវដាក់នុយដែលធ្វើពីបាយបុក លាយជាមួយកន្ទក់អោយល្អិតរួចយកទៅលាបនៅលើ មាត់ប្រើសដើម្បីអោយត្រីចូល ស៊ី ។ តួប៉ោងគេដាក់ពន្លិចចូលក្នុងទឹករួចយកអង្កាមមកដាក់ចូលក្នុងប៉ោងអោយត្រី ចូលស៊ីកាន់តែច្រើន ។បន្ទាប់មកគេយកឫស្សីដោតជាបង្គោលមួយអោយជាប់នឹងដី បើ នៅកន្លែងថ្មត្រូវដាក់បង្គោលចំនួនបីដើម្បីកុំអោយវារលំ ។ គេយកប៉ោងចងនឹងបង្គោល កំពស់ពីបាតដីប្រហែល ៥-៦ តឹក ហើយជំរៅទឹកចាប់ពី ១ ម៉ែត្រទៅ ១.២០ ម៉ែត្រ ដោយដាក់យ៉ាងណាអោយមាត់ប៉ោងផុតពីទឹកកំពស់២-៣តឹក ។



**ទីកន្លែងនេសាទ** នៅតាមព្រៃលិចទឹក តាមចន្លោះថ្មដែលមានទឹកនឹង មិន ហូរ ។

**រដូវកាលនេសាទ** នៅខែមករា ដល់ខែឧសភា ។

**ប្រភេទត្រីដែលនេសាទបាន** មាន ត្រីរៀល ត្រីកញ្ជ្រូក ត្រីស្លឹកឫស្សី ត្រីឆ្កិន និងត្រីកំពត ។

**អ្នកប្រើប្រាស់** ទាំងក្មេង និងមនុស្សចាស់ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើទេ ព្រោះរកបានត្រីតិច ពួកគាត់ ផ្លាស់ប្តូរមកប្រើមងនិងសំណាញ់វិញ ព្រោះអាចរកត្រីបានច្រើនជាង ។

## ជំពូក៤: ឧបករណ៍មង

### ៤.១ មងពន្លិច



**លក្ខណៈរូប**ជាប្រភេទឧបករណ៍នេសាទបែបពាក់កណ្តាលបុរាណ និងសម័យ ។ មងនេះគេធ្វើពីខ្សែជ័រតានីរឺខ្សែនីឡុង ។ មងនេះគេប្រើចាប់ពីក្រឡា ០.៧-១៣ ស.ម មងនេះគេធ្វើរនងពីរផ្នែកខាងលើ និងផ្នែកខាងក្រោម ផ្នែកខាងឡើគេហៅថារនងលើ និងផ្នែកខាងក្រោមគេហៅរនងក្រោមខុសពីមងធម្មតា ។ មងធម្មតាមានរនងលើ និង-មានសំណរជើងក្រោម ។

**វិធីធ្វើ** មងក្រឡាធំគឺមានទំហំចាប់ពី ១០-១៣ ស.ម និងប្រើខ្សែលេខ ៨០-២០០ (លេខសំគាល់ខ្សែ) ហើយចំពោះមងក្រឡា តូចមានទំហំក្រឡាចាប់ពី ០.៧-១០ ស.ម និងខ្សែលេខ ១២០-១៥០ (លេខសំគាល់ខ្សែ) ចំនែកចន្លោះតាមង ក្រឡាធំគឺមានទំហំចាប់ពី៩-១០ ស.ម ហើយចន្លោះពីមួយទៅមួយគឺរោប់ក្រឡាមង យកតែម្តងចាប់ពីក្រឡា ២០-២៥ក្រឡា



គេចងភ្ជាប់គ្នាទើបបានកុំអោយរូត រីឯរនងក្រោមគឺដូចគ្នា ដែរ ។ ចំពោះមងក្រឡាតូច គឺគេធ្វើដូចតែមងក្រឡាធំដែរប៉ុន្តែគ្រាន់តែថាខុសគ្នាត្រង់ ចន្លោះនៃមងដែលត្រូ-វគេយកក្រឡាពីមួយទៅមួយចាប់ពី ០.៥-១០ (សង់ទីម៉ែត្រ) ហើយត្រាចន្លោះន-នងពី ២៥-៣០ ក្រឡាហើយរនងគេធ្វើដូចជាមងក្រឡាធំដែរ ។

**វិធីប្រើប្រាស់** ផ្នែកខាងលើគេចងភាប់ទៅនឹងមែកឈើនៅមាត់ទន្លេនៅ កណ្តាលទឹកគេមានធ្វើខ្សែឆ្លងសំរាប់ចងចុងរនងម្ខាងទៀត ចំណែកជើងក្រោមគេចង ដុំថ្មទម្ងន់ពី ១-១.៥ គីឡូក្រាមថ្មនេះគេចងសំរាប់ពន្លិចរនងក្រោមអោយសាច់មងលិច ចុះទៅក្នុងទឹកម្យ៉ាង ទៀតដើម្បីអោយសាច់មងលាតត្រដាង ដើម្បីអោយត្រីធ្វើដំណើរ ទៅអាចជាប់មង ចំនែកចន្លោះដែលត្រូវចងដុំថ្មគឺមានចំងាយពីគ្នាចាប់ពីមួយទៅមួយ ប្រវែង១៥-២០ ម៉ែត្រ ។ ហើយផ្នែកននងលើគេយកឫស្សីល្អកាត់ជាកង់ៗតាមចន្លោះ ថ្នាំងជើងជាកំសួល សំរាប់លាតសាច់មងតាមចន្លោះថ្មដែលចងផ្នែកខាងក្រោមនៃខ្សែ ។

**ទីកន្លែងប្រើប្រាស់នេសាទ** តាមទន្លេ តាមទឹករ៉ឹន អន្លង់ និងប៉ែរ ។

**រដូវកាលនេសាទ** ពេញ១ឆ្នាំ ។

**ប្រភេទត្រីដែលដាក់បាន** ត្រីប៉ាវ៉ា កែ ក្អែក ឆ្ដោក ខ្លា ប៉ាសុីអុី... ។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិនៅតែពេញនិយមក្នុងការប្រើប្រាស់ ព្រោះ ក្នុង១ថ្ងៃក៏អាចរកបានពី១ទៅ៣គីឡូក្រាមដែរ ។

## ៤.២ មងបណ្តែត



**លក្ខណះរូប** ប្រជាជនក្នុងភូមិមិនបានដឹងពីប្រវត្តនៃការកកើតមងបណ្តែតនេះទេ។ វិធីសាស្ត្រក្នុងការធ្វើមងបណ្តែតនេះគឺនៅមានតិចតួចណាស់នៅតាមគ្រួសារដែលនៅរក្សាប្រពៃណីចាក់ធ្វើមងបណ្តែត ព្រោះបច្ចុប្បន្ននេះការដាក់លក់មងនៅលើទីផ្សារគឺមានច្រើនណាស់ ដូច្នេះដោយគ្រាន់តែពួកគាត់ទិញយកមកពីផ្សារហើយត្រារនងលើក្រោមប្រហែលជា ២-៣ថ្ងៃរួចជាស្រេច ដោយមិនចាំបាច់ចំណាយពេលយូរក្នុងការធ្វើមងបណ្តែតនេះ។

**វិធីធ្វើ** ប្រភេទឧបករណ៏នេះគឺគេច្រើនប្រើរនងលើនិងរនងក្រោម។ ចំពោះរនងលើគេច្រើនដាក់កំសួល ដើម្បីអោយវាអណ្តែតងាយស្រួលយើងមើលឃើញ និងរនងខាងក្រោមគេត្រូវដាក់កងដែលធ្វើអំពីដែក រឺសំណដែលមាន ទំហំពី ៥-៨ លី និងពត់ជារង្វង់មូលប្រហែលជា ២-៣ តឹក ។ មងប្រភេទនេះភាគច្រើនគេប្រើដែលមាន



ប្រវែងចាប់ពី ៧0-៨0 ម៉ែត្រ និងមានជំរៅប្រហែលជា ៥-៧ម៉ែត្រ។

**វិធីប្រើប្រាស់** គេត្រូវវាយមងទៅក្នុងទឹកដោយយកចុងម្ខាងចងជាប់ទៅ នឹងកានរួចហើយព្រលែងចោលនិងម្ខាងទៀតចងជាប់ទៅនឹងទូក ហើយនៅពេលដែលទៅជិតដល់គោលដៅ ក៏ទាញឡើងមកលើទូកដើម្បីដោះយកត្រី ។

**រដូវកាលប្រើប្រាស់** នៅពេលដែលទឹកចាប់ផ្តើមឡើងគឺចាប់ពីខែមេសា ដល់ខែសីហា និងនៅរដូវសំរកគេអាចបណ្តែតបានចាប់ពីខែ តុលា ដល់ខែវិច្ឆិកា។

**ប្រភេទត្រី** មានដូចជាត្រីពោ ត្រីឆ្ពិន ត្រីប៉ាវ៉ា ត្រីប៉ាសុីអុី ត្រីព្រួល ត្រីក្អែក ត្រីកេះជំរៅ ត្រីកែ ត្រីឆ្កោក ត្រីត្រសក់.....។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៏** ប្រជាជននៅក្នុងភូមិប្រើប្រាស់ច្រើន ហើយភាគច្រើនគឺពួកគាត់ធ្វើដោយខ្លួនឯង ពីព្រោះវាងាយស្រួលធ្វើ ហើយនៅចន្លោះពីខែ មេសា ដល់ខែឧសភាគឺពួកគាត់អាចរកត្រីបានច្រើនអាចពី ១0ទៅ ៣0គីឡូក្រាមក្នុង១ថ្ងៃ ។

## ៤.៣ មងត្រីរៀល



**លក្ខណៈរូប**ប្រជាជននៅភូមិកោះខនឌិនភាគច្រើនគេនិយមប្រើមងត្រីរៀលណាស់ តែឥឡូវពួកគាត់មិនសូវនិយមចាក់ទៀតទេព្រោះភាគច្រើនគាត់ច្រើនទិញយកសាច់មងមកពីផ្សារហើយយកមកត្រារនង ដោយភាគច្រើនគេចាប់ទាញសាច់មងវាស់យកពី ៣-៤តឹក រួចគេចងជារនង និងនៅជើងក្រោមគេមានដាក់សំណ ដើម្បីអោយសាច់មងវាលាតធឹងល្អ ។ចំពោះជំរៅមងនេះមានប្រវែងពី១-១.៥ម៉ែត្រ។ ជួនកាលគេទិញយកមក ពីផ្សារតែម្តង។



**វិធីធ្វើ** ទិញសាច់មងមកពីផ្សារហើយចងរនង និងដាក់ជើងសំណ ។

**វិធីប្រើប្រាស់** ភាគច្រើនដាក់នៅពេលយប់ និងដាក់បណ្តោយទឹក ។

**រដូវកាលប្រើប្រាស់** បានគ្រប់ខែ តែត្រីត្រូវខ្លាំងពីខែមិនា ដល់ខែកក្កដា ។

**ទីកន្លែងប្រើប្រាស់** អូ និងទន្លេ ភាគច្រើនគេដាក់នៅពេលយប់ ។

**ប្រភេទត្រីដាក់បាន** ត្រីរៀល ត្រីអាចម៍កុក និយាយរួមបានត្រីគ្រប់ប្រភេទអោយតែតូចៗ ។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិនៅតែពេញនិយមក្នុងការប្រើប្រាស់មងនេះជាពិសេសនៅរដូវដែលសំបូរគាត់អាចដាក់បានត្រីរៀលចាប់ពី១០ ទៅ៣០គីឡូក្រាមក្នុង១យប់ ។

# ជំពូក ៥: ឧបករណ៍ត្រួចត្រប

## ៥.១ ឧបករណ៍ត្រួចត្រប

៥.១.១ អង្រុត



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណះរូប** ធ្វើពីប្ញស្សី ផ្តៅ ដែកលួស មានរាងមូលអង្កត់ផ្ចិតផ្នែកខាងលើប្រវែង ១ តឹក ផ្នែកខាងក្រោមប្រវែង ១៥ តឹក មានកំពស់ ៥-៦តឹក។

**វិធីធ្វើ:** ដំបូងគេកាប់ប្ញស្សីយកមកកាត់ប្រវែងពី ៥-៦ តឹក ហើយពុះជាចំរៀកពី ៦-៧ លី ហើយបិតអោយមូលស្អាត ហើយយកវាទៅចាក់ចេញជាក្បាលអោយមានរាងមូលដោយយកទំហំពី១-១៥តឹក ហើយក្បាលវាគេយកឈើមកគ្បៀលឱ្យប្រហោង ហើយគេលាក់កវាដើម្បីឱ្យងាយស្រួលដាក់បញ្ចូលទៅនឹងអង្រុតរួចគេដំឡើងឃ្នងវាដើម្បីអោយរីកក្រោមនិងនៅពាក់កណ្តាលគេយក ប្ញស្សីយកមកដាក់អោយជាប់នឹង នៅជើងក្រោមគេដាក់ឃ្នងមួយទៀត។ គេយកដែកលួសមួយមកចងអោយជាប់កុំអោយឃ្នងរំកិលចុះឡើង។ ជើងក្រោមទំហំពី ៥-៦ តឹកធ្វើឱ្យមូល។



**វិធីប្រើប្រាស់** យើងត្រូវរុតព្រៀវៗហើយបើប៉ះត្រីនោះយើងលូកយកទៅតែម្តង។

**រដូវកាលប្រើប្រាស់** ចាប់ពីខែ វិច្ឆិកា ដល់ខែកក្កដា

**ទីកន្លែងនេសាទ** ដែលគេនេសាទនៅតាម បឹង ទន្លេ អូរត្រពាំង។

**ប្រភេទត្រីដែលនេសាទបាន** ត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ ត្រីកន្ធ ...។

**អ្នកប្រើប្រាស់** ទាំងក្មេងទាំងចាស់ ។

**ការវិវត្តន៍** កាលពីមុនប្រជាពលរដ្ឋធ្វើអង្រុតដោយយកវល្លិ៍មងចង ក៏ប៉ុន្តែសំរាប់បច្ចុប្បន្នគឺឈប់ប្រើវល្លិ៍ទៀតហើយដោយគាត់បានយកខ្សែលួស រឺក៏ខ្សែជ័រយកមកចងវិញ ។

## ៥.២ ឧបករណ៍សំណាញ់

### ៥.២.១ សំណាញ់




**លក្ខណៈរូប** សំណាញ់មានរាងដូចជាសាជី ហើយប្រជាជននៅក្នុងភូមិចូលចិត្តប្រើសំណាញ់២ ប្រភេទគឺ សំណាញ់ព្រយុង និងសំណាញ់ឡាក់ ។

**វិធីធ្វើ** ដំបូងយើងទិញខ្សែនីឡុងពីផ្សារ ហើយយកមកចាក់អោយចេញជាក្រឡា ។ ក្រឡារបស់សំណាញ់ធំមានទំហំ ៥-៩ (សង់ទីម៉ែត្រ) និងក្រឡាតូចមានទំហំ ១.៥-២.៥ (សង់ទីម៉ែត្រ) ។ កំពស់សំណាញ់មានប្រវែងពី ៣-៩ (សង់ទីម៉ែត្រ) ។ ហើយទំហំជុំវិញជើងព្រយុងមានប្រវែងជាមធ្យម៨ម៉ែត្រ និងមានចងព្រយុងដែលធ្វើពីសំណដើម្បីឱ្យប្រទាញសាច់សំណាញ់ ។

**វិធីប្រើប្រាស់** ចំពោះរបៀបប្រើប្រាស់សំណាញ់នេះវិញគេត្រូវចាប់សំណាញ់ហើយជ្រុំជើងអោយស្មើ និងចាប់ត្រកងខ្សែទាញនឹងសាច់សំណាញ់ដោយទុកអោយសាច់សំណាញ់សល់ចុះក្រោមប្រហែល ៣ហាត់ រួចលើកដាក់លើស្មា (ការដាក់លើកែងដៃនេះចង់ដាក់ខាងណាក៏បានដែរទៅតាមជំនាញរបស់មនុស្សម្នាក់ៗ) ។



បន្ទាប់មកគេចាប់សាច់សំណាញ់នោះគ្រវែងបង្វិលបោះចូលទៅក្នុងទឹក ដើម្បីអោយសាច់សំណាញ់វាបែក ។

**ទីកន្លែង** ភាគច្រើន គេទៅបង់នៅតាមទំនប់ ហាតខ្សាច់ អូរ និងក្បែរកោះ ឬច្រាំងទន្លេ ។

**រដូវកាលប្រើប្រាស់**គ្រប់រដូវកាល ។

**ប្រភេទត្រី** សំណាញ់ក្រឡាតូចគេអាចបង់បានត្រីចំរុះ តែតូចៗ ឯសំណាញ់ក្រឡាធំៗ ជាទូទៅ បង់បាន ត្រី ឆ្ពិន ត្រីកែ្អក ត្រីប៉ាវ៉ា ត្រីឆ្លាំង ត្រីក្របី ត្រីឆ្តោ....។

**អ្នកប្រើប្រាស់** មនុស្សពេញវ័យ ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិប្រើប្រាស់ច្រើន ព្រោះវាងាយស្រួលធ្វើ និងមានលក់នៅផ្សារស្រាប់ មិនត្រឹមតែប៉ុណ្ណោះក៏អាចជួយអោយពួកគាត់រកត្រីបានច្រើនសម្រាប់ហូប និងពេលខ្លះអាចយកទៅលក់ទៀតផង ។

## ជំពូក ៦: ឧបករណ៍ធ្វើអោយត្រីផ្គុំ

### ៦.១ ឈ្នាងត្រាំ



**លក្ខណៈរូប** ឧបករណ៍នេះធ្វើឡើងពីឫស្សី ផ្តៅ ដែលមានជាបីជ្រុង ប៉ោងផ្នែកចំហៀង និងមានថ្នក់។ ឈ្នាងត្រាំមានបណ្តោយប្រវែង ២-៣ម៉ែត្រ កំពស់ប្រហែល ១,៥ម៉ែត្រ និងមុខកាត់ប្រវែង ១,៥-២ម៉ែត្រ។ ព្រោះតែវាពិបាកក្នុងការនេសាទដោយពេលទៅលើកត្រីម្តងៗត្រូវមានគ្នាពី២-៣នាក់ សំរាប់អូសឈ្នាងអោយឡើងមកលើគោកព្រោះវាធំហើយធ្ងន់។

**វិធីធ្វើ** ដំបូងគេកាប់ឫស្សីប្រហែលជា ៣-៥ ដើមហើយយកមកពុះជាចំរៀកតូចៗរួចបិត ឫស្សីអោយមានរាងស្តើង បន្ទាប់មកត្បាញជាប់គ្នា ដោយត្បាញលើកមួយសង្កត់មួយរួចហើយយើងភ្ជាប់មាត់ឈ្នាងជុំវិញដោយចំរៀកផ្តៅតូចៗ និងមុខរបស់វាគេត្រូវចងឈើជាទទឹងដើម្បីឱ្យងាយស្រួល ក្នុងការអូសឈ្នាងឡើងមកលើគោក។ ចំនែកឯមាត់ឈ្នាងគេពុះឫស្សីពីរបន្ទះសំរាប់អមមាត់ឈ្នាង ហើយក្តាប់អោយជាប់ដើម្បីកុំអោយវាទន់ និងងាយស្រួលអូសឡើងលើគោក និងនៅបាតឈ្នាងគេមានចងដាក់ឫស្សីពីរដើម្បីកុំអោយឈ្នាងវារេ និងសឹកបាតឈ្នាង បន្ទាប់មកគេត្រូវចោះរន្ធនៅត្រង់គូទដែលទទឹងមានប្រវែង ៥0 សង់ទីម៉ែត្រ និងបណ្តោយ ២0សង់ទីម៉ែត្រ។



មុននឹងយកឈ្នាងទៅដាក់ ដំបូងគេត្រូវកាប់សម្រាស់កូនឈើដូចជា ដើមធ្នារ ដើមលាចផ្ទុះ ដើមទ្រនំបង្គួយយកទៅហាលឱ្យស្ងួត រួចចងជាបាច់ហើយយកទៅច្រុះក្នុងឈ្នាងដែលបានដាក់ត្រាំនៅក្នុងទន្លេជាការស្រេច។
ចំពោះរយៈពេលធ្វើឈ្នាងត្រាំ១គឺគេចំណាយពេលអស់ ពី ៣-៥ ថ្ងៃ។

**វិធីប្រើប្រាស់** គឺយកឈ្នាងទៅដាក់ជិតមាត់ទឹករួចយកសម្រាស់ទៅរៀបក្នុងឈ្នាង ហើយបិទសន្ទះគូទរួចរុញទំលាក់ទឹកអោយលិចឈ្នាងរួចបោះបង្គោលចងទុកដោយបែរមុខមករកច្រាំងហើយលើកក្នុងមួយថ្ងៃពីរដង ពេលព្រឹកនិងពេលល្ងាច ឬនៅពេលដែលត្រីមិនសូវត្រូវគេអាចដាក់រហូតដល់ ២-៣ថ្ងៃ ទើបលើកមើលម្តង នៅពេលដែលលើកម្តងៗត្រូវមានគ្នា ២-៣ នាក់ ដើម្បីធ្វើការជួយលើកគ្នា ហើយនៅពេលដែលលើកម្តងៗបានត្រីចំនួនពី ២-៥ គីឡូក្រាម។

**ទីកន្លែង** តាមពាមអូរ កន្ទុយកោះ ច្រាំងទន្លេ បឹង អូ។

**រដូវកាលប្រើប្រាស់** ចាប់ពីខែកក្កដាដល់ខែវិច្ឆិកា ដាក់នៅតាមទន្លេតែបើដាក់នៅតាមបឹងរឺអន្លង់គឺដាក់បានពេញមួយឆ្នាំ។

**ប្រភេទត្រីដែលនេសាទបាន** មានត្រីរៀល ត្រីឆ្លាំង ត្រីឆ្លូញ ត្រីខ្ញឹង កំពិស ត្រីឆ្ពិន ត្រីរ៉ស់ ត្រីក្រាយ ត្រីស្លាត ត្រីចង្វា បង្កង និងប្រភេទត្រីតូចៗជាច្រើនទៀត។

**អ្នកប្រើប្រាស់** ភាគច្រើនជាបុរសដែលពេញកម្លាំង។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើប្រាស់ទេ ព្រោះមិនសូវចេះធ្វើ ហើយត្រូវប្រើមនុស្ស២ទៅ៣នាក់នៅពេលលើក គេប្រើសំណាញ់វិញស្រួលជាង ។

## ៦.២ កន្ទ្រុំ



រូបភាពដកស្រង់ចេញពីសៀវភៅរដ្ឋបាលជលផល

**លក្ខណៈរូប** រាងរបស់កន្ទ្រុំគឺដូចជាសំបុកសត្វស្លាបផ្សេងៗ ដែលវាធ្វើនៅតាមមែកឈើ ។

**វិធីធ្វើ** គឺគាប់មែកឈើតូចៗ ដូចជាមែករំរៃ មែកអំពែ្លង ភ្នំភ្លេង ដើមធ្មេញត្រី ដែលមានលក្ខណៈទន់ៗស្អិតៗងាយរលួយ ។ ដំបូងកាប់ដើមទាំងនោះយកទៅហាលអោយជ្រុះស្លឹកអស់រួចយកទៅចងជាបាច់ ចងក្បាល និងកន្ទុយដែលមានទំហំ ៣ -៤តឹក ប្រហែលជាមួយម៉ែត្រ ។

**វិធីប្រើប្រាស់** យើងចងមែកឈើជាបាច់ រួចយកវាទៅដាក់ក្នុងទឹកបានរយៈពេល១ថ្ងៃទើបលើយកមកដាក់លើគោក បើត្រីចូលក្នុងនេះយើងអាចចាប់វាបានយ៉ាងងាយស្រួល ។



**ប្រភេទត្រីដែលនេសាទបាន** មានដូចជា ត្រីឆ្លាំង ត្រីចង្វា ត្រីកញ្ចុះ កំពិសដែលជាប្រភេទត្រីតូចៗ ។

**ទីកន្លែងដាក់** ភាគច្រើនដាក់នៅតាមអន្លង់ ទន្លេ អូរ ពាមអូរ តាមព្រៃក្បែរថ្មនៅតាមច្រាំង ។

**រដូវកាលដាក់** ដាក់ចាប់ពីខែ មករា -មេសា ។

**អ្នកប្រើប្រាស់** ទាំងបុរស និងស្ត្រី ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិមិនសូវប្រើប្រាស់ទេ ពីព្រោះវាដាក់ត្រីមិនសូវបានដូចកាលពីមុន ព្រោះពីមុនសំបូរត្រី ពួកគាត់ប្រែមកប្រើប្រាស់ មង សំណាញ់ និង លបវិញព្រោះអាចរកបានត្រីច្រើនជាង ។

## ជំពូក ៧ៈ ឧបករណ៍លំពែង

## ៧.១ សាង



**លក្ខណៈរូប** មានផ្លែធ្វើពីដែក ដងធ្វើពីឫស្សីប៉ុនមេដៃប្រវែង ៤ ម៉ែត្រ ទំហំដងមានមុខកាត់ទំហំ ៣ ហ៊ុន ផ្លែសាងគេអាចយកឆ្អឹងឆ័ត្រ ឬកាំម៉ូតូ ចំនួន ៨ដើម ។

**វិធីធ្វើ** ដំបូងគេកាប់ឫស្សីប៉ុនមេជើងដែលមានប្រវែង ៤ ម៉ែត្រ និងផ្លែរបស់វាធ្វើអំពីកាំកង់ឬកាំម៉ូតូចំនួន ៨ដើម ដែលមានប្រវែង ១,៥តឹក ហើយយកដែកនោះទៅវាយបញ្ចូលទៅក្នុងប្រវែងដែកកីឈើ ០,៥តឹក ដើម្បីដាក់អមអមអោយវារឹងដើម្បីកុំអោយវាហែកចេញពីគ្នានិងមានចន្លោះកាន់តែធំ ។ ផ្លែស្វាងត្រូវបានគេយកទៅសំលៀងអោយមុតស្រួច ។ផ្លែសាងនេះមិនធ្វើងាយនោះទេព្រោះគេធ្វើវាជារាងត្រង់ៗតែម្តង ។



**វិធីប្រើប្រាស់** នៅពេលយប់ទើបគេដើរឆ្លុះតាមទន្លេ បឹង អូរ បើឃើញត្រី ឬកង្កែបយើងឆ្លុះពិលអោយចំ ហើយដើរទៅជិតយកសាងនោះចាក់អោយចំ ។

**ប្រភេទត្រីដែលនេសាទបាន** មានដូចជា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង កន្ធាយ កង្កែប ពស់ ។

**រដូវកាលនេសាទ** គឺប្រើបានពេញមួយឆ្នាំ ។

**ទីកន្លែងនេសាទ** នៅតាមវាលស្រែ តាមមាត់ទន្លេ អូរ បឹង និងនៅតាមកោះតូចៗ ។

**អ្នកប្រើប្រាស់** ភាគច្រើនបុរស ។

**ការវិវត្តន៍** ប្រជាជននៅក្នុងភូមិភាគច្រើនប្រើនៅពេលយប់ ហើយមានភ្លៀងទើបពួកគាត់ចេញទៅឆ្លុះ ។

# មជ្ឈមណ្ឌលត្រីពិភពលោក

វើលហ្វីស- សមាជិកមួយនៃសហាគមពិគ្រោះយោបល់សម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិដែលហៅកាត់ថា ស៊ីជីអាយអេអ (CGIAR) គឺជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញមួយ។ ស៊ីជីអាយអេអ គឺជាស្ថាប័នដៃគូសកលមួយដែលរួបរួមអង្គការស្រាវជ្រាវនានាដើម្បីសន្តិសុខស្បៀងនាពេលអនាគត។ ការស្រាវជ្រាវរបស់ស៊ីជីអាយអេអផ្តោតលើការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ បង្កើនសន្តិសុខស្បៀង កែលម្អសុខមាលភាពមនុស្សជាតិ និងអាហារូបត្ថម្ភ និងធានាឲ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព។ ការស្រាវជ្រាវនេះ អនុវត្តដោយមជ្ឈមណ្ឌលស្រាវជ្រាវចំនួន១៥ ដែលសុទ្ធសឹងជាសមាជិករបស់សហាគមស៊ីជីអាយអេអ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធិពីសំណាក់អង្គការជាដៃគូជាង១០០ផ្សេងទៀត ដែលរួមទាំងវិទ្យាស្ថានស្រាវជ្រាវនៅថ្នាក់ជាតិ និងថ្នាក់តំបន់ អង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ និង វិស័យឯកជន។

វើលហ្វីសប្តេជ្ញាសម្រេចគោលដៅអភិវឌ្ឍន៍ចំបងៗចំនួនពីរគឺ ១. លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនជាពិសេស ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ នៅតាមទីកន្លែងនានាដែលវិស័យជលផល និងវារីវប្បកម្មធ្វើឲ្យមានការប្រែប្រួលវិជ្ជមាន និង ២. បង្កើនការផ្គត់ផ្គង់ជាទ្រង់ទ្រាយធំ និងការទទួលបានធនធានត្រីដែលមានតម្លៃសមរម្យសម្រាប់ប្រជាជនក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទន្ទឹមនឹងធានានិរន្តរភាពបរិស្ថាន។

ដើម្បីសម្រេចគោលដៅទាំងនេះ ការស្រាវជ្រាវរបស់យើងគឺផ្តោតទៅលើការបង្កើត និងប្រមូលផ្តុះចំណេះដឹង ដែលយើងអាចចែកចាយបន្ត និងអាចយកទៅប្រើប្រាស់បាន។

ផ្តើមចេញពីការប្រមូលផ្តុំ និងការវិភាគថ្មីៗដែលផ្តោតចំគោលដៅ ការអនុវត្តនៅថ្នាក់មូលដ្ឋាន និងការចែកចាយចំណេះដឹង បច្ចេកវិទ្យា ផលិតកម្ម និងសេវាកម្មរបស់យើងជួយឲ្យការអភិវឌ្ឍកើតមានឡើង ទន្ទឹមខ ខខ្លែនសូត្រអំពីរបៀបធ្វើយ៉ាងណាឲ្យបានប្រសើរជាងមុន។ ដោយមានអ្នកវិទ្យាសាស្ត្រ និងបុគ្គលិកសរុប ច្រើនជាង៣៥៣នាក់ ដែលមានមូលដ្ឋាននៅក្នុង៨ប្រទេសនៅក្នុងទ្វីបអាស៊ី អាហ្វ្រិក និងប៉ាស៊ីហ្វិក យើងធ្វើការនៅក្នុងប្រទេសច្រើន

ជាង ១៩ នៅលើពិភពលោក។ បច្ចុប្បន្ននេះ ការិយាល័យថ្នាក់តំបន់ ឬ ប្រចាំប្រទេសរបស់



យើង ស្ថិតនៅក្នុងប្រទេស បង់ក្លាដែស កម្ពុជា អេហ្ស៊ីប ម៉ាឡាវី ម៉ាឡេស៊ី (ស្នាក់ការកណ្តាល) ហ្វីលីពីន កោះសូឡូម៉ុង និងហ្សំប៊ី។

បេសកកម្មរបស់វើលហ្វីសមានឥទ្ធិពលមកលើអាយុជីវិតរបស់ប្រជាជនជាច្រើនលាននាក់ដែលរស់នៅ និងមានជីវភាពពឹងផ្អែកលើត្រី។ យើងមានមោទនភាពចំពោះតួនាទីរបស់យើង នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈធនធានជលផល និងវារីវប្បកម្ម។

# សម្ព័ន្ធភាពតំបន់ដីសើម

សម្ពន្ធភាពតំបន់ដីសើម គឺជាសមាគមដែលបានបង្កើតឡើងដោយភ្នាក់ងារអភិវឌ្ឍន៍មួយចំនួន ដែលមានការតាំងចិត្តខ្ពស់ក្នុងការផ្តួចផ្តើមបង្កើតគំនិតថ្មី និងធ្វើការអភិវឌ្ឍប្រកបដោយការច្នៃប្រឌិតដើម្បីកាត់បន្ថយភាពក្រីក្រ។ ដៃគូរបស់សម្ពន្ធភាពនេះជឿជាក់ថាការកាត់បន្ថយភាពក្រីក្រអាចធ្វើទៅបានល្អ នៅពេលដែលមានអន្តរអំពើកើតចេញមកពីកម្រិតមូលដ្ឋាន ការទំនាក់ទំនងយ៉ាងសកម្ម និងធ្វើការកែលម្អធនធានក្នុងតំបន់ដីសើម និងវារីជាតិ ដែលជាគំនិតផ្តួចផ្តើម ដើម្បីកាត់បន្ថយភាពក្រីក្រនៅអាស៊ីអាគ្នេយ៍។ តំបន់ដីសើមគឺជាធនធានដែលប្រជាជនក្រីក្រ នៅក្នុងមូលដ្ឋានពឹងអាស្រ័យខ្លាំងបំផុត។

នាពេលបច្ចុប្បន្ន សម្ព័ន្ធភាពបានធ្វើការជាមួយអង្គការដៃគូប្រហែលជា៥0នៅក្នុងតំបន់អាងទន្លេមេគង្គ។ ការងារអភិវឌ្ឍ និងអនុវត្តដោយអង្គការដៃគូនៅកម្រិតមូលដ្ឋាន ថ្នាក់ស្រុក និងថ្នាក់ខេត្ត បានផ្តល់ផលប្រយោជន៏ដោយផ្ទាល់ តាមរយៈការខិតខំប្រឹងប្រែងកសាងសមត្ថភាពដែលគាំទ្រដោយអង្គការដៃគូនៅថ្នាក់តំបន់។ បន្ថែមពីលើភាពខ្លាំងដែលផ្តល់ឱ្យដោយអង្គការដៃគូផ្សេងៗគ្នា គឺការរួមបញ្ចូលនៃចំណេះដឹង និងជំនាញសំរាប់ថ្នាក់តំបន់។

បច្ចុប្បន្ន សម្ព័ន្ធភាពរួមបញ្ចូលដោយអង្គការដៃគូថ្នាក់តំបន់រួមមាន:

- វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT)
- កូរិន-អាស៊ី (CORIN-ASIA)
- មជ្ឈមណ្ឌលត្រីពិភពលោក (The WorldFish Center)
- មូលនិធិពិភពលោកដើម្បីអភិរក្សធម្មជាតិ (WWF)
- និងអង្គការដៃគូនៅថ្នាក់មូលដ្ឋានជាង៥0ដែលស្ថិតនៅប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម

មានប្រជាជនរាប់លាននាក់នៅក្នុងសហគមន៏តូចៗនៃភូមិភាគអាស៊ីអាគ្នេយ៍ ពឹងផ្អែកតាមបែបផែនផ្សេងៗគ្នាលើធនធានតំបន់ដីសើម។ តំបន់ដីសើមគឺជាចំណុចចំបងក្នុងការចូលរួមផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ សម្ព័ន្ធភាពនេះផ្តោតសំខាន់លើ៤ចំណុចចំបងៗគឺ ១- ការបែងចែកផលប្រយោជន៏រួម ២- ការអភិវឌ្ឍ និងការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ៣-ធនធានវារីជាតិ ៤- ការផ្លាស់ប្តូរគោលនយោបាយស្ថាប័ន និងសុវត្ថិភាពធនធានដែលចាំបាច់សម្រាប់ប្រើប្រាស់តាមរយៈការអភិវឌ្ឍសមត្ថភាព។

សម្ព័ន្ធភាពនេះផ្សារភ្ជាប់ទំនាក់ទំនងទៅថ្នាក់តំបន់ និងអង្គការអន្តរជាតិ និងផ្តួចផ្តើមដើម្បីជួយការងារទាំងនេះ អោយដល់ថ្នាក់មូលដ្ឋាន និងសម្របសម្រួលលទ្ធផលការងារដែលបានមកពីថ្នាក់មូលដ្ឋាន ដើម្បីយកទៅជជែកវែកញែកនៅក្នុងអង្គសិក្ខាសាលា និងកិច្ចប្រជុំនៅថ្នាក់តំបន់។ កិច្ចពិភាក្សារបស់ដៃគូនៅថ្នាក់តំបន់



រួមបញ្ចូលជាមួយភ្នាក់ងារជាច្រើនទៀតដូចជា អង្គការស្បៀងអាហារ និងកសិកម្ម (FAO) វិទ្យាស្ថាន-បរិស្ថានស្តុកហូម (SEI) មជ្ឈមណ្ឌលអភិវឌ្ឍន៏វិស័យជលផលអាស៊ីអាគ្នេយ៍ (SEAFDEC) និងគណៈកម្មការទន្លេមេគង្គ (MRC) **...** ។ល។ និងកិច្ចផ្តួចផ្តើមសម្រាប់ព្រៃកោងកាងនាពេលអនាគត។

THE WETLANDS ALLIANCE

BUILDING LOCAL CAPACITY FOR SUSTAINABLE WETLANDS MANAGEMENT

# អង្គការសេប៉ា

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (សេប៉ា) គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមិនប្រកាន់គណបក្សនយោបាយ និងមិនស្វែងរកផលចំណេញ ។ អង្គការនេះ មានសមាសភាពបុគ្គលិកជានិស្សិត និងអ្នកឯកទេសផ្សេងៗ ដែលមានចំណាប់អារម្មណ៍លើការអភិរក្សវប្បធម៌ជនជាតិដើមភាគតិច និងការពារបរិស្ថាន។ អង្គការនេះទទួលស្គាល់ពីសារៈសំខាន់នៃទស្សនៈ គំនិត ចំណេះដឹង បទពិសោធន៍ និងយោបល់របស់ប្រជាពលរដ្ឋ ដើម្បីមានឥទ្ធិពលទៅលើគំរោងអភិវឌ្ឍន៍ ការបង្កើនផលចំណេញជាអតិបរិមាដល់សហគមន៍ដែលមានស្ត្រី បុរស និងក្រុមជនជាតិដើម រួបរួមគ្នាពង្រឹងសិទ្ធិអំណាច និងធ្វើការជាមួយគ្នាដើម្បីគ្រប់គ្រងទន្លេ និងធនធានធម្មជាតិ និងកសាងការចិញ្ចឹមជីវិតឲ្យមាននិរន្តរភាព តាមរយៈចំណងទាក់ទងគ្នានៃយុទ្ធសាស្ត្របង្កើតសហគមន៍ និងការកសាងសមត្ថភាព ការតស៊ូមតិ និងការបង្កើតជាបណ្តាញការងារ។ អង្គការនេះ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋាន ឲ្យដើរតួយ៉ាងសំខាន់នៅក្នុងការផ្តល់យោបល់ដល់គោលនយោបាយការពារសិទ្ធិខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅថ្នាក់ជាតិ និងតំបន់ ។ តំបន់ជាគោលដៅរបស់អង្គការសេប៉ា សព្វថ្ងៃនេះ គឺនៅក្នុងខេត្តស្ទឹងត្រែង ដែលតាំងនៅភាគឦសាននៃប្រទេសកម្ពុជា ជាកន្លែងដែលសំបូរធនធានធម្មជាតិ ជាពិសេសនៅតាមដងទន្លេមេគង្គ និងដៃទន្លេនេះ ។

**អាសយដ្ឋាន:** ផ្ទះលេខ ៥៩ ផ្លូវលេខ ១៥៦ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជា ណាចក្រកម្ពុជា ប្រអប់សំបុត្រលេខ ១៨៨៦ ទូរស័ព្ទ: ០២៣ ៨៨១ ៦១៣ ទូរសារ: ០២៣ ២៦៩ ១៧៩ អ៊ីម៉ែល cepa@cepa-cambodia.org

ការិយាល័យខេត្តស្ទឹងត្រែង ស្ថិតនៅឃុំកណ្តាល ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ទូរស័ព្ទ: ០៧៤ ៩៧៣ ៨៥៨ ។



## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះខនឌិន

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | គីម ប៊ុនវ៉ែត | ប | ៤៣ | កណ្តាលភូមិ | 011 42 39 81 |
| ២ | មឿន ស្រីណាន | ស | ២១ | កណ្តាលភូមិ | |
| ៣ | ប៉ែន គន្ធា | ស | ៦៣ | កណ្តាលភូមិ | |
| ៤ | កែវ សារ៉ាត់ | ប | ២០ | កណ្តាលភូមិ | 097 21 78 290 |
| ៥ | ម៉ៅ ហង្ស | ស | ៣៨ | កណ្តាលភូមិ | |
| ៦ | អ៊ុល សារឿន | ប | ៤៨ | កណ្តាលភូមិ | |
| ៧ | អ៊ឹម ធន | ប | ៥១ | កណ្តាលភូមិ | |
| ៨ | ហេង សិទ្ធិ | ប | ២៩ | កណ្តាលភូមិ | |
| ៩ | ចាន់ ខូវ | ស | ៤៥ | កណ្តាលភូមិ | |
| ១០ | ហេង ធន | ប | ៤៤ | កណ្តាលភូមិ | 097 23 65 148 |
| ១១ | ម៉ៅ សារ៉េត | ប | ៦២ | កណ្តាលភូមិ | 012 35 62 40 |
| ១២ | ម៉ៅ សុគឿន | ស | ៣៥ | កណ្តាលភូមិ | |
| ១៣ | ចាន់ តី | ស | ២៣ | កណ្តាលភូមិ | |
| ១៤ | អ៊ឹម ម៉ៅ | ប | ៤៦ | កណ្តាលភូមិ | |
| ១៥ | សៀង វុទ្ធី | ស | ២៨ | កណ្តាលភូមិ | |
| ១៦ | អៀង ចាន់ណា | ស | ២៤ | កណ្តាលភូមិ | |
| ១៧ | សែម សាវន | ស | ៤៨ | កណ្តាលភូមិ | |
| ១៨ | នូវ ហាត | ប | ៣៦ | កណ្តាលភូមិ | |
| ១៩ | មាស សារិត | ប | ៣០ | កណ្តាលភូមិ | |
| ២០ | ហេង ធឿន | ស | ៤១ | កន្ទុយភូមិ | |
| ២១ | ចាន់ ដានី | ស | ២៤ | កន្ទុយភូមិ | |
| ២២ | ម៉ក់ ស្រីអន | ស | ២២ | កន្ទុយភូមិ | 088 58 25 220 |

## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះខនខិន (ត)

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ២៣ | សឹម នឿន | ស | ៤១ | កន្ទុយភូមិ | |
| ២៤ | ម៉ាក់ វ៉ាម៉េត | ប | ២៤ | កន្ទុយភូមិ | |
| ២៥ | ឡាន់ សោមន្នី | ស | ២៦ | កន្ទុយភូមិ | |
| ២៦ | សេង សេន | ស | ៤៨ | កន្ទុយភូមិ | |
| ២៧ | ព្រំ សាវឿន | ស | ៣១ | កន្ទុយភូមិ | 092 95 12 16 |
| ២៨ | សៅ វី | ប | ៤៣ | ក្បាលភូមិ | |
| ២៩ | នាង តាំង | ប | ៧៣ | ក្បាលភូមិ | |
| ៣០ | ហែម ជា | ប | ៥០ | ក្បាលភូមិ | |
| ៣១ | អ៊ុំម ប៊ុនឈុន | ប | ៤៨ | ក្បាលភូមិ | |
| ៣២ | យិន ជីន | ប | ៤៤ | កណ្តាលភូមិ | 097 574 973 5 |
| ៣៣ | ម៉ៅ សារ៉ុន | ស | ៥២ | ក្បាលភូមិ | |
| ៣៤ | ភូម៉ា សុខគី | ប | ៦០ | ក្បាលភូមិ | |
| ៣៥ | មូល ស្រីស | ស | ២០ | ក្បាលភូមិ | 097 901 157 3 |
| ៣៦ | ហួយ លក្ខិណា | ស | ២៥ | ក្បាលភូមិ | |
| ៣៧ | មឹង គឹមស្រ៊ាន | ស | ៦២ | ក្បាលភូមិ | |
| ៣៨ | ទៀង យន | ប | ៤៩ | កន្ទុយភូមិ | |
| ៣៩ | គឹម ហម | ស | ៤៩ | ក្បាលភូមិ | |
| ៤០ | ញ៉ែន ផល្លា | ប | ៤៨ | កណ្តាលភូមិ | |
| ៤១ | វ៉ាន គន្ធា | ស | ២៨ | ក្បាលភូមិ | |

ស្រីចំនួន ២២នាក់

ប្រុសចំនួន ១៩នាក់



## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះស្នែង

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | បួន ហ្វៃន | ស | ១៩ | កណ្តាលភូមិ | |
| ២ | សាយ មុន្នី | ស | ២២ | កណ្តាលភូមិ | |
| ៣ | ដា យ៉ាន់ | ស | ៥៧ | កណ្តាលភូមិ | |
| ៤ | គី ទី | ប | ៣៨ | កណ្តាលភូមិ | |
| ៥ | ម៉ា ប៊ុតសា | ស | ២២ | កណ្តាលភូមិ | |
| ៦ | ឆោម ញឹម | ប | ៥៥ | កណ្តាលភូមិ | 011 69 34 17 |
| ៧ | ថាំង បួរ | ស | ២១ | កណ្តាលភូមិ | |
| ៨ | ផង ថានីន | ស | ២៤ | កន្ទុយភូមិ | 076 73 05 913 |
| ៩ | គី ម៉ាឡៃ | ស | ១៩ | កន្ទុយភូមិ | 097 48 09 034 |
| ១០ | ឡុត សាន់ | ស | ១៨ | កន្ទុយភូមិ | |
| ១១ | មុក សុនី | ស | ៥៧ | កន្ទុយភូមិ | |
| ១២ | ភូមិ ថៃ | ស | ៤៨ | កន្ទុយភូមិ | |
| ១៣ | មុត សុខា | ស | ១៧ | កន្ទុយភូមិ | |
| ១៤ | ឡា ចាន់ថា | ស | ១៩ | កន្ទុយភូមិ | |
| ១៥ | ឡុញ ហុន | ប | ២៦ | កន្ទុយភូមិ | |
| ១៦ | ពុន ណា | ស | ១៩ | កន្ទុយភូមិ | |
| ១៧ | ថៃ វ៉ាង | ប | ២០ | កន្ទុយភូមិ | |
| ១៨ | គឿង វុធ | ប | ៥៧ | ក្បាលភូមិ | 011 49 96 30 |
| ១៩ | លៀង ចាន់ | ប | ៥៥ | ក្បាលភូមិ | 011 43 49 21 |
| ២០ | បួរ ខាំតង | ស | ៣៨ | ក្បាលភូមិ | 097 98 13 154 |
| ២១ | លឹម សៃ | ប | ៤០ | ក្បាលភូមិ | 099 77 42 83 |
| ២២ | សន យ៉ាត | ស | ៤៤ | ក្បាលភូមិ | 11 69 34 17 |

## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះស្នែង (ត)

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ២៣ | តឹម ហ៊ុន | ប | ៣៧ | ក្បាលភូមិ | |
| ២៤ | លេង លីណា | ស | ១៩ | ក្បាលភូមិ | 097 72 59 891 |
| ២៥ | ភូមិ ប៉ាន់ | ស | ៤៥ | ក្បាលភូមិ | |
| ២៦ | សាយ សុភាព | ប | ៣០ | ក្បាលភូមិ | |
| ២៧ | សៀង កេត | ប | ៣៥ | ក្បាលភូមិ | |
| ២៨ | ថង វិរៈ | ប | ២៦ | ក្បាលភូមិ | |
| ២៩ | ហួត ល័យ | ស | ១៩ | ក្បាលភូមិ | |
| ៣០ | យូន យឿ | ស | ៥៧ | ក្បាលភូមិ | |
| ៣១ | យូន ភឿ | ស | ៥៩ | ក្បាលភូមិ | |
| ៣២ | ឡុត ចឹង | ប | ៥៩ | ក្បាលភូមិ | |
| ៣៣ | លិត សុភិត | ស | ២៣ | ក្បាលភូមិ | |
| ៣៤ | សៃ សួយ | ប | ៤៤ | ក្បាលភូមិ | |
| ៣៥ | ផាយ តឿង | ប | ៥៥ | ក្បាលភូមិ | |
| ៣៦ | លៀន សុខុម | ប | ៤៣ | កណ្តាលភូមិ | 011 640 547 |
| ៣៧ | និន ភិរុណ | ប | ២៧ | កណ្តាលភូមិ | |
| ៣៨ | សន សុខន | ប | ៤៩ | ក្បាលភូមិ | |
| ៣៩ | ផេង ចម | ប | ៥៧ | ក្បាលភូមិ | |
| ៤០ | ខាំ ឡឿ | ស | ៤៨ | កណ្តាលភូមិ | |
| ៤១ | ផាយ ហម | ស | ៤៨ | ក្បាលភូមិ | |
| ៤២ | ថាំង លែត | ស | ២៥ | កណ្តាលភូមិ | 097 575 187 7 |
| ៤៣ | នូ ល័យ | ស | ៥៤ | ក្បាលភូមិ | |
| ៤៤ | ភិត សំអន | ប | ៣២ | ក្បាលភូមិ | |



## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះស្នែង (ត)

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ៤៥ | លឿង ថាវី | ប | ៦៦ | ក្បាលភូមិ | |
| ៤៦ | ចាន់ ធឿង | ប | ២៦ | ក្បាលភូមិ | |
| ៤៧ | ឡាន យន | ស | ៤១ | កណ្តាលភូមិ | |
| ៤៨ | បួន ខាន | ប | ៣០ | កណ្តាលភូមិ | |
| ៤៩ | ម៉ឺន ជិត | ប | ៣៣ | កណ្តាលភូមិ | |
| ៥០ | ប្អូ វ៉ាន់ | ប | ៤២ | កណ្តាលភូមិ | |
| ៥១ | ថា លីហាវ | ប | ២៤ | កណ្តាលភូមិ | 011 65 60 60 |
| ៥២ | វី សារុន | ប | ៤២ | កណ្តាលភូមិ | 011 436 175 |

ស្រីចំនួន ២៦នាក់

ប្រុសចំនួន ២៦នាក់

## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិវីនសៀន

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំង | លេខទូស័ព្ទ |
|---|---|---|---|---|---|
| ១ | ស៊ី ចាន់ដន | ស | ៥៥ | កណ្តាលភូមិ | 011 93 50 48 |
| ២ | ឡុង នឹក | ប | ៥១ | កណ្តាលភូមិ | 011 282 572 |
| ៣ | ញឹម សៀន | ប | ៤២ | កណ្តាលភូមិ | |
| ៤ | ពុត កន | ប | ៣៥ | កណ្តាលភូមិ | |
| ៥ | ពុត ស៊ូ | ប | ៣៧ | កណ្តាលភូមិ | 099 806 725 |
| ៦ | យិន សុឃិត | ប | ៤២ | កណ្តាលភូមិ | |
| ៧ | ប៉ន យ៉ាន | ប | ២៩ | កណ្តាលភូមិ | |
| ៨ | សាយ ហួន | ប | ៥៥ | កណ្តាលភូមិ | |
| ៩ | មុំ ខា | ប | ៣០ | កណ្តាលភូមិ | 097 290 272 4 |
| ១០ | ប្រាក់ ខុំ | ប | ៥៦ | កណ្តាលភូមិ | |
| ១១ | ប៊ុ ផន | ប | ៤៦ | កណ្តាលភូមិ | |
| ១២ | ចាន់ វណ្ណី | ប | ៣០ | កណ្តាលភូមិ | |
| ១៣ | សន ផាន់នី | ប | ២៧ | កណ្តាលភូមិ | |
| ១៤ | សារ៉ុន ចៃ | ប | ២៨ | កណ្តាលភូមិ | |
| ១៥ | សៀន ប៊ុនចាន់ | ប | ២០ | កណ្តាលភូមិ | |
| ១៦ | ឱន ខាន់ | ប | ២០ | កណ្តាលភូមិ | |
| ១៧ | អ៊ិន ប៊ុនសុំ | ប | ៥៦ | កន្ទុយភូមិ | 076 750 190 5 |
| ១៨ | ក្លូង ផិង | ប | ៥២ | កន្ទុយភូមិ | |
| ១៩ | ឃី ញុត | ប | ៣៨ | កន្ទុយភូមិ | |
| ២០ | ដាំ វ៉ាន់ | ប | ៣២ | កន្ទុយភូមិ | |
| ២១ | ផៃ ទី | ប | ២៨ | កន្ទុយភូមិ | 011 435 510 |
| ២២ | ដាំ ធន | ប | ២៥ | កន្ទុយភូមិ | |



## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិវីនសៀន (ត)

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ២៣ | ផឹង សុគី | ស | ១៨ | កន្ទុយភូមិ | |
| ២៤ | ភឹម នួនស៊ី | ស | ៣១ | ក្បាលភូមិ | |
| ២៥ | សិត រ៉យ | ប | ២៩ | ក្បាលភូមិ | |
| ២៦ | ញឹម ទូ | ប | ៣០ | ក្បាលភូមិ | |
| ២៧ | ភឹម សុគី | ស | ៤៣ | ក្បាលភូមិ | |
| ២៨ | ស៊ី សុបាន | ប | ៣០ | ក្បាលភូមិ | |
| ២៩ | ដាំ ដើយ | ប | ៣៥ | ក្បាលភូមិ | 011 534 753 |
| ៣០ | យិន មឿន | ប | ៤៥ | ក្បាលភូមិ | |
| ៣១ | ប៊ុ លៀន | ប | ៤២ | ក្បាលភូមិ | |
| ៣២ | ប៊ីនណម | ស | ៤៤ | ក្បាលភូមិ | |
| ៣៤ | សូ សាន់ | ប | ៤៤ | ក្បាលភូមិ | |
| ៣៥ | ផាយ តឿង | ប | ៥៥ | ក្បាលភូមិ | |
| ៣៦ | ដេង ចាន់ | ប | ៦៨ | កណ្តាលភូមិ | |
| ៣៧ | ទុំ ប៊ុនធឿន | ប | ២៥ | ក្បាលភូមិ | |

ស្រីចំនួន ០៥នាក់
ប្រុសចំនួន ៣២នាក់

## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះលូ

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| 1 | កុំ ថង | ប | 49 | ក្បាលកោះ | 088 944 248 6 |
| 2 | ខាំផន ស៊ីទុន | ប | 45 | ក្បាលកោះ | 011 665 983 |
| 3 | ថាន់ តែ | ស | 35 | ក្បាលកោះ | |
| 4 | យូន នូកន | ស | 42 | ក្បាលកោះ | |
| 5 | ថាន់ ថ្លា | ស | 32 | ក្បាលកោះ | |
| 6 | ខាំផន អៀង | ស | 28 | ក្បាលកោះ | |
| 7 | សា ផូ | ប | 48 | ក្បាលកោះ | |
| 8 | ខាំផន នុន | ស | 43 | ក្បាលកោះ | |
| 9 | លីន ស៊ីង | ប | 50 | ក្បាលកោះ | |
| 10 | កុំ ថៃម | ប | 41 | ក្បាលកោះ | |
| 11 | ខាំផុន បូកែវ | ស | 40 | ក្បាលកោះ | |
| 12 | ប៉ាន់ ណយ | ប | 34 | ក្បាលកោះ | |
| 13 | សុង វណ្ណស៊ី | ស | 22 | ក្បាលកោះ | 076 60 75 466 |
| 14 | សុង ខាំឡា | ស | 23 | ក្បាលកោះ | 011 978 996 |
| 15 | ទុន ណាងណយ | ស | 20 | ក្បាលកោះ | |
| 16 | ថង លៀម | ស | 20 | ក្បាលកោះ | |
| 17 | ចាន់ ញ៉ា | ប | 25 | ក្បាលកោះ | |
| 18 | ទើម ហោរ | ប | 25 | ក្បាលកោះ | |
| 19 | សុខ មី | ប | 28 | ក្បាលកោះ | |
| 20 | ខុត អូយ | ប | 43 | ក្បាលកោះ | |
| 21 | គ្រីម ផល | ស | 58 | កន្ទុយកោះ | |
| 22 | យ៉ិវ សន្ធនា | ប | 28 | កន្ទុយកោះ | 076 575 655 6 |



## បញ្ជីឈ្មោះអ្នកស្រាវជ្រាវភូមិកោះលូ (ត)

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីតាំងភូមិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| 23 | រុំ គុណ | ប | 27 | កន្ទុយកោះ | |
| 24 | ប៊ុន ខាន | ប | 28 | កន្ទុយកោះ | |
| 25 | ចន រុំ | ប | 40 | កន្ទុយកោះ | |
| 26 | គី សៃ | ប | 59 | កន្ទុយកោះ | |
| 27 | ប៊ុន ផាន | ប | 30 | កន្ទុយកោះ | |
| 28 | លៀន ហូប | ប | 43 | កន្ទុយកោះ | |
| 29 | ពើ ថុង | ប | 50 | កន្ទុយកោះ | |
| 30 | ណាម តម | ស | 22 | កន្ទុយកោះ | |
| 31 | ប៊ុន ងៀង | ប | 35 | កន្ទុយកោះ | |
| 32 | សៀន កៀ | ប | 31 | កន្ទុយកោះ | |
| 33 | ហាន តិ | ប | 28 | កន្ទុយកោះ | |

ស្រីចំនួន ១២នាក់
ប្រុសចំនួន ២១នាក់